កម្មវិធីពន្លកចំណេះ៖
ទិន្នន័យ និងការពិភាក្សា ដើម្បីការអភិវឌ្ឍនៅកម្ពុជា

# ឯកសារអំណានសម្រាប់វគ្គបណ្ដុះបណ្ដាល ស្ដីពីយុទ្ធសាស្ត្រស្រាវជ្រាវសមភាពយេនឌ័រ និង សង្គមបរិយាបន្ន

ភ្នំពេញ
ខែ កក្កដាឆ្នាំ២០២០

Margherita Maffii
គ្រូបង្គោលសមភាពយេនឌ័រនិងសង្គមបរិយាបន្ន



Australian Aid
ពន្លក ចំណេះ
The Asia Foundation

# មាតិកា


បុព្វកថា i
គោលដៅ និងទិសាលភាព ii

០១ គោលដៅ និងទិសាលភាព ១
១.១. ទស្សនាទានគោល ៣
១.២. យន្តការនៃការផាត់ចេញ ៨
១.៣. ឯកសារសម្រាប់ការពិភាក្សា និងលំហាត់ជាក្រុម ១០

០២ ភាពពាក់ព័ន្ធនៃសមភាពយេនឌ័រ និងសង្គមបរិយាបន្នសម្រាប់កម្ពុជា ១១
២.១. សមភាពយេនឌ័រ៖ វឌ្ឍនភាព និងចំណុចសម្រាប់ការកែលម្អ ១១
២.២. ភាពក្រីក្រ ១៣
២.៣. ជាតិពន្ធុ ១៥
២.៤. អាយុ ១៦
២.៥. ពិការភាព ១៧
២.៦. អត្តសញ្ញាណភេទ ១៧
២.៧. ភាពងាយរងគ្រោះផ្សេងទៀត ១៨
២.៨. ការវិវឌ្ឍ និងការផ្លាស់ប្តូរ ១៨
២.៩. ឯកសារសម្រាប់ការពិភាក្សា និងលំហាត់ជាក្រុម ១៩

០៣ តួនាទីនៃការស្រាវជ្រាវសមភាពយេនឌ័រ និងសង្គមបរិយាប័ន្ន ២៣
៣.១. វិធីសាស្រ្ត ២៦
៣.២. ការចូលរួម ២៨
៣.៣. ការស្រាវជ្រាវជាមួយក្រុមដែលបាត់បង់ឱកាស ៣០
៣.៤. ការគិតគូរពីក្រុមសីលធម៌ ៣១
៣.៥. ឯកសារសម្រាប់ការពិភាក្សា និងលំហាត់ជាក្រុម ៣៣

## ០៤ សមត្ថភាពយេនឌ័រ និងសង្គមបរិយាបន្នក្នុងការស្រាវជ្រាវ ៣៧


៤.១. ក្របខណ្ឌទ្រឹស្តី និងការពិនិត្យឡើងវិញលើឯកសារពាក់ព័ន្ធ ៣៨
៤.២. ធនធាន ៣៩
៤.៣. ទិន្នន័យបន្ទាប់បន្សំដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ និងសង្គមបរិយាបន្ន ៣៩
៤.៤. ការកំណត់ជាមុននូវអត្តសញ្ញាណរបស់ក្រុមដែលបាត់បង់ឱកាស ៤១
៤.៥. ការគ្រោងដំណើរការប្រមូលទិន្នន័យ ៤២
៤.៦. ការរៀបចំឧបករណ៍ស្រាវជ្រាវ ៤៣
៤.៧. ដំណើរការប្រមូលទិន្នន័យ ៤៧
៤.៨. ដំណើរការសម្ភាស និងពិភាក្សា ៤៩
៤.៩. អំពីការបកប្រែ ៥១
៤.១០. អំពីការថតសំឡេងបទសម្ភាសន៍ និងកិច្ចពិភាក្សាក្រុមគោលដៅ ៥២
៤.១១. ចំនួនប៉ុន្មាន? ៥៣
៤.១២. ការផ្ទៀងផ្ទាត់លទ្ធផល ៥៤
៤.១៣. ឯកសារសម្រាប់ការពិភាក្សា និងលំហាត់ជាក្រុម ៥៥


## ០៥ ការវិភាគលទ្ធផល និងការរាយការណ៍ ៥៩


៥.១. ការកត់ត្រា ៥៩
៥.២. ការវិភាគព័ត៌មាន ៦០
៥.៣. អំពី Software សម្រាប់ការវិភាគទិន្នន័យបែបគុណភាព ៦៣
៥.៤. ការសរសេររបាយការណ៍ ៦៤
៥.៥. អនុសាសន៍ ៦៦
៥.៦. ឯកសារយោង ៦៧
៥.៧ ការអានពិនិត្យផ្ទៀងផ្ទាត់ ៦៧
៥.៨. ការជួយពិនិត្យ ៦៨
៥.៩. សេចក្តីថ្លែងអំណរគុណ និងការផ្តល់កិត្តិយស ៦៨
៥.១០. ឯកសារសម្រាប់ការពិភាក្សា និងលំហាត់ជាក្រុម ៦៩
ឯកសារយោង ៧៣



# បុព្វកថា

ឯកសារគាំទ្រវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធសាស្ត្រស្រាវជ្រាវនេះ ត្រូវបានបង្កើតឡើងជាធនធានបន្ថែម សម្រាប់អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលចំនួន២ ស្តីពីយុទ្ធសាស្ត្រស្រាវជ្រាវសមភាពយេនឌ័រ និងសង្គម បរិយាបន្ន (GESI) ដែលបានធ្វើឡើងនៅខែ មិថុនា ឆ្នាំ ២០២០។ ឯកសារទាំងនេះមានព័ត៌មានបន្ថែម ឯកសារយោង និងតំណភ្ជាប់ដែលនឹងបង្កើនចំណេះដឹងដែលទទួលបានក្នុងវគ្គទាំងនេះ។ កំណែឯកសារថ្មីនេះក៏ពិចារណាពីសំណូម ពរ និងមតិយោបល់របស់អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ ទាំងពីរនេះផងដែរ។

វគ្គបណ្តុះបណ្តាលនេះបានធ្វើឡើងតាមប្រព័ន្ធអនឡាញ ដោយសារតែកាលៈទេសៈពិសេស ក្នុងអំឡុងវិបត្តិកូវីដ ១៩។ វគ្គបណ្តុះបណ្តាលអនឡាញនេះសម្រួលដល់អ្នកចូលរួមអាចរៀនសូត្រពីចម្ងាយ ប៉ុន្តែប្រឈមនឹងបញ្ហាមួយចំនួន ដូចជា ពេលវេលាខ្លី និងបញ្ហា បណ្តាញអ៊ីនធឺណិត។

ដូច្នេះ កម្រងឯកសារអំណាននេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ខ្លឹមសារបណ្តុះបណ្តាលទាំងអស់ដល់អ្នកចូលរួម និងដើរតួនាទីជាធនធានគ្រប់ជ្រុងជ្រោយដែលផ្តល់ឯកសារយោង វិធីសាស្ត្រកាន់តែស៊ីជម្រៅ តំណភ្ជាប់ទៅកាន់ព័ត៌មានដែលមានប្រយោជន៍ ករណីសិក្សា និងលំហាត់ដែលបានបង្កើតឡើងក្នុងវគ្គបណ្តុះបណ្តាល។



# គោលដៅ និងវិសាលភាព

ក្នុង និងក្រោយវគ្គបណ្តុះបណ្តាល អ្នកចូលរួមជាច្រើនបានស្នើសុំព័ត៌មានបន្ថែម និងជាតុចូលពាក់ព័ន្ធនឹងបញ្ហានានា ដូចជា ការបញ្ជ្រាបយេនឌ័រការវិភាគយេនឌ័រ និងវិធីសាស្ត្រស្រាវជ្រាវ។ ដោយសារតែវគ្គបណ្តុះបណ្តាលនេះផ្តោតលើវិធីសាស្ត្រដែលត្រូវពិចារណា ក្នុងពេលស្រាវជ្រាវសមភាពយេនឌ័រ និងបរិយាប័ន្នសង្គម ក្រុមបណ្តុះបណ្តាលបានកំណត់ពីតម្រូវការធនធានដាច់ដោយឡែកសម្រាប់អ្នកចូលរួម។ កម្រងឯកសារអំណាននេះផ្តល់ព័ត៌មានបន្ថែមដែលមានសារៈសំខាន់សម្រាប់សមភាពយេនឌ័រ និងបរិយាបន្នសង្គម និងមិនមែនជាការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយពីវិធីសាស្ត្រវិភាគយេនឌ័រ និងវិធីសាស្ត្រស្រាវជ្រាវផ្នែកសង្គមឡើយ ប៉ុន្តែជាការផ្តល់ទិដ្ឋភាពរួម ស្តីពីរបៀបអនុវត្តការស្រាវជ្រាវពីសមភាពយេនឌ័រ និង សង្គមបរិយាបន្ន។



# ១ សញ្ញាណទូទៅស្តីពីសមភាពយេនឌ័រ និងសង្គមបរិយាបន្ន

“*សមភាពយេនឌ័រ និងសង្គមបរិយាបន្ន (GESI) គឺជាទស្សនទានមួយដែលដោះស្រាយពីវិសមភាពនៃទំនាក់ទំនងអំណាចរបស់មនុស្សដោយផ្អែកលើយេនឌ័រ ទ្រព្យសម្បត្តិ លទ្ធភាព ទីតាំង វណ្ណៈ/ជាតិពន្ធុ ភាសា និងទីភ្នាក់ងារ ឬការបញ្ចូលគ្នានៃសមាសភាគទាំងអស់នេះ។ សមភាពយេនឌ័រ និងសង្គមបរិយាបន្នផ្តោតលើសកម្មភាពចាំបាច់ដើម្បីរក្សាតុល្យភាពទំនាក់ទំនងអំណាចទាំងនេះឡើងវិញ កាត់បន្ថយយុគភាព និងធានានូវសិទ្ធិ ឱកាស និងការគោរពដោយស្មើភាពសម្រាប់បុគ្គលគ្រប់រូប ដោយមិនគិតពីអត្តសញ្ញាណសង្គមរបស់ពួកគេ*”

(International Dev. Partners Group Nepal, 2017, p 7)



**សមភាពយេនឌ័រ និងសង្គមបរិយាបន្ន** ពិចារណាថាតើការចាញ់ប្រៀបចម្រុះ និងត្រួតគ្នា បង្កើតការបាត់បង់ឱកាសក្នុងសង្គមដោយរបៀបណា។ ដោយកត់សម្គាល់ពីលក្ខណៈចម្រុះនេះ គេអាចបង្កើតយុទ្ធសាស្ត្រ និងវិធីសាស្ត្រដែលអាចឱ្យក្រុមងាយរងគ្រោះបំផុត ក្រុមជួបការលំបាក និងក្រុមដែលត្រូវបានផាត់ចេញទទួលបាន សំឡេង និងការយកចិត្តទុកដាក់ និងរួមចំណែក និងទទួលបានអត្ថប្រយោជន៍ស្មើគ្នាពីការអភិវឌ្ឍ។ សមភាព យេនឌ័រ និង សង្គមបរិយាបន្នបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ អង្គការសហប្រជាជាតិ (“មិនទុកនរណាម្នាក់ចោល”) និងលើកកម្ពស់ការអភិវឌ្ឍបែបបរិយាបន្ន

(UNDP, 2015b)

សមភាពយេនឌ័រ និងបរិយាបន្នសង្គម ត្រូវបានអនុម័តជាលើកដំបូងជាក្របខណ្ឌអភិវឌ្ឍន៍ក្នុងប្រទេសនេប៉ាល់ ដោយសារការទទួលស្គាល់លក្ខណៈចម្រុះជាច្រើនក្នុងសង្គមនេប៉ាល់ ដូចជា យុគភាពសេដ្ឋកិច្ច ការរើសអើងយេនឌ័រ ប្រព័ន្ធវណ្ណៈដែលធ្វើឱ្យប៉ះពាល់ដល់ក្រុមសង្គមជាច្រើន និងលក្ខណៈចម្រុះនៃជាតិពន្ធុដែលសំបូរដោយក្រុមជនជាតិដើម និងក្រុមជនជាតិភាគតិច។ ដូច្នេះធនធានជាច្រើនស្តីពីសមភាពយេនឌ័រ និងសង្គមបរិយាបន្ន គឺទាញចេញពីបទពិសោធន៍នៅប្រទេសនេប៉ាល់

(International Dev. Partners Group, 2017)

# ១.១. ទស្សនាទានគោល

## យេនឌ័រ

សំដៅលើគុណលក្ខណៈក្នុងសង្គម និងឱកាសដែលពាក់ព័ន្ធនឹងភាពជាបុរស និងភាពជាស្ត្រី និងទំនាក់ទំនងរវាងបុរស និងស្ត្រី និងក្មេងស្រី និងក្មេងប្រុស។ គុណលក្ខណៈ ឱកាស និងទំនាក់ទំនងទាំងនេះត្រូវបានបង្កើតឡើងក្នុងសង្គម និងត្រូវបានរៀនសូត្រតាមរយៈដំណើរការសង្គមនីយកម្ម។ ដំណើរការទាំងនេះផ្អែកតាមបរិបទ/ពេលវេលា និងអាចផ្លាស់ប្ដូរបាន។ យេនឌ័រកំណត់ពីក្ដីរំពឹងទុក ការអនុញ្ញាត និងការឱ្យតម្លៃដល់ស្ត្រី ឬបុរសក្នុងបរិបទណាមួយ។ ក្នុងសង្គមភាគច្រើន មានភាពខុសគ្នា និងវិសមភាពរវាងស្ត្រី និងបុរសលើការកំណត់ការទទួលខុសត្រូវ សកម្មភាពដែលធ្វើឡើង លទ្ធភាពទទួលបាន និងការគ្រប់គ្រងធនធាន និងឱកាសធ្វើសេចក្ដីសម្រេចចិត្ត។ យេនឌ័រជាផ្នែកមួយនៃបរិបទសង្គមវប្បធម៌ទូលំទូលាយ។ លក្ខណៈវិនិច្ឆ័យសំខាន់ៗផ្សេងទៀតសម្រាប់ការវិភាគសង្គមវប្បធម៌ រួមមាន វណ្ណៈ ជាតិសាសន៍ កម្រិតភាពក្រីក្រ ក្រុមជាតិពន្ធុ និងអាយុ (ប្រភព ៖ UN Women)។

## វិសមភាពយេនឌ័រ

សំដៅលើស្ថានភាពផ្លូវច្បាប់ សង្គម និងវប្បធម៌ ដែលភេទ និង/ឬយេនឌ័រកំណត់ពីសិទ្ធិ និងសេចក្ដីថ្លៃថ្នូរផ្សេងៗសម្រាប់ស្ត្រី និងបុរស ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈលទ្ធភាពមិនស្មើភាពរបស់ស្ត្រី និងបុរសក្នុងការទទួលបាន ឬប្រើប្រាស់សិទ្ធិរបស់ខ្លួន និងការសន្មតពីតួនាទីបែបប្រកាន់គំនិតក្នុងសង្គម និងវប្បធម៌។ តួនាទីទាំងនេះប៉ះពាល់ដល់ស្ថានភាពរបស់ស្ត្រីនៅគ្រប់ទិដ្ឋភាពនៃជីវិតក្នុងសង្គម មិនថាជីវិតឯកជន ឬសាធារណៈ ក្នុងគ្រួសារ ឬទីផ្សារការងារ ក្នុងជីវិតសេដ្ឋកិច្ច ឬនយោបាយ ក្នុងអំណាច និងការធ្វើសេចក្ដីសម្រេចចិត្ត ឬក្នុងផ្នែកសុខភាព និងសន្តិសុខឡើយ។ ក្នុងសង្គមទាំងអស់ ស្ត្រីចាញ់ប្រៀបបុរស។ វិសមភាពយេនឌ័រតំណាងឱ្យទិដ្ឋភាពសង្គមទូទៅ ប៉ុន្តែផ្តល់បទពិសោធន៍ខុសគ្នាដល់ក្រុមណាមួយ។ ការរើសអើងដោយផ្អែកលើជាតិពន្ធុសេដ្ឋកិច្ចសង្គមឬអត្តសញ្ញាណអាចត្រួតគ្នានឹងវិសមភាពយេនឌ័រ និងបង្កើតការបាត់បង់ឱកាសច្រើនស្រទាប់ (ប្រភព ៖ UNDP, 2015a)។

## សង្គមបរិយាប័ន្ន

មានន័យថាសមាជិក និងផ្នែកទាំងអស់នៃសង្គមមួយទទួលបានសិទ្ធិ និងអត្ថប្រយោជន៍ស្មើៗគ្នាក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច និងសង្គម ដោយគ្មានការរើសអើងដោយផ្អែកលើភេទ អាយុ តំបន់ភូមិសាស្ត្រ ជាតិពន្ធុ ដើមកំណើត សាវតាអប់រំ ស្ថានភាពសេដ្ឋកិច្ច វណ្ណៈ សាសនា ពិការភាព អត្តសញ្ញាណភេទ ស្ថានភាពសុខភាព ឬកត្តាផ្សេងទៀត (ប្រភព ៖ UN DESA)។

## សមភាពយេនឌ័រ

សំដៅលើសិទ្ធិ ការទទួលខុសត្រូវ និងឱកាសស្មើភាពសម្រាប់ស្ត្រី និងបុរស និងក្មេងស្រី និងក្មេងប្រុស។ សមភាពមិនមានន័យថា ស្ត្រី និងបុរសនឹងធ្វើជាមនុស្សដូចគ្នានោះទេ ប៉ុន្តែវាមានន័យថា សិទ្ធិ ការទទួលខុសត្រូវ និងឱកាសរបស់ស្ត្រី និងបុរស នឹងមិនអាស្រ័យលើថាតើពួកគេកើតមកជាស្រី ឬប្រុសនោះទេ។ សមភាពយេនឌ័របញ្ជាក់ថា ផលប្រយោជន៍ តម្រូវការ និងអាទិភាពរបស់ស្ត្រី និងបុរស ត្រូវបានពិចារណាដោយផ្អែកតាមលក្ខណៈចម្រុះនៃក្រុមអាយុផ្សេងៗរបស់ស្ត្រី និងបុរស។ សមភាពយេនឌ័រមិនមែនជាបញ្ហារបស់ស្ត្រីទេ ប៉ុន្តែគួរពាក់ព័ន្ធ និងចូលរួមពេញលេញដោយបុរស និងស្ត្រី។ សមភាពរវាងស្ត្រី និងបុរសត្រូវបានចាត់ទុកជាបញ្ហាសិទ្ធិមនុស្ស និងជាបុរេលក្ខខណ្ឌសម្រាប់ និងជាសូចនាករនៃការអភិវឌ្ឍប្រកបដោយចីរភាពដែលផ្តោតការយកចិត្តទុកដាក់លើមនុស្ស (ប្រភព ៖ UN Women)។

## ភាពប្រសព្វគ្នា

ការបែងចែកក្នុងសង្គមដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ដូចជា ជាតិសាសន៍ វណ្ណៈ និងយេនឌ័រ ដែលអនុវត្តចំពោះក្រុម ឬបុគ្គលណាមួយ បង្កើតជាការរើសអើង ឬការចាញ់ប្រៀបជាប្រព័ន្ធដែលត្រួតគ្នា និងប្រទាក់ក្រឡាគ្នា។ ភាពប្រសព្វគ្នាអាចឱ្យគេយល់ពីអន្តរកម្មនៃរចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច និងអំណាចផ្សេងៗដែលកំណត់ការគៀបសង្កត់ និង/ឬបុព្វសិទ្ធិ (ប្រភព ៖ C.J.P. Colfer, Sijapati Basnett, & Ihalainen, 2018)។

## ការផាត់ចេញពីសង្គម

ជាដំណើរការដែលបុគ្គល ឬក្រុមនានាត្រូវបាផាត់ចេញទាំងស្រុង ឬដោយផ្អែកពីការចូលរួមពេញលេញក្នុងសង្គមដែលពួកគេរស់នៅ" (ប្រភព ៖ Kabeer, 2005)។ ទស្សនទាននៃការផាត់ចេញពីសង្គមមាន ប្រភពនៅអឺរ៉ុបនៅទសវត្សរ៍ឆ្នាំ ១៩៧០ ប៉ុន្តែទស្សនទាននេះមានភាពពាក់ព័ន្ធក្នុងការសិក្សាអំពីអភិវឌ្ឍន៍តាំងពីពេលនោះមក ហើយបច្ចុប្បន្នបានក្លាយជាការប្តេជ្ញាចិត្តធ្វើឱ្យមានការ ប្រែប្រួលដ៏សំខាន់ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ របស់អង្គការសហប្រជាជាតិ ("មិនទុកនរណាម្នាក់ចោល")។ ក្របខណ្ឌនៃការផាត់ចេញពីសង្គមកំពុង "ផ្តល់វិធីសាស្ត្រចម្រុះមួយសម្រាប់ការក្រឡេកមើលទម្រង់ផ្សេងៗនៃការចាញ់ប្រៀប ជាបញ្ហាដែលហាក់ត្រូវបានដោះស្រាយផ្សេងៗគ្នាក្នុងការសិក្សាអំពីអភិវឌ្ឍន៍... និងច្បាមយកបទពិសោធន៍របស់ក្រុម និងប្រភេទនានាដែលត្រូវបាន "ដាក់ឱ្យដាច់ដោយឡែក" "បង្ខាំង" ឬ "ទុកចោល" (ប្រភព ៖ UN DESA)។

## ក្របខណ្ឌនៃការផាត់ចេញពីសង្គម សង្ខេបពីទិដ្ឋភាពចម្រុះនៃការផាត់ចេញពីសង្គម ៖

- អ័ក្សឈរនៃវិសមភាពសេដ្ឋកិច្ចពិចារណាពីកម្រិតនៃភាពខ្វះខាតអ្វីដែលអ្នកមាន (ធនធាន ប្រាក់ចំណូល និងទ្រព្យសម្បត្តិ)។
- អ័ក្សដេកនៃការរើសអើងពិចារណាពីអត្តសញ្ញាណរបស់អ្នក ដោយផ្អែកលើយេនឌ័រ ជាតិពន្ធុ ឬលក្ខណៈពិសេសរបស់ក្រុមផ្សេងទៀត។
- ការចាត់ប្រៀបដោយសារកត្តាភូមិសាស្ត្រពិចារណាពីទីតាំងរបស់អ្នក ឬការចាត់ប្រៀបដែលអាចបណ្ដាលមកពីការបង្ខាំងទុកក្នុងទីកន្លែងដាក់លាក់ ដែលត្រូវបានកាត់ផ្ដាច់ចេញពីទំនាក់ទំនងក្នុងសង្គម សេដ្ឋកិច្ច ឬការប្រាស្រ័យទាក់ទងផ្សេងទៀត (តំបន់ដាច់ស្រយាល សំណង់អនាធិបតេយ្យក្នុងទីក្រុង។ល។)។

រូប ១ ៖ ក្របខណ្ឌនៃការផាត់ចេញពីសង្គម (បរិយាយពី UNESCO, 2016, pp. 51-58)



កត្តាផ្សេងៗដែលកំណត់ពីការផាត់ចេញពីសង្គមមានទំនាក់ទំនងគ្នាទៅវិញទៅមក និងត្រួតគ្នា ដែលបង្កើតបានជាទម្រង់ពហុសមាសភាគនៃការផាត់ចេញ (Kabeer, 2005; Stewart F., in UNESCO, 2016)។ ភាពក្រីក្រកំណត់ពីការផាត់ចេញនៅគ្រប់កម្រិត ប៉ុន្តែក្រុមដែលប្រឈមនឹងការរើសអើងដោយសារកត្តាផ្សេងទៀត នឹងប្រឈមនឹងការបាត់បង់ឱកាសយ៉ាងខ្លាំង។ ក្រុមជនជាតិដើមភាគតិច ហាក់ត្រូវបានផាត់ចេញពីជីវភាពនយោបាយ និងសង្គម ដែលកំណត់ពីការផាត់ចេញពីសេដ្ឋកិច្ច ហើយពួកគេប្រឈមនឹងការផាត់ចេញកាន់តែខ្លាំងដោយសារទីតាំងរបស់ពួកគេក្នុងតំបន់ដាច់ស្រយាល។ ការមានវ័យចំណាស់ វ័យក្មេង និងវ័យកុមារភាព បានក្លាយជាកត្តាកំណត់ការបាត់បង់ឱកាសក្នុងចំណោមក្រុមដែលប្រឈមនឹងទម្រង់ផ្សេងទៀតនៃការរើសអើង។ យេនឌ័រដើរតួនាទីជាកត្តាអន្តរវិស័យដែលកើតមានចំពោះគ្រប់ក្រុមទាំងអស់ រួមទាំងក្រុមដែលមានធនធានច្រើន។ ទោះជាយ៉ាងណា កត្តារើសអើងចម្រុះ និងត្រួតគ្នា កំណត់ពីកម្រិត និងផលប៉ះពាល់នៃវិសមភាពយេនឌ័រ។

ផ្អែកលើក្របខណ្ឌទស្សនទាននេះ គេអាចប្រមើលមើលពីអន្តរកម្មរវាងក្រុមទាំងឡាយដែលកំពុងប្រឈម នឹងហានិភ័យនៃការផាត់ចេញ ដោយពិចារណាពីកត្តាហានិភ័យដែលបង្កើតជាការរើសអើង និងភាពខ្វះខាតច្រើនស្រទាប់។ តារាងខាងក្រោមបង្ហាញពីហានិភ័យជាច្រើនដែលបុគ្គលម្នាក់អាចប្រឈម ដើម្បីឱ្យអ្នកអាចមើលឃើញរបៀបដែលមនុស្សអាចប្រឈមនឹងកត្តាជាច្រើនក្នុងពេលតែមួយ។

*ក្របខណ្ឌ "មិនទុកនរណាម្នាក់ចោល" របស់អង្គការសហប្រជាជាតិដែលផ្តល់មូលដ្ឋានព័ត៌មានដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ មានប្រភពពីសមភាពយេនឌ័រ និងសង្គមបរិយាបន្ន ហើយធនធានពាក់ព័ន្ធជាច្រើនត្រូវបានបង្កើតឡើងដើម្បីគាំទ្រ និងជាត្រីវិស័យសម្រាប់ការអនុវត្តសកម្មភាព (UNDP, 2016)។*

# ១.សញ្ញាណទូទៅស្តីពីសមភាពយេនឌ័រនិងសង្គមបរិយាបន្ន

| ការផាត់ចេញពីសង្គម និងសេដ្ឋកិច្ច | ស្ត្រី | ជនក្រីក្រ | ជនជាតិដើមភាគតិច | ជនជាតិភាគតិច | សាសនាភាគតិច | ក្រុមអត្តសញ្ញាណភេទភាគតិច | ជនមានពិការភាព | អ្នកផ្ទុកមេរោគអេដស៍ | កម្មករក្រៅប្រព័ន្ធជនចំណាកស្រុក | អ្នករស់នៅទីដាច់ស្រយាល | អ្នកប្រកបរបរផ្លូវភេទ | អ្នកប្រើប្រាស់គ្រឿងញៀន | មនុស្សចាស់ | យុវជន | កុមារ | អ្នកផ្សេងទៀត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ស្ត្រី | | | | | | | | | | | | | | | | |
| ជនក្រីក្រ | | | | | | | | | | | | | | | | |
| ជនជាតិដើមភាគតិច | | | | | | | | | | | | | | | | |
| ជនជាតិភាគតិច | | | | | | | | | | | | | | | | |
| សាសនាភាគតិច | | | | | | | | | | | | | | | | |
| ក្រុម អត្តសញ្ញាណភេទ ភាគតិច | | | | | | | | | | | | | | | | |
| ជនមានពិការភាព | | | | | | | | | | | | | | | | |
| អ្នកផ្ទុកមេរោគអេដស៍ | | | | | | | | | | | | | | | | |
| កម្មករក្រៅប្រព័ន្ធ ជនចំណាកស្រុក | | | | | | | | | | | | | | | | |
| អ្នករស់នៅទីដាច់ ស្រយាល | | | | | | | | | | | | | | | | |
| អ្នកប្រកបរបរផ្លូវភេទ | | | | | | | | | | | | | | | | |
| អ្នកប្រើប្រាស់គ្រឿង ញៀន | | | | | | | | | | | | | | | | |
| មនុស្សចាស់ | | | | | | | | | | | | | | | | |
| យុវជន | | | | | | | | | | | | | | | | |
| កុមារ | | | | | | | | | | | | | | | | |
| អ្នកផ្សេងទៀត | | | | | | | | | | | | | | | | |

# ១.២. យន្តការនៃការផាត់ចេញ

សង្គមនីមួយៗមាន**គុណតម្លៃ ជំនឿ បទដ្ឋាន ឥរិយាបថ និងអាកប្បកិរិយា** ដែលកំណត់អ្នកដែលត្រូវបានគេឱ្យតម្លៃ និងជាលទ្ធផល អ្នកដែលរងការមាក់ងាយ អ្នកដែលមិនទទួលបានការយកចិត្តទុកដាក់ និងអ្នកដែលទទួលរងការរើសអើង ដោយផ្អែកលើលក្ខណៈផ្សេងៗ ដូចជា ភេទ ទ្រព្យសម្បត្តិ ជាតិពន្ធុ សាសនា អត្តសញ្ញាណភេទ ស្ថានភាពសុខភាព អាយុ ពណ៌សំបុរ។ល។ ទម្រង់នៃការរើសអើងទាំងនេះត្រូវបានគេមើលឃើញថាស្របច្បាប់ និងសមហេតុផលដោយមនុស្សភាគច្រើនក្នុងសង្គម និងជាទូទៅផ្អែកលើការយល់ព្រម ការគ្មានការបង្ខិតបង្ខំ (Kabeer, 2005)។ បទដ្ឋាន បុរេនិច្ឆ័យ ផ្នត់គំនិត និងភាពលម្អៀងដែលជះឥទ្ធិពលលើការរើសអើង គឺជាឥរិយាបថ និងអាកប្បកិរិយាបង្កប់ដែលផ្អែកលើតម្លៃ និងវប្បធម៌សង្គមរួមដែលអនុវត្តដោយមនុស្សភាគច្រើន និងជាញឹកញាប់ ធ្វើឡើងដោយមិនដឹងខ្លួន។

***បទដ្ឋានយេនឌ័រជាគំនិតដែលកំណត់ថាតើស្ត្រី និងបុរសគួរធ្វើជាមនុស្សបែបណា និងគួរប្រព្រឹត្ត ដែលតំណាងឱ្យស្តង់ដារ និងក្តីរំពឹងទុកដែលជាទូទៅស្ត្រី និងបុរសអនុវត្តតាមក្នុងសង្គម វប្បធម៌ និងសហគមន៍មួយ (សូមមើល European Institute for Gender Equality Thesaurus)។***

ផ្នត់គំនិតយេនឌ័រជាគំនិតសន្មតជាមុនថា មនុស្សស្រី និងមនុស្សប្រុសត្រូវបានកំណត់បុគ្គលិកលក្ខណៈតាមទំនើងចិត្ត ហើយតួនាទីត្រូវបានកំណត់ និងរឹតត្បិតទៅតាមភេទរបស់ពួកគេ។ ផ្នត់គំនិតជាបុព្វហេតុដែលបង្កជាឫសគល់នៃឥរិយាបថ គុណតម្លៃ បទដ្ឋាន និងបុរេនិច្ឆ័យប្រឆាំងនឹងស្ត្រីដែលចាក់ឫសកប់យ៉ាងជ្រៅ។ គេប្រើប្រាស់ផ្នត់គំនិតដើម្បីសំអាងហេតុផល និងរក្សាទំនាក់ទំនងអំណាចតាំងពីមុនមករបស់បុរសដែលមានប្រៀបលើស្ត្រី និងឥរិយាបថផ្លូវភេទដែលធ្វើឱ្យស្ត្រីគ្មានភាពជឿនលឿន (OHCHR, 2014)។

បទដ្ឋាន ផ្នត់គំនិត និងបុរេនិច្ឆ័យ មិនត្រឹមតែជះឥទ្ធិពលលើទំនាក់ទំនងយេនឌ័រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឥរិយាបថ និងអាកប្បកិរិយាចំពោះក្រុមសង្គមជាតិពន្ធុ ជនមានពិការភាពទៀតផង។ ឧ. ក្នុងផ្នែកជាច្រើននៅទូទាំងពិភពលោក មានគំនិតអវិជ្ជមានដែលយល់ថា ជនក្រីក្រជាមនុស្សខ្ជិលជនជាតិដើមភាគតិចដើរថយក្រោយ ក្រុម LGBTI មិនសូវមានសីលធម៌ យុវជនធ្វេសប្រហែស និងគ្មានការទទួលខុសត្រូវ មនុស្សចាស់គ្មានប្រយោជន៍ ជនពិការមិនអាចធ្វើការបាន អ្នកជនបទអវិជ្ជា មនុស្សសំបុរខ្មៅអាក្រក់។ល។ គំនិត និងផ្នត់គំនិតទាំងនេះគឺខុសឆ្គង និងបង្កផលអន្តរាយ។

***បទដ្ឋាន ផ្នត់គំនិត បុរេនិច្ឆ័យ និងភាពលម្អៀងទាំងនេះ ជាកម្មវត្ថុនៃការសិក្សាផ្នែកចិត្តសាស្ត្រសង្គមដ៏សំខាន់ (Jackson, 2011)។ បទដ្ឋាន ផ្នត់គំនិត និងបុរេនិច្ឆ័យ ពាក់ព័ន្ធយ៉ាងខ្លាំងនឹងទិដ្ឋភាពសង្គម សេដ្ឋកិច្ច និង វប្បធម៌របស់សង្គមមួយ និងហាក់វិវឌ្ឍ និងប្រែប្រួល តាមពេលវេលា។***

យុទ្ធសាស្ត្រស្រាវជ្រាវសមភាពយេនឌ័រ និងសង្គមបរិយាបន្ន ផ្តោតសំខាន់លើការទទួលស្គាល់ ការគ្រប់គ្រង និងការប្រឆាំងនឹងបទដ្ឋាន ផ្នត់គំនិត និងបុរេនិច្ឆ័យដែលលើកកម្ពស់វិសមភាពយេនឌ័រ និងការផាត់ចេញពីសង្គម។ យុទ្ធសាស្ត្រទាំងនេះក៏ផ្តោតផងដែរលើការផ្លាស់ប្តូរបទដ្ឋាន និងគំនិតអវិជ្ជមានទាំងនេះដើម្បីបង្កើតឱកាសកាន់តែច្រើនសម្រាប់ការសម្រេចបានសមភាពយេនឌ័រ និងសមភាពសម្រាប់ក្រុមផ្សេងទៀតដែលបាត់បង់ឱកាស។

# ១.៣. ឯកសារសម្រាប់ការពិភាក្សា និងលំហាត់ជាក្រុម

ឧបករណ៍ និងឯកសារទាំងនេះត្រូវបានប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាលអនឡាញ ដើម្បីជំរុញឱ្យមានការឆ្លុះបញ្ចាំង បង្កើនកិច្ចពិភាក្សា និងអនុវត្តទស្សនទាន និងវិធីសាស្ត្រសមភាពយេនឌ័រ និង សង្គមបរិយាបន្ន។ ក្នុងវគ្គបណ្តុះបណ្តាលនេះ អ្នកចូលរួមត្រូវបានលើកទឹកចិត្តឱ្យចែករំលែកបទពិសោធន៍របស់ខ្លួនលើទស្សនៈវិស័យស្តីពីសមភាពយេនឌ័រ និងបរិយាបន្នសង្គមក្នុងកិច្ចពិភាក្សាពេញអង្គ។

មានការចាក់បញ្ចាំងវីដេអូខាងក្រោមស្តីពីភាពលម្អៀង បុរេនិច្ឆ័យ និងផ្នត់គំនិតដែលស្តែងឡើងដោយឯកឯង ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់កិច្ចពិភាក្សាពេញអង្គ និងកិច្ចពិភាក្សាជាក្រុម និងជួយបង្កើនស្វ័យយល់ដឹងអំពីឥរិយាបថ អាកប្បកិរិយា និងការផ្លាស់ប្តូរ ៖

- ភាពលម្អៀងដោយសារភាពក្រីក្រ និងការផាត់ចេញ (Poverty and exclusion bias) ៖ ឃ្លីបវីដេអូដែលបង្ហាញពីបុរេនិច្ឆ័យពាក់ព័ន្ធនឹងភាពក្រីក្រ និងស្ថានភាព។
- ភាពលម្អៀងដែលស្តែងឡើងដោយឯកឯង (Unconscious biases) ៖ កម្រងរឿងរ៉ាវវីដេអូក្នុងការិយាល័យមួយដែលបង្ហាញពីភាពលម្អៀងដែលស្តែងចេញដោយឯកឯងចំពោះស្ត្រី ពិការភាព និងអាកប្បកិរិយាដែលជះឥទ្ធិពលលើយុវជន
- វិនិច្ឆ័យលឿនពេក (Too quick to judge) ៖ រឿងរ៉ាវវីដេអូស្តីពីការវិនិច្ឆ័យជាមុន និងពិការភាព។



# ២ ភាពពាក់ព័ន្ធនៃសមភាពយេនឌ័រ និងសង្គមបរិយាបន្នសម្រាប់កម្ពុជា

## ២.១. សមភាពយេនឌ័រ៖ វឌ្ឍនភាព និងចំណុចសម្រាប់ការកែលម្អ

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍នេះ សមភាពយេនឌ័រនៅកម្ពុជាសម្រេចបានវឌ្ឍនភាពយ៉ាងច្រើន (ក្រសួងកិច្ចការនារី 2014b)។ សមភាពយេនឌ័រត្រូវ បានចែងក្នុងក្របខណ្ឌច្បាប់ និងរដ្ឋធម្មនុញ្ញកម្ពុជា។ ក្របខណ្ឌច្បាប់ និងគោលនយោបាយផ្សេងទៀតឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការសម្រេចបានសមភាពយេនឌ័រ ដូចជា ការផ្តល់សច្ចាប័នដល់លិខិតុបករណ៍អន្តរជាតិ ដូចជា អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)។ ក្រសួងកិច្ចការនារីជាស្ថាប័នជាតិរបស់កម្ពុជាដែលទទួលបន្ទុកកិច្ចការសមភាពយេនឌ័រ និងមានតួនាទីរៀបចំយុទ្ធសាស្ត្រជាតិសម្រាប់ការពន្លឿនសមភាពយេនឌ័រ និងផ្តល់មូលដ្ឋានព័ត៌មានដល់គោលនយោបាយជាតិផ្សេងទៀត។ ក្រៅពីនេះ សមភាពយេនឌ័រត្រូវបានដាក់បញ្ចូលក្នុងដំណើរការវិមជ្ឈការ ដែលមានរចនាសម្ព័ន្ធ និងសកម្មភាពសម្រាប់ត្រួតពិនិត្យ និងធានាការអនុវត្តសមភាពយេនឌ័រនៅកម្រិតវិមជ្ឈការទាំងអស់របស់រដ្ឋាភិបាល។



កម្ពុជាបង្ហាញពីការចូលរួមយ៉ាងច្រើនរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ច និងសម្រេចបានសមិទ្ធិផលសំខាន់ៗពាក់ព័ន្ធនឹងលទ្ធភាពស្មើភាពក្នុងការទទួលបានការអប់រំ ហើយកម្ពុជាសម្រេចបានគោលដៅអភិវឌ្ឍន៍សហវត្សរ៍របស់ខ្លួនសម្រាប់ការអប់រំរបស់ក្មេងស្រី និងលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសេវាសុខភាព (ដូចខាងលើ)។ មានកត្តាផ្សេងៗទៀតដែលរួមចំណែកដល់សមភាពយេនឌ័រ ដែលក្នុងនោះរួមមាន ការមិនមានបទដ្ឋាន ឬគុណតម្លៃទូទៅដែលជម្រុញការពេញចិត្តកុមារតាមភេទ (ចង់មានកូនប្រុស ជាងកូនស្រី) ឬការអនុវត្តបែបរើសអើងក្នុងការផ្ទេរកេរមត៌ក និងទ្រព្យសម្បត្តិ។ ជាការពិតណាស់ ច្បាប់បានធានាការចុះបញ្ជីដីធ្លីដោយដាក់ឈ្មោះទាំងប្តី និងប្រពន្ធ។

ទោះបីជាសម្រេចបានសមិទ្ធិផលទាំងនេះក្តី ក៏នៅតែមានផ្នែកដែលមិនសូវមានវឌ្ឍនភាពផងដែរ។ ការផាត់ចេញស្ត្រីពីជីវភាពសាធារណៈ និងតួនាទីធ្វើសេចក្តីសម្រេចចិត្តនៅតែលេចឡើង ជាពិសេសសម្រាប់មុខតំណែងធំៗក្នុងជួររដ្ឋាភិបាល ឬក្នុងវិស័យមួយចំនួន ដូចជា តុលាការ។ កម្មករក្រៅប្រព័ន្ធភាគច្រើនជាស្ត្រី ដែលប្រមូលផ្តុំក្នុងការងារដែលមិនជាប់លាប់ គ្មានជម្រើស ឬគ្រោះថ្នាក់។ តួនាទីទ្វេរបស់ស្ត្រីក្នុងនាមជាតួអង្គសេដ្ឋកិច្ច និងអ្នកថែទាំបឋមដែលបង្កប់ក្នុងបទដ្ឋានសង្គម ក៏បានរឹតត្បិតការអភិវឌ្ឍរបស់ស្ត្រីផងដែរ។ ក្រៅពីនេះ ផ្នត់គំនិតយេនឌ័រនៅតែមើលស្រាលចំណេះដឹង សមត្ថភាព និងជំនាញរបស់ស្ត្រី។ អំពើហិង្សាផ្អែកលើយេនឌ័រ (GBV) និងអំពើហិង្សាលើស្ត្រី (VAW) នៅតែជាបញ្ហាកង្វល់ក្នុងសង្គម (ក្រសួងកិច្ចការនារី 2014b)។

**ក្នុងចំណោមស្ត្រីនៅកម្ពុជា មានក្រុមស្ត្រីដែលងាយរងគ្រោះខ្លាំង ឬប្រឈមនឹងហានិភ័យនៃការផាត់ចេញ (ក្រសួងកិច្ចការនារី 2014a)។**

## ក្រុមស្ត្រីដែលបាត់បង់ឱកាស



ស្ត្រីក្រីក្រ ស្ត្រីរស់នៅជនបទ និងទីក្រុង ស្ត្រីគ្មានដីធ្លី ពលករជាស្ត្រី ស្ត្រីសុំទាន ស្ត្រីរើសអេតចាយ



ស្ត្រីប្រឡូកក្នុងការងារដែលផ្តល់ប្រាក់ឈ្នួលទាប និងគ្មានជម្រើស ដូចជា កម្មកររោងចក្រកាត់ដេរ



ស្ត្រីក្នុងការងារក្រៅប្រព័ន្ធឬការងារគ្រោះថ្នាក់ ដូចជា ស្ត្រីធ្វើការតាមផ្ទះ ស្ត្រីធ្វើការក្នុងវិស័យកំសាន្ត ស្ត្រីប្រកបរបរផ្លូវភេទ



ស្ត្រីចំណាកស្រុក



ស្ត្រីស្រឡាញ់ស្រីដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរយេនឌ័រ



ស្ត្រីដែលរងការរំលោភបំពាន និងជាជនរងគ្រោះនៃអំពើហិង្សាលើស្ត្រី

# ២.២. ភាពក្រីក្រ

កម្ពុជាសម្រេចបានវឌ្ឍនភាពយ៉ាងច្រើនក្នុងការកាត់បន្ថយអត្រាភាពក្រីក្រថ្នាក់ជាតិ (ត្រូវបានកំណត់ជាប្រាក់ចំណូលតិចជាង ១,៩ ដុល្លារក្នុងមួយថ្ងៃ) ពីចំនួន ៥៣% (២០០៤) មកត្រឹម ២០,៥% (២០១១) និងថយចុះមកត្រឹម ១៣,៥% (២០១៤) ហើយអត្រានេះនៅតែបន្តថយចុះបន្ថែមទៀត (ធនាគារពិភពលោក ២០១៩)។ ទោះជាយ៉ាងណា ធនាគារពិភពលោកកត់សម្គាល់ថា ការកាត់បន្ថយភាពក្រីក្រក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយមានភាពយឺតយ៉ាវ ហើយក្រុមមួយចំនួន (ជនក្រីក្រនៅទីក្រុង) ទទួលបានអត្ថប្រយោជន៍តិចពីកំណើនសេដ្ឋកិច្ច។ ការវិភាគថ្មីមួយពីភាពក្រីក្រពហុសមាសភាគនៅកម្ពុជាបានផ្តល់ការស្វែងយល់កាន់តែច្បាស់ពីអ្នកដែលក្រីក្រ និងកត្តាសំខាន់ៗដែលជំរុញភាពក្រីក្រ (Anderson 2019)។ ពាក់ព័ន្ធនឹងសមភាពយេនឌ័រ និងបរិយាបន្នសង្គម សំខាន់បំផុតត្រូវពិចារណាពីអន្តរកម្មរវាងភាពក្រីក្រី/ភាពខ្វះខាតធនធាន និងកត្តាលើ "អ័ក្សដេក" ផ្សេងទៀតដែលបង្កជាការរើសអើង ដូចជា យេនឌ័រ ជាតិពន្ធុ អាយុ សុខភាព អត្តសញ្ញាណភេទ ពិការភាព។ល។



ស្ត្រីចំណាស់ ស្ត្រីមេម៉ាយ ស្ត្រីមេគ្រួសារ



ស្ត្រីផ្ទុកមេរោគអេដស៍/ជំងឺអេដស៍



ស្ត្រីដែលសេពគ្រឿងញៀន ឬមានដៃគូសេពគ្រឿងញៀន ឬគ្រឿងស្រវឹង។



ស្ត្រីជនជាតិដើមភាគតិច



ស្ត្រីជនជាតិភាគតិច



ស្ត្រីជាប់ពន្ធនាគារ



ស្ត្រីដែលមានពិការភាព

## ការកាត់បន្ថយភាពក្រីក្រក្នុងមួយរំឡងពេល

**៥៣%**
ឆ្នាំ ២០០៤

**២០.៥%**
ឆ្នាំ ២០១១

**១៣.៥%**
ឆ្នាំ ២០១៤

## ការកាត់បន្ថយភាពក្រីក្រក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយមានភាពយឺតយ៉ាវ

អន្តរកម្មនៃសមភាពយេនឌ័រ និងបរិយាបន្នសង្គម



# ២.៣. ជាតិពន្ធុ

កម្ពុជាជាប្រទេសមួយដែលមានក្រុមជាតិពន្ធុចម្រុះ។ ក្នុងនោះ ជនជាតិខ្មែរមានចំនួនរហូតដល់ ៩០% នៃចំនួនប្រជាជនសរុបប្រហែល ១៦,៥ លាននាក់។ ក្រុមជាតិពន្ធុផ្សេងទៀតរួមមាន ជនជាតិភាគតិចចាម វៀតណាម ឡាវ និងចិន។ កម្ពុជាមានជនជាតិដើមភាគតិចចំនួន ២៤ ក្រុមផ្សេងគ្នា ដែលនិយាយភាសា និងអនុវត្តវប្បធម៌ របរចិញ្ចឹមជីវិត និងបែបផែនសង្គមរៀងៗខ្លួន។ ជនជាតិដើមភាគតិចទាំងនេះកំពុងរស់នៅក្នុងខេត្ត ១៥ ប៉ុន្តែមានចំនួនច្រើនបំផុតនៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង កំពង់ធំ និងព្រះវិហារ (AIPP & Bourdier 2015)។ ក្រុមជនជាតិដើមភាគតិចមានសមាសភាគប្រមាណ ១,៣៤% នៃចំនួនប្រជាជនសរុប ប៉ុន្តែគ្មានទិន្នន័យស្ថិតិដែលអាចទុកចិត្តបានស្ដីពីក្រុមជនជាតិដើមភាគតិចនៅកម្ពុជាឡើយ (CIPA-CIYA-AIPP 2019)។ ស្ថានភាពរបស់ជនជាតិដើមភាគតិចនៅកម្ពុជាកំពុងបង្កការព្រួយបារម្ភ ដោយសារតែការថយចុះជាលំដាប់នូវធនធានធម្មជាតិ ដែលជាប្រភពរបរចិញ្ចឹមជីវិតរបស់ពួកគេ បូករួមនឹងកង្វះ ឬការមិនអភិវឌ្ឍពេញលេញនូវវិស័យអប់រំ សុខាភិបាល ទំនាក់ទំនង និងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងកង្វះឱកាសការងារ (IWGIA 2020)។

**៩០%**
ជនជាតិខ្មែរ



**១.៣៤%**
ជនជាតិភាគតិចចាម
វៀតណាម ឡាវ និងចិន



**២៤** 
ក្រុម ជនជាតិដើមភាគតិច
ផ្សេងៗគ្នា

**១៥**
ខេត្ត

# ២.៤. អាយុ

ការថយចុះអត្រាបង្កកំណើតជារួម និងការកើនឡើងនៃអាយុសង្ឃឹមរស់របស់ប្រជាជន បាន និងកំពុងបង្កើនសមាមាត្រនៃចំនួនប្រជាជនវ័យចំណាស់នៅកម្ពុជា។ ប្រជាជនវ័យចំណាស់ទាំងនេះបានបង្កើនឧប្បត្តិហេតុនៃការកើតជំងឺ ពិការភាព តម្រូវការការថែទាំរយៈពេលវែង ចំណាយកាន់តែច្រើនលើការថែទាំសុខភាព និងអសន្តិសុខហិរញ្ញវត្ថុ (រាជរដ្ឋាភិបាលកម្ពុជា ២០១៧)។ កត្តានានា ដូចជាជាតិពន្ធុ សាសនា ស្ថានភាពសុខភាព កម្រិតអប់រំ និងស្ថានភាពសេដ្ឋកិច្ច ក៏អាចបង្កើនភាពងាយរងគ្រោះរបស់មនុស្សចាស់ផងដែរ។ នៅកម្ពុជា ស្ត្រីចំណាស់មានចំនួនច្រើនជាង និងងាយរងគ្រោះជាងបុរសចំណាស់ ដោយសារតែការរើសអើងយេនឌ័រ និងហានិភ័យកាន់តែខ្លាំងនៃការធ្លាក់ខ្លួនក្រ ក្លាយជាស្ត្រីមេម៉ាយ និងមិនទទួលបានការយកចិត្តទុកដាក់ (ដូចខាងលើ)។

យុវជនដែលមានអាយុ ១៥-២៩ ឆ្នាំ មានចំនួនជិតពាក់កណ្តាលនៃចំនួនប្រជាជនគ្រប់អាយុធ្វើការនៅកម្ពុជា ប៉ុន្តែយុវជនយ៉ាងច្រើននៅតែមិនសូវមានជំនាញ ដោយសារការបោះបង់ការសិក្សា (OECD Development Centre 2017)។ ចំណុចនេះបានបង្ខំឱ្យយុវជនកម្ពុជាប្រឡូកក្នុងការងារដែលមិនសូវមានជំនាញ ផ្តល់ប្រាក់ឈ្នួលទាប និងមិនជាប់លាប់។ កត្តានេះធ្វើឱ្យកម្ពុជាបាត់បង់ធនធានមនុស្សដែលមានសក្តានុពល។ ស្ត្រីវ័យក្មេងកាន់តែប្រឈមនឹងហានិភ័យនៃការជាប់ផុងក្នុងការងារក្រៅប្រព័ន្ធ មិនជាប់លាប់ និងផ្តល់ប្រាក់ឈ្នួលទាប។ នៅជនបទ មិនសូវមានឱកាសការងារទេ ហើយនេះជាកត្តាមួយដែលធ្វើឱ្យមានការធ្វើចំណាកស្រុកក្នុង និងក្រៅប្រទេស។ នៅតំបន់ជនជាតិដើមភាគតិច ស្ថានភាពនេះកាន់តែលេចឡើងច្បាស់ ព្រោះទីនោះមានឱកាសការងារតិច និងលទ្ធផលអប់រំទាបជាងកម្រិតមធ្យម។ ពិការភាព និងអាកប្បកិរិយាដែលមានហានិភ័យ ដូចជាការសេពគ្រឿងញៀន និងគ្រឿងស្រវឹង ក៏បង្កផលប៉ះពាល់ដល់យុវជនផងដែរ។

**↓ ការថយចុះអត្រាបង្កកំណើត**

**↑ ការកើនឡើងប្រជាជនវ័យចំណាស់**

បញ្ហាប្រឈមដែលមនុស្សចាស់ជួបប្រទះ៖

- ការកើតជំងឺ
- ពិការភាព
- តម្រូវការថែទាំរយៈពេលវែង
- ចំណាយលើការថែទាំសុខភាព
- អសន្តិសុខហិរញ្ញវត្ថុ

យុវជនដែលមានអាយុ ១៥-២៩ ឆ្នាំ មានចំនួនជិត

**50%**

នៃចំនួនប្រជាជនគ្រប់អាយុធ្វើការនៅកម្ពុជា

បញ្ហាប្រឈមរបស់យុវជនកម្ពុជា

- មិនសូវមានជំនាញ
- ប្រាក់ឈ្នួលទាប
- ការងារមិនជាប់លាប់

# ២.៥. ពិការភាព

អង្គការសុខភាពពិភពលោក (WHO) និងរបាយការណ៍ស្តីពីពិការភាពក្នុងពិភពលោករបស់ធនាគារពិភពលោក (២០១១) បានប៉ាន់ស្មានថា ប្រជាជនទូទាំងពិភពលោកចំនួន ១៥% មានពិការភាព។ ក្នុងនេះ ប្រជាជន ២% មានការលំបាកយ៉ាងខ្លាំងក្នុងការបំពេញមុខងារ។ នៅកម្ពុជា ចំនួនផ្លូវការនៃជនមានពិការភាព ត្រូវបានប៉ាន់ស្មានថាមានតិចជាង ២% (សូមចុច here)។ ទោះជាយ៉ាងណា ការអង្កេតប្រជាសាស្ត្រ និងសុខភាព (DHS) ដែលបានធ្វើឡើងនៅឆ្នាំ២០១៤ប៉ាន់ស្មានថាប្រជាជនកម្ពុជាចំនួន១០% មានទម្រង់មួយចំនួននៃពិការភាព(NIS, 2014)។គោលនយោបាយជាតិស្តីពីពិការភាពត្រូវបានដាក់ឱ្យអនុវត្តតាមដំណាក់កាលដោយរាជរដ្ឋាភិបាលកម្ពុជាដោយផ្តោតសំខាន់លើទិដ្ឋភាពទាំងអស់នៃជីវិតរស់នៅ ដូចជា សុខភាព និងការអប់រំ ការងារ និងការចូលរួមក្នុងជីវភាព នយោបាយ ដើម្បីកាត់បន្ថយភាពក្រីក្រ លុបបំបាត់ការរើសអើង និងសម្រេចបានសិទ្ធិស្មើភាពសម្រាប់ជនពិការ (DAC, 2017)។ ទោះជាយ៉ាងណា អង្គការសង្គមស៊ីវិលដែលកំពុងធ្វើការពាក់ព័ន្ធនឹងសិទ្ធិរបស់ជនមានពិការភាពបានគូសបញ្ជាក់ពីចំនួនជនពិការយ៉ាងច្រើនដែលកំពុងរស់នៅក្នុងភាពក្រីក្រ និងប្រឈមនឹងការផាត់ចេញ និងឧបសគ្គក្នុងប្រទេសកម្ពុជា (សូមចុច here)។

## តើមនុស្សប៉ុន្មាននាក់ដែលមានពិការភាព?

**១៥%** នៃប្រជាជនទូទាំងពិភពលោក

អង្គការសុខភាពពិភពលោក (WHO) និង
ធនាគារពិភពលោក (World Bank) (២០១១)

**២%**

ចំនួនផ្លូវការរបស់កម្ពុជា

**១០%**

ការអង្កេតប្រជាសាស្ត្រនិងសុខភាព (DHS) ២០១៤

> *“ក្រៅពីទម្រង់ផ្សេងទៀតនៃការផាត់ចេញស្ត្រីដែលមានពិការភាពងាយនឹងរងគ្រោះដោយសារអំពើហិង្សាផ្អែកលើយេនឌ័រអំពើហិង្សាផ្លូវភេទ ឬទម្រង់ផ្សេងទៀតនៃការរំលោភបំពានរាងកាយ និងផ្លូវចិត្ត”*
>
> *(ក្រសួងកិច្ចការនារី 2014a)។*

# ២.៦. អត្តសញ្ញាណភេទ

នៅកម្ពុជា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ (១៩៨៩) ហាមឃាត់អាពាហ៍ពិពាហ៍មនុស្សដែលមានភេទដូចគ្នា។ ទោះជាយ៉ាងណា ហាក់មានការអត់អោនខ្លះៗចំពោះគូស្នេហ៍ដែលមានភេទដូចគ្នា។ ច្បាប់កម្ពុជាមិនបានចែងច្បាស់ពីការហាមឃាត់ការរើសអើងដោយផ្អែកលើនិន្នាការផ្លូវភេទ និងអត្តសញ្ញាណភេទឡើយ និងគ្មានការដាក់ទណ្ឌកម្មលើអ្នកដែលរំលោភសិទ្ធិមនុស្សរបស់ក្រុម LGBT នោះទេ។ ជាញឹកញាប់ ក្រុម LGBT ប្រឈមនឹង "ការមាក់ងាយ ការរើសអើង និងការផាត់ចេញយ៉ាងខ្លាំងក្នុងមជ្ឈដ្ឋានផ្សេងៗ ដូចជា ផ្ទះ សាលារៀន កន្លែងធ្វើការ មូលដ្ឋានសុខាភិបាល

និងទីសាធារណៈ” (សូមចុច here)។ ចំណុចនេះរួមចំណែកបង្កជាភាពងាយរងគ្រោះ និងភាពឯការរបស់ក្រុម LGBT ដែលអាចជះផលអាក្រក់លើសុខុមាលភាព និងជីវិតរស់នៅរបស់ពួកគេ។ កង្វះការទទួលស្គាល់ និងការការពារសិទ្ធិរបស់ក្រុមភេទភាគតិចបានធ្វើឱ្យក្រុម LGBT មិនអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនឱ្យបានពេញលេញដើម្បីចូលរួមក្នុងការអភិវឌ្ឍនយោបាយ សង្គម សេដ្ឋកិច្ច វប្បធម៌ និងការអភិវឌ្ឍបែបបរិយាប័ន្ននៅព្រះរាជាណាចក្រកម្ពុជា (ក្រសួងកិច្ចការនារី 2014a)។

# ២.៧. ភាពងាយរងគ្រោះផ្សេងទៀត

ការផាត់ចេញពីសង្គមអាចបណ្តាលមកពីបាតុភូតក្នុងសង្គម សេដ្ឋកិច្ច និងវប្បធម៌ ដូចជា ការធ្វើចំណាកស្រុកទាំងក្នុង និងក្រៅប្រទេស និកម្មភាព ឬបញ្ហាដែលកំពុងលេចឡើងផ្សេងទៀត ដូចជាការសេពគ្រឿងញៀន។ កង្វះទិន្នន័យ ឬឯកសារយោង បង្ហាញថាទាំងនេះជាផ្នែកដែលអាចលេចឡើងក្នុងការស្រាវជ្រាវ។

# ២.៨. ការវិវឌ្ឍ និងការផ្លាស់ប្តូរ

ទស្សនៈវិស័យតាំងពីដើមមកស្តីពីយេនឌ័រនៅកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍ បានគូសបញ្ជាក់ពីតួនាទីរបស់ស្ត្រីក្នុងយុគមុនសម័យទំនើប និងសម័យទំនើប និងការវិវឌ្ឍនៃឋានានុក្រមយេនឌ័រ និងតួនាទីក្នុងដំណាក់កាលប្រវត្តិសាស្ត្រផ្សេងៗ (Andaya, 2006; Jacobsen, 2008)។ ពីមុន ស្ត្រីនៅអាស៊ីអាគ្នេយ៍ និងកម្ពុជាទទួលបានសមភាពស្មើគ្នា ជាសមភាពក្នុងកម្រិតយ៉ាងខ្ពស់ដែលត្រូវបានចាត់ទុកថាមានភាពលេចធ្លោក្នុងតំបន់ (Reid, 2015)។ ការស្រាវជ្រាវកន្លងមក បានផ្តល់ព័ត៌មានបរិបទសំខាន់ៗដើម្បីស្វែងយល់ពីក្រុមជាតិពន្ធុចម្រុះ និងក្រុមជនជាតិដើមភាគតិចនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ (Scott, 2009)។

# ២.៩. ឯកសារសម្រាប់ការពិភាក្សា និងលំហាត់ជាក្រុម

**វគ្គទី ២** ផ្ដោតលើសមភាពយេនឌ័រ និង សង្គមបរិយាបន្ននៅកម្ពុជា។ ខាងក្រោមនេះជាវីដេអូជាច្រើន (ភាសាខ្មែរ) ដែលពាក់ព័ន្ធនឹងយេនឌ័រ និងការផាត់ចេញពីសង្គម ដែលអាចយកទៅប្រើប្រាស់សម្រាប់កិច្ចពិភាក្សាជាក្រុម ឬកិច្ចពិភាក្សាពេញអង្គ។

## យេនឌ័រ



**សមភាពយេនឌ័រ** ឃ្លីបគំនូរជីវចល ដែលពន្យល់ពីវិសមភាពយេនឌ័រ



**ប្ដី និងប្រពន្ធ** រឿងវ៉ាវីដេអូស្ដីពីតួនាទីយេនឌ័រដែលបង្ហាញពីគូស្វាមីភរិយាមួយគូនៅកម្ពុជា



**អំពើហិង្សាលើស្ត្រី** រឿងវ៉ាវីដេស្ដីពីអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា (ទីក្រុង ជនបទ ស្ត្រីវ័យក្មេង និងស្ត្រីចំណាស់)



**ក្រាហ្វិកព័ត៌មានស្ដីពីយេនឌ័រនិងការអប់រំរបស់ក្មេងស្រី** ឃ្លីបគំនូរជីវចលដែលបង្ហាញពីបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងយេនឌ័រនិងការអប់រំ។

## ភាពក្រីក្រ និងការបាត់បង់ឱកាសសេដ្ឋកិច្ច




**ក្មេងស្រីក្រីក្រ** ឃ្លីបវីដេអូស្ដីពីក្មេងស្រីម្នាក់ដែលមានឪពុកម្ដាយធ្វើចំណាកស្រុក ហើយគាត់ត្រូវបង្ខំចិត្តធ្វើការដើម្បីជួយផ្គត់ផ្គង់ជីដូន និងប្អូនៗ



**ជីវិតរបស់ក្មេងស្រីផ្សព្វផ្សាយស្រាបៀរ** ដេអូឯកសារស្ដីពីបទពិសោធន៍របស់ក្មេងស្រីដែលធ្វើការក្នុងវិស័យកំសាន្ត។

## ជនជាតិដើមភាគតិច



ស្ត្រីជនជាតិភាគតិចនៅកម្ពុជា
វីដេអូឯកសារស្តីពីស្ត្រីជនជាតិដើមភាគតិចនៅខេត្តរតនគិរី ដែលបង្ហាញពីរឿងរ៉ាវពាក់ព័ន្ធនឹងការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រងដីធ្លី



ក្រុមជនជាតិដើមភាគតិចនៅកម្ពុជា
វីដេអូឯកសារស្តីពីជនជាតិដើមភាគតិចនៅកម្ពុជា។

## អត្តសញ្ញាណភេទ ការមាក់ងាយដោយសារមេរោគអេដស៍



ក្រុម LGBTI នៅកម្ពុជា
វីដេអូឯកសារស្តីពីបុរេនិច្ឆ័យចំពោះគូស្នេហ៍ស្រីស្រឡាញ់ស្រីដូចគ្នា



ស្នេហាក្នុងរោងចក្រ
វីដេអូឯកសារស្តីពីកម្មករ LGBTI នៅក្រុងភ្នំពេញដែលសម្រេចចិត្តធ្វើការក្នុងរោងចក្រដើម្បីគេចវេសពីបុរេនិច្ឆ័យ និងការបាត់បង់ឱកាសនៅជនបទ



ស្ត្រីមានផ្ទុកមេរោគអេដស៍
វីដេអូឯកសារស្តីពីស្ត្រីដែលប្រឈមនឹងការបាត់បង់ឱកាសក្រោយការធ្វើតេស្តបង្ហាញថាមានផ្ទុកមេរោគអេដស៍។

## ពិការភាព



ពិការភាព ស្ត្រី កីឡា
ឃ្លីបឯកសារវីដេអូស្តីពីស្ត្រីម្នាក់ដែលមានពិការភាព ការលំបាករបស់គាត់ និងការផាត់ចេញ និងរបៀបដែលគាត់ជម្នះបញ្ហាទាំងនោះដោយលេងកីឡា។

## សំណួរមួយចំនួនសម្រាប់ការពិភាក្សា

- តើបទដ្ឋាន និងបុរេនិច្ច័យនៅកម្ពុជា ហាក់សន្មតថា អ្នកមាន និងអ្នកមានអំណាច មានគុណធម៌ផ្នែកសីលធម៌ ហើយជនក្រីក្រ មិនសូវមានគុណធម៌ផ្នែកសីលធម៌ មែនឬទេ?
- តើជនក្រីក្របំផុតត្រូវបានស្អប់ ឬទទួលរងការមាក់ងាយពីអ្នកទីក្រុង អ្នកមាន និងអ្នកមានការអប់រំ មែនឬទេ? បង្កផលវិបាកអ្វីខ្លះ?
- តើក្រុមដែលមានអត្តសញ្ញាណជាតិពន្ធុទូទៅ បង្ហាញពីផ្នត់គំនិត និងភាពលម្អៀងចំពោះក្រុមជាតិពន្ធុដែលមិនមែនជាជនជាតិខ្មែរ ឬទេ?
- តើសង្គមកម្ពុជាបង្ហាញពីគំរូទូទៅក្នុងកម្រិតខ្ពស់ក្នុងទម្រង់បែបណា? តើនរណាខ្លះដែលសង្គមសន្មតជាបុគ្គល ឬក្រុមអវិជ្ជមានដែលមិនអនុវត្តតាមគំរូទូទៅនេះ?
- តើមានការសន្មតដូចម្តេចចំពោះការមានពិការភាពក្នុងសង្គមកម្ពុជា ធៀបនឹងជំនឿក្នុងវប្បធម៌ និងសាសនា?

## ករណីសិក្សាទី ១

*អានអត្ថបទនេះ រួចឆ្លុះបញ្ចាំងពីភាពដូចគ្នា (ឥរិយាបថចំពោះជនជាតិដើមភាគតិចនៅកម្ពុជា)*

ប្រទេស ក (ប្រទេសណាមួយនៅអាស៊ីអាគ្នេយ៍) មានធនធានព្រៃឈើយ៉ាងច្រើនដែលមិនទាន់បានប្រើប្រាស់ឱ្យអស់លទ្ធភាព ហើយមុខងារចម្បងនៃធនធានទាំងនោះគឺរួមចំណែកដល់ការអភិវឌ្ឍជាតិ។ ការកាប់ធនធានព្រៃឈើយ៉ាងសំបូរបែបនេះនឹងជួយជំរុញពាណិជ្ជកម្មអន្តរជាតិ ផ្តល់ការងារដល់ប្រជាជន និងផលិតផលឈើសម្រាប់ប្រទេសនោះ និងពិភពលោកទាំងមូល។ តំបន់ព្រៃឈើទាំងនេះហាក់គ្មានមនុស្សរស់នៅទេប៉ុន្តែតាមពិតមានមនុស្សមួយចំនួនតូចកំពុងរស់នៅ ហើយពួកគេគ្មានការយល់ដឹង និងរស់នៅតាមបែបប្រពៃណី។ ពួកគេបង្កភាពអាម៉ាស់ដល់ប្រទេសនោះ។ ចំណុចនេះត្រូវបានបង្ហាញតាមរយៈជំនឿលើព្រលឹង កម្មសិទ្ធិសមូហភាព និងការអនុវត្តកសិកម្មព្រៃដុតដែលបង្កការបំផ្លិចបំផ្លាញ។ ការធ្វើឱ្យមនុស្សទាំងនេះមានអរិយធម៌ដោយបង្វែរពួកគេឱ្យងាកទៅគោរពប្រតិបត្តិសាសនាគោល និងបញ្ចុះបញ្ចូលឱ្យពួកគេអនុវត្តកសិកម្មនៅមួយកន្លែងដែលមានលក្ខណៈអចិន្ត្រៃយ៍ ដូចកសិករសកម្មនៅតំបន់ទំនាប មានសារៈសំខាន់ណាស់សម្រាប់ការកែលម្អជីវិតរបស់មនុស្សទាំងនោះ និងបញ្ចូលពួកគេក្នុងរដ្ឋទំនើប។ ការផ្លាស់ប្តូរទាំងនេះនឹងរួមចំណែកដល់ការធ្វើទំនើបកម្មប្រទេសទាំងមូល

(កែសម្រួលពី Colfer et al. Making Sense of Intersectionality, CIFOR, 2018)។



# ៣ តួនាទីនៃការស្រាវជ្រាវ សមភាពយេនឌ័រ និង សង្គមបរិយាបន្ន

> *ប្រសិនបើយើងឈានជើងចេញពីផ្ទះ យើងនឹងដឹងច្រើន យើងនឹងហ៊ានបញ្ចេញមតិ យើងនឹងទទួលបានព័ត៌មានច្រើន យើងនឹងទទួលបានបទពិសោធន៍ចម្រុះ យើងនឹងទទួលបានការគោរពច្រើន...។*

កិច្ចពិភាក្សាក្រុមគោលដៅជាមួយស្ត្រីស្តីពីព្រៃសហគមន៍
( Agarwal, 2010, pp. 16 )



ការស្រាវជ្រាវសង្គមដើរតួនាទីយ៉ាងសំខាន់ក្នុងសមភាពយេនឌ័រ និង សង្គមបរិយាបន្ន។ ការស្រាវជ្រាវនេះអាចលាតត្រដាងពីការរើសអើង និងការផាត់ចេញតាមរយៈទិន្នន័យថ្មីៗ និងការវិភាគ និងផ្តល់អនុសាសន៍ ឬលើកឡើងពីវិធីសាស្ត្រសមស្រប។ ចំណុចសំខាន់គឺការស្រាវជ្រាវនេះអាចបង្កើនភាពអង់អាចរបស់ក្រុមដែល បាត់បង់ឱកាស ដោយផ្តល់ឱកាសដល់ពួកគេសម្រាប់ការចូលរួម ភាពលេចធ្លោរ និងទទួលបានទីភ្នាក់ងារ (លទ្ធភាពបង្កើតជម្រើសដែលមានប្រសិទ្ធភាព និងប្រែក្លាយជម្រើសទាំងនោះទៅជាលទ្ធផលដែលចង់បានតាមរយៈសកម្មភាព)។

**ទោះជាយ៉ាងណា បទដ្ឋាន ផ្នត់គំនិត បុរេវិនិច្ឆ័យ ឬការមាក់ងាយដែលរារាំងក្រុមបាត់បង់ឱកាសមិនឱ្យចូលរួមពេញលេញក្នុងសង្គម ក៏អាចរារាំងមិនឱ្យពួកគេចូលរួមក្នុងការស្រាវជ្រាវផងដែរ។**

> *ជាទូទៅ តំណាងរបស់ក្រុមដែលបាត់បង់ឱកាស មិនមែនជាអ្នកផ្តួចផ្តើមការស្រាវជ្រាវស្តីពីក្រុមរបស់ខ្លួនឡើយ ហើយជាទូទៅ អ្នកដែលបាត់បង់ឱកាសមិនមែនជាអ្នកដែលទទួលបានប្រយោជន៍ពីលទ្ធផលស្រាវជ្រាវនោះទេ។*
>
> (Moree, 2018, p. 3)

ក្រុម និងបុគ្គលដែលបាត់បង់ឱកាស មិនសូវត្រូវបានដាក់បញ្ចូលតាមបែបប្រតិសកម្មក្នុងការរៀបចំវិធីសាស្រ្ត និងការអនុវត្តការស្រាវជ្រាវដែលមិនផ្តោតជាពិសេសលើពួកគេឡើយ។ ពួកគេមិនត្រូវបានជ្រើសរើសជាអ្នកផ្តល់ព័ត៌មាន ឬគ្មានការពិចារណាពីឧបសគ្គដែលពួកគេប្រឈម ដូចជា ពេលទំនេរ ភាសា អក្ខរភាព ចល័តភាព ឬការមាក់ងាយក្នុងសង្គម។ ក្រៅពីនេះ វិធីសាស្រ្តស្រាវជ្រាវអាចមិនអនុញ្ញាតឱ្យពួកគេជម្នះភាពអៀនខ្មាស ភាពអាម៉ាស់ ឬតម្លៃផ្ទាល់ខ្លួនទាប ឬមិនផ្តល់ការការពារគ្រប់គ្រាន់ដល់ពួកគេ។

**ខាងក្រោមនេះជាកត្តានានាក្នុងចំណោមភាពលម្អៀង ដែលអាចរារាំងមិនឱ្យពួកគេចូលរួមយ៉ាងសកម្មក្នុងសកម្មភាពស្រាវជ្រាវ ៖**

| | |
|---|---|
| **កត្តាជាប្រព័ន្ធ** | ឥស្សរៈជនក្នុងសហគមន៍ អាជ្ញាធរ អ្នកតាក់តែងគោលនយោបាយ និងអ្នកផ្តល់ព័ត៌មាន អាចមានបុរេនិច្ឆ័យផ្នែកសង្គម វប្បធម៌ និងជាតិពន្ធុដែលពាក់ព័ន្ធនឹងយេនឌ័រចំពោះក្រុម និងបុគ្គលដែលបាត់បង់ ឱកាស (មិនមានបង្ហាញក្នុងស្ថិតិ មិនត្រូវបានចាត់ទុកជាអ្នកផ្តល់ព័ត៌មានដែលអាចជឿទុកចិត្តបាន)។ |
| **កត្តាវិធីសាស្រ្ត** | ការរៀបចំការស្រាវជ្រាវអាចមានការវិនិច្ឆ័យជាមុន ឬបុរេនិច្ឆ័យចំពោះក្រុម ឬបុគ្គលដែលបាត់ បង់ឱកាស។ ភាពលម្អៀងដោយឯកឯងរបស់អ្នកស្រាវជ្រាវ និងកង្វះការយល់ដឹងពីវិសមភាពនៃទំនាក់ទំនង អំណាចដែលត្រូវបានបង្កើតឡើងរវាងអ្នកស្រាវជ្រាវ និងអ្នកផ្តល់ព័ត៌មាន |
| **កត្តាផ្សេងទៀត** | ទោះបីជាការរៀបចំការស្រាវជ្រាវនិងអ្នកស្រាវជ្រាវបានពិចារណាពីយេនឌ័រ និងការផាត់ចេញពីសង្គមក្តី ក៏នៅតែមិនសូវមានការសម្របសម្រួល និងការគាំទ្រដើម្បីជំរុញការចូលរួមយ៉ាងសកម្មរបស់ក្រុមនិងបុគ្គលដែលបាត់បង់ឱកាស។ការបែងចែកធនធានអាចមិនគ្រប់គ្រាន់ (ពេលវេលា ការគាំទ្រ ដូចជា ការបកប្រែ) និងជំនាញ។ល។)។ |

# ៣.១. វិធីសាស្ត្រ

វិធីសាស្ត្របែបបរិមាណ និងវិធីសាស្ត្របែបគុណភាព សុទ្ធតែមានភាពសមស្រប ផ្នែកវិទ្យាសាស្ត្រ និងពាក់ព័ន្ធគ្នាទៅវិញទៅមក។ តារាងខាងក្រោមបង្ហាញពី លក្ខណៈទូទៅមួយចំនួននៃវិធីសាស្ត្រទាំងពីរនេះ។

(ប្រភព ៖ Flick, von Kardorff, & Steinke, 2004;  Creswell, 2014)

| វិធីសាស្ត្របែបគុណភាព | វិធីសាស្ត្របែបបរិមាណ |
| --- | --- |
| រិះរក និងបង្កើតសម្មតិកម្ម | សាកល្បងសម្មតិកម្ម |
| ការយល់ឃើញរបស់អ្នកស្រាវជ្រាវបែបបរានុម័តជាសមាសភាគមួយនៃភស្តុតាង | ផ្តោតសំខាន់លើភាពឯករាជ្យរបស់អ្នកសង្កេត ដែលមិនពឹងផ្អែកលើកម្មវត្ថុនៃការស្រាវជ្រាវ |
| អន្តរកម្មផ្តោតលើការស្វែងអារម្មណ៍ ការជំរុញទឹកចិត្ត អត្ថន័យ | អន្តរកម្មផ្តោតលើភាពញឹកញាប់នៃអថេរ ដែលកំណត់ទុកជាមុន (កម្រងសំណួរ) |
| ភាពបត់បែនក្នុងការប្រមូលទិន្នន័យ ការប្រើប្រាស់ការសង្កេតរបស់អ្នកចូលរួម ការសម្ភាស កិច្ចសន្ទនា។ល។ | ការប្រមូលទិន្នន័យមានស្តង់ដារខ្ពស់ការប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យដែលមានការរៀបចំនិងប្រភេទដែលកំណត់ទុកជាមុន |
| សំណាកតូច ក្នុងបរិបទធម្មជាតិ | សំណាកធំ បរិបទអាចមិនពាក់ព័ន្ធ |
| ដំណើរការពីក្រោមទៅលើ | ដំណើរការពីលើមកក្រោម |
| ការវិភាគបែបវិសេសានុមាន | ការវិភាគបែបអនុមាន |

***មានការទទួលស្គាល់ជារួមថា វិធីសាស្ត្របែបបរិមាណដោយមានការចូលរួម "ផ្តល់ការយល់ដឹងស៊ីជម្រៅពីកម្រិតបច្ចុប្បន្ន បុព្វហេតុ/មូលហេតុស្នូល ឧបសគ្គ និងឱកាស" របស់ក្រុម និងបុគ្គលដែលបាត់បង់ឱកាស (Smeru Research Institute, 2018)។***

ដើម្បីកំណត់រកបទដ្ឋាន គុណតម្លៃ និងបុរេនិច្ឆ័យដែលកំណត់ពីការបាត់បង់ឱកាស និងការរើសអើង និងយល់ពីផលប៉ះពាល់នៃកត្តាទាំងនេះលើក្រុម និងបុគ្គលទាំងឡាយ ចាំបាច់ត្រូវស្វែងយល់ស៊ីជម្រៅពីទស្សនៈវិស័យ ការជំរុញទឹកចិត្ត ឬអារម្មណ៍។ វិធីសាស្ត្របែបគុណភាពមានភាពសមស្របជាងសម្រាប់ការវិភាគបរិបទស្មុគស្មាញ និងរស់រវើកនៃភាពខុសគ្នាដោយផ្អែកតាមភេទ ជាតិពន្ធុ វណ្ណៈ ស្ថានភាព អត្តសញ្ញាណភេទ។ល។ (Denzin & Lincoln, 2017, Preface)។ ការស្រាវជ្រាវបែបបរិមាណផ្អែកលើសម្មតិកម្មថា អ្នកស្រាវជ្រាវនឹងសាកល្បងដោយកំណត់អថេរជាច្រើន និងប្រមូលភាពញឹកញាប់ និងទំនាក់ទំនងទៅវិញទៅមកនៃអថេរទាំងនោះ។ ផ្ទុយទៅវិញ ការស្រាវជ្រាវបែបគុណភាពជាដំណើរការមួយដែល "ចេញពីក្នុងទៅក្រៅ" ដើម្បីពិនិត្យមើលទស្សនៈរបស់អ្នកចូលរួមក្នុងការស្រាវជ្រាវ (Flick et al., 2004, pp.3-6) និងវិភាគព័ត៌មានទាំងនេះ ដែលត្រូវបានប្រមូលពីការសម្ភាស ការពិភាក្សា និងការសង្កេត ដើម្បីផ្តល់ការពន្យល់។

ជាញឹកញាប់ ការស្រាវជ្រាវបែបគុណភាពត្រូវបានគេចាត់ទុកជាវិធីសាស្ត្រ ***"ដែលមិនសូវមានលក្ខណៈវិទ្យាសាស្ត្រ"*** ហើយការយល់ឃើញនេះក៏ត្រូវបានគូសបញ្ជាក់ផងដែរក្នុងវគ្គបណ្តុះបណ្តាលអនឡាញនេះ។ ទោះជាយ៉ាងណា វិធីសាស្ត្របែបគុណភាពដែលមានលក្ខណៈចម្រុះ និងមានគោលបំណងគាំទ្រដល់ប្រភេទផ្សេងៗនៃការស្រាវជ្រាវផ្នែកសង្គម ឆ្លងកាត់ដំណើរការផ្តល់សុពលភាព និងការគ្រប់គ្រងតឹងរ៉ឹងដូចវិធីសាស្ត្របែបបរិមាណដែរ (Denzin & Lincoln, 2008)។

ការជ្រើសរើសវិធីសាស្ត្រមួយផ្អែកលើកត្តាជាច្រើន។ នៅពេលចុះស្រាវជ្រាវពីវិស័យមួយដែលគេស្គាល់ ក្នុងបរិបទមួយដែលគេដឹងច្បាស់ ស្ដីពីបញ្ហាដែលយ៉ាងហោចណាស់ត្រូវបានគេស្រាវជ្រាវដោយផ្អែក វិធីសាស្ត្រនេះអាចត្រូវបានរៀបចំទុកជាមុន។ ប៉ុន្តែនៅពេលមានការស្រាវជ្រាវទៅលើវិស័យថ្មីៗ ដែលមិនសូវមានការវិភាគទស្សនាទាន និងឯកសារយោង វិធីសាស្ត្រគួរមានលក្ខណៈបើកទូលាយ និងផ្ដល់ភាពបត់បែនច្រើន (សូមមើលក្នុង Flick et al., 2004, Part4)។

វិធីសាស្ត្រអាចរួមបញ្ចូលទាំងសមាសភាគបែបបរិមាណ និងសមាសភាគបែបគុណភាព។ វិធីសាស្ត្របែបគុណភាពអាចផ្ដល់ការយល់ដឹងកាន់តែប្រសើរពីប្រធានបទ និងបញ្ហាសំខាន់ៗ ចំណែកវិធីសាស្ត្របែបបរិមាណអាចកំណត់ចំនួនភាពញឹកញាប់នៃបាតុភូតណាមួយ (Creswell, 2014)។

## ៣.២. ការចូលរួម

***ការធ្វើឱ្យការស្រាវជ្រាវមានលក្ខណៈចូលរួម សំដៅលើការកំណត់ឡើងវិញពីទំនាក់ទំនងរវាងអ្នកជំនាញស្រាវជ្រាវ និងអ្នកចូលរួម។ ក្នុងដំណើរការស្រាវជ្រាវ អាចមានការចូលរួមក្នុងកម្រិតផ្សេងៗ។ ការស្រាវជ្រាវអាចត្រូវបានគ្រប់គ្រងទាំងស្រុងដោយអ្នកស្រាវជ្រាវជំនាញ ដែលរៀបចំវិធីសាស្ត្រប្រមូលទិន្នន័យ និងវិភាគលទ្ធផល។ យ៉ាងណាមិញ អ្នកចូលរួមក៏អាចគ្រប់គ្រងទាំងស្រុងលើដំណើរការស្រាវជ្រាវផងដែរ។ នៅចន្លោះនេះ មានលទ្ធភាពផ្សេងៗជាច្រើន។***

ការស្រាវជ្រាវបែបចូលរួម ប្រមូលបញ្ចូលគ្នានូវទស្សនៈវិស័យរបស់អ្នកចូលរួម និងទស្សនៈវិស័យរបស់អ្នកស្រាវជ្រាវ។ ក្រុមទាំងពីរនេះត្រូវបានទាមទារអោយដើរតួនាទីយ៉ាងសកម្ម យល់ពីគ្នាទៅវិញទៅមក ធ្វើអន្តរកម្ម និងស្វែងរកមូលដ្ឋានរួម (Bergold & Thomas, 2012)។ វិធីសាស្ត្របែបចូលរួមពាក់ព័ន្ធនឹងការបែងចែកអំណាចឡើងវិញរវាងអ្នកស្រាវជ្រាវជំនាញ និងអ្នកចូលរួម ដោយមិនប្រកាន់គំនិតថាមានតែអ្នកខាងក្រៅទេ (អ្នកស្រាវជ្រាវ) ដែលមានជំនាញ និងងាកទៅរកការទទួលស្គាល់ចំណេះដឹង ជំនាញ ទស្សនៈ និងចក្ខុវិស័យរបស់អ្នកចូលរួម។

រូប ២ ៖ កម្រិតនៃការចូលរួម និងទំនាក់ទំនងរវាងអ្នកស្រាវជ្រាវ និងអ្នកឆ្លើយតប




( ដកស្រង់ចេញពី Schubotz, 2020 )

ការស្រាវជ្រាវបែបចូលរួមដ៏ពិតប្រាកដជាមួយសហគមន៍គឺជាដំណើរការស្មុគស្មាញមួយ ដែលទាមទារពេលវេលា ធនធាន ជំនាញ និងសមត្ថភាពដោះស្រាយទិដ្ឋភាពផ្សេងៗជាច្រើនដែលអាចលេចឡើង និងត្រូវដោះស្រាយ។ ដូច្នេះហើយទើបការស្រាវជ្រាវបែបចូលរួមជាមួយសហគមន៍ ឬក្រុម ច្រើនតែត្រូវបានរឹតត្បិតដោយបញ្ហាពេលវេលា និងថវិកា។ ទោះជាយ៉ាងណា សូម្បីតែក្នុងក្របខណ្ឌនៃការស្រាវជ្រាវដែលមិនសូវមានការចូលរួម ក៏គេនៅតែអាចអនុវត្តវិធីសាស្ត្របែបសហការ និងផ្តោតលើភាពជាដៃគូដែលបង្កើនការចូលរួមបានដែរ។

*ឧ. អ្នកអាចគ្រោងរៀបចំក្រុមផ្តល់ប្រឹក្សារបស់អ្នកចូលរួមដែលនឹងពិនិត្យឡើងវិញលើការរៀបចំការស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវ ជំរុញការចូលរួមរបស់អ្នកចូលរួមក្នុងការប្រមូលព័ត៌មាន និងការវិភាគលទ្ធផល អំពាវនាវឱ្យអ្នកចូលរួមផ្តល់សុពលភាពដល់លទ្ធផល។ល។*

# ៣.៣. ការស្រាវជ្រាវជាមួយក្រុមដែល បាត់បង់ឱកាស

ការស្រាវជ្រាវជាមួយក្រុម ឬបុគ្គលដែលបាត់បង់ឱកាស និងត្រូវបានផាត់ចេញពីសង្គមទាមទារនូវវិធីសាស្ត្រសមស្របពេលវេលា និងការគ្រប់គ្រងភាពលម្អៀងការវិនិច្ឆ័យជាមុន និងទំនាក់ទំនងអំណាចដែលកើតចេញពីទំនាក់ទំនងរវាងអ្នកស្រាវជ្រាវ និងអ្នកចូលរួម។ អ្នកស្រាវជ្រាវគួរដឹង និងឆ្លុះបញ្ចាំងពីគោលជំហរអំណាចរបស់ខ្លួន ធៀបនឹងក្រុម ឬបុគ្គលដែលបាត់បង់ឱកាស និងទទួលស្គាល់ការមានប្រៀបជាងរបស់ខ្លួនពាក់ព័ន្ធនឹងស្ថានភាពសង្គម ភេទ ឬទិដ្ឋភាពផ្សេងទៀត។ ក្រៅពីនេះ អ្នកស្រាវជ្រាវដែលមិនអនុវត្តវិធីសាស្ត្របែបចូលរួម និងមានការចរចាក្នុងការស្រាវជ្រាវ មានអំណាចសម្រេចចិត្តលើដំណើរការនេះ ព្រោះពួកគេរៀបចំ គ្រោង និងអនុវត្តការស្រាវជ្រាវ (Moree, 2018)។

*ការចរចាក្រុម និងបុគ្គលដែលបាត់បង់ឱកាស ឱ្យចូលរួមក្នុងការស្រាវជ្រាវ ជាវិធីមួយក្នុងការកាត់បន្ថយវិសមភាពនៃទំនាក់ទំនងអំណាចរវាងអ្នកស្រាវជ្រាវ និងអ្នកចូលរួម។ សមភាពយេនឌ័រ និងសង្គមបរិយាបន្ន ផ្តោតលើការផ្លាស់ប្តូរក្នុងសង្គម ហើយគេមិនអាចសម្រេចគោលដៅនេះបានឡើយ ប្រសិនបើក្រុម ឬបុគ្គលទាំងនោះមិនត្រូវបានបង្កើនភាពអង់អាច មិនដឹងពីគោលដៅនៃដំណើរការដែលពួកគេចូលរួម មិនអាចបញ្ចេញមតិរបស់ខ្លួនដោយសេរី ឬមិនអាចប្រើប្រាស់ទីភ្នាក់ងាររបស់ខ្លួនបាន។*

# ៣.៤. ការគិតគូរពីក្រមសីលធម៌

ក្រុមដែលបាត់បង់ឱកាសក្នុងសង្គម  អាចប្រឈមនឹងឧបសគ្គដែលរារាំងមិនឱ្យពួកគេចូលរួមពេញលេញ និងហានិភ័យសម្រាប់ការចូលរួម។ ការបង្ហាញខ្លួនជាសាធារណៈ និងការនិយាយពីការព្រួយបារម្ភផ្ទាល់ខ្លួន អាចធ្វើឱ្យពួកគេកាន់តែបាត់បង់ឱកាស ឬប្រឈមនឹងគ្រោះថ្នាក់។ មានករណីដែលស្ត្រីត្រូវបានសាច់ញាតិ ឬដៃគូខឹងសម្បារ បន្ទាប់ពីបានឡើងនិយាយក្នុងកិច្ចប្រជុំសហគមន៍ស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ។

## ការយល់ព្រមជាមុនក្នុងការផ្តល់ព័ត៌មានស្រាវជ្រាវ

អ្នកចូលរួមត្រូវផ្តល់ការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវក្នុងការស្រាវជ្រាវ។ គួរចាត់ទុកចំណុចនេះជាដំណើរការ ជាជាងគ្រាន់តែជាផ្តល់ការអនុញ្ញាតលំៗ ( simple preemptive green light ) ដល់អ្នកស្រាវជ្រាវ។  ដូច្នេះប្រហែលជាមានការពិនិត្យឡើងវិញ និងការពិភាក្សាឡើងវិញក្នុងដំណើរការស្រាវជ្រាវ ហើយអ្នកចូលរួមគួរមានសិទ្ធិដកការយល់ព្រមរបស់ខ្លួនបានគ្រប់ពេល។

## ការបណ្តុះបណ្តាលក្រមសីលធម៌ដល់បុគ្គលិកស្រាវជ្រាវ

បុគ្គលិកស្រាវជ្រាវត្រូវឆ្លងកាត់ការបណ្តុះបណ្តាលស្តីពីក្រមសីលធម៌ក្នុងការស្រាវជ្រាវ សិទ្ធិមនុស្ស ការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ និងមានក្រមសីលធម៌ និងការទទួលខុសត្រូវខ្ពស់។

## ទំនួលខុសត្រូវក្នុងការរាយការណ៍ប្រកបដោយសីលធម៌

ការទទួលខុសត្រូវ និងក្រមសីលធម៌ក្នុងការរាយការណ៍លទ្ធផល។

## ការផ្តល់អត្ថប្រយោជន៍ច្បាស់លាស់នៃការស្រាវជ្រាវ

ការចូលរួមក្នុងការស្រាវជ្រាវនេះគួរផ្តល់អត្ថប្រយោជន៍ច្បាស់លាស់។ នេះជាផ្នែកមួយនៃការយល់ព្រមដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ និងគួរកំណត់ឱ្យបានច្បាស់។

## ការសហការដែលផ្តល់អាទិភាពដល់សហគមន៍

គួរសហការជាមួយដៃគូ និងអង្គការក្នុងសហគមន៍ ទីជម្រក រចនាសម្ព័ន្ធជំនួយ ឬអ្នកពាក់ព័ន្ធដែលមានឯកទេសផ្សេងទៀតដើម្បីដោះស្រាយការព្រួយបារម្ភមួយចំនួន(អំពើហិង្សាលើស្ត្រី ឬកុមារ ការបំពានគ្រឿងញៀន ការជួញដូរមនុស្ស ការងារដោយបង្ខំ ការរំលោភសិទ្ធិមនុស្ស។ល។)



**ការស្រាវជ្រាវសមភាពយេនឌ័រ និងសង្គមបរិយាប័ន្ន ដែលជំរុញការចូលរួមយ៉ាងសកម្មរបស់ក្រុម និងបុគ្គលដែលបាត់បង់ឱកាស គួរពង្រឹងវិធានការនានាដើម្បីធានាថា អ្នកចូលរួមនឹងទទួលបានប្រយោជន៍ពីការស្រាវជ្រាវនេះ។ សំខាន់ជាងនេះទៅទៀត ត្រូវការពារអ្នកចូលរួមពីហានិភ័យដែលពាក់ព័ន្ធនឹងការចូលរួមក្នុងការស្រាវជ្រាវនេះ។** គោលការណ៍ទាំងនេះអនុវត្តចំពោះការស្រាវជ្រាវផ្នែកសង្គមគ្រប់ប្រភេទ ប៉ុន្តែមានសារៈសំខាន់ណាស់នៅពេលធ្វើការជាមួយក្រុមដែលបាត់បង់ឱកាស។ ខាងក្រោមនេះជាគោលការណ៍ណែនាំមួយចំនួនដែលត្រូវពិចារណា ៖

### ការផ្តល់ដំណឹងជាមុនពីហានិភ័យដែលអាចកើតមាន

គួរប្រាប់អ្នកចូលរួមពីហានិភ័យពាក់ព័ន្ធនឹងការស្រាវជ្រាវនេះ និងផ្តល់ការពិពណ៌នាពេញលេញស្តីពីរបៀបគ្រប់គ្រងហានិភ័យទាំងនេះ។

### ការគោរពដល់ឯកជនភាពរបស់អ្នកចូលរួម

ការរក្សាការសម្ងាត់ និងអនាមិកភាពជាចំណុចដែលគួរលើកមកពិភាក្សាស៊ីជម្រៅជាមួយអ្នកចូលរួម និងគួរអនុវត្តវិធានការនានាដើម្បីគោរពអនុសាសន៍ និងការទាមទាររបស់ពួកគេ។

### ការការពារសិទ្ធនៃការចូលរួម

ការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងនគរបាល អាចជាកត្តាភាពចាំបាច់ដើម្បីធានាថា ការចូលរួមក្នុងការស្រាវជ្រាវមិនបង្កើនហានិភ័យនៃការកំណត់អត្តសញ្ញាណ ការចាប់ខ្លួន ឬការឃុំឃាំងនៅពេលធ្វើការជាមួយក្រុមជាក់លាក់ (អ្នកប្រកបរបរផ្លូវភេទ អ្នកប្រើប្រាស់ថ្នាំញៀន ។ល។)

### ការប៉ះប៉ូវដល់អ្នកចូលរួមប្រកបដោយសីលធម៌

គួរពិចារណាពីការប៉ះប៉ូវដល់ការចូលរួមក្នុងសកម្មភាពស្រាវជ្រាវ ប្រសិនបើការធ្វើការជាមួយជនក្រីក្រខ្លាំង ឬអ្នកដែលពឹងផ្អែកលើប្រាក់ចំណូលប្រចាំថ្ងៃ ប្រសិនបើការចូលរួមនោះចំណាយពេលយូរ (សកម្មភាពសហគមន៍ដែលចំណាយពេលជាច្រើនថ្ងៃ។ល។)។ គួរចរចាគ្នាពីប្រភេទ បរិមាណ និងសិទ្ធិទទួលបានការប៉ះប៉ូវ។ ជាញឹកញាប់ ការប៉ះប៉ូវជាសម្ភារៈជាវិធីសាស្ត្រសមស្រប។



# ៣.៥. ឯកសារសម្រាប់ការពិភាក្សា និងលំហាត់ជាក្រុម

វគ្គទី ៣ ផ្តោតលើការស្រាវជ្រាវជាមួយក្រុមដែលបាត់បង់ឱកាស និងក្រុមដែលត្រូវបានផាត់ចេញ។ មានការបង្កើតករណីសិក្សាជាច្រើនដើម្បីពិភាក្សាពីរបៀបកំណត់អត្តសញ្ញាណក្រុម ដែលបាត់បង់ឱកាសក្នុងបរិបទមួយ ក្នុងការស្រាវជ្រាវសមភាពយេនឌ័រ និងបរិយាបន្នសង្គម។

## ករណីសិក្សា ៣.១

### *ការប្រើប្រាស់ប្រព័ន្ធទឹកនៅតាមខេត្ត*

ក្នុងឃុំមួយនៃខេត្ត ក ដើម្បីផ្តល់ទឹកស្រោចស្រពដល់កសិករនៅរដូវប្រាំង គេបានសង់ទំនប់មួយក្រោមជំនួយពីម្ចាស់ជំនួយខាងក្រៅ និងមូលនិធិអភិវឌ្ឍន៍ឃុំ។ ទំនប់នេះទ្រទ្រង់ភូមិ ៤។ ដើម្បីគ្រប់គ្រងធនធានទឹក គេបានបង្កើតគណៈកម្មាធិការគ្រប់គ្រងទឹកសហគមន៍ដោយផ្អែកតាមច្បាប់។ ក្រោយការអនុវត្តសកម្មភាពបានប៉ុន្មានឆ្នាំ គេបានគ្រោងរៀបចំការស្រាវជ្រាវមួយដើម្បីវាយតម្លៃលទ្ធភាពរបស់អ្នកភូមិក្នុងការទទួលបានធនធានទឹក និងស្វែងយល់ថាតើមានទម្រង់នៃការផាត់ចេញ ឬទេ និងមូលហេតុ។

**ក្នុងដំណើរការនៃការរៀបចំការស្រាវជ្រាវនេះ គេត្រូវឆ្លើយសំណួរ ២ ខាងក្រោម៖**

- តើក្រុមណាខ្លះក្នុងសហគមន៍ដែលគួរក្លាយជាចំណុចផ្តោតនៃការស្រាវជ្រាវនេះ?
- តើអ្នកស្រាវជ្រាវអាចចូលទៅជួបក្រុមទាំងនេះប្រមូលការយល់ឃើញរបស់ពួកគេ និងកាត់បន្ថយភាពលម្អៀង ដោយរបៀបណា? ភាពលម្អៀងកើតឡើងដោយសារតែបរិស្ថានជុំវិញ (អ្នកផ្តល់ព័ត៌មាន សមាជិកសហគមន៍ ។ល។) ឬការតាក់តែងការស្រាវជ្រាវ ។

# ករណីសិក្សា ៣.២

## *យេនឌ័រ និងបរិយាបន្នក្នុងការបោះបង់ការសិក្សា*

ផ្អែកតាមស្ថិតិដែលប្រមូលដោយអាជ្ញាធរមូលដ្ឋាន ឃុំ ខ បង្ហាញពីកំណើនខ្ពស់នៃអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា។ និន្នាការនេះមានលក្ខណៈស្រដៀងគ្នាក្នុងចំណោមសហគមន៍ទូទាំងឃុំ។ សាលាបឋមសិក្សាស្ថិតនៅតាមសហគមន៍នីមួយៗ។ អាជ្ញាធរចង់ធ្វើការសិក្សាស្រាវជ្រាវដើម្បីវាយតម្លៃថាតើសមភាព/វិសមភាពយេនឌ័រ និងសង្គមបរិយាប័ន្ន/ការផាត់ចេញពីសង្គម រួមចំណែកដល់ការការបោះបង់ការសិក្សារបស់ក្មេងស្រី និងក្មេងប្រុស ឬទេ និងដោយរបៀបណា?

- តើគេត្រូវការទិន្នន័យបន្ទាប់បន្សំអ្វីខ្លះដើម្បីគ្រោងរៀបចំការស្រាវជ្រាវនេះ?
- តើគួរពិគ្រោះជាមួយអ្នកផ្តល់ព័ត៌មាន/អ្នកពាក់ព័ន្ធណាខ្លះដើម្បីទទួលបានព័ត៌មាន?
- តើគួរផ្តោតសំខាន់លើសហគមន៍/ក្រុម ឬគ្រួសារណាខ្លះ?

- ព្រាងបញ្ជីឈ្មោះបណ្តោះអាសន្នរបស់ក្រុមឬគ្រួសារដែលត្រូវការការយកចិត្តទុកដាក់ រួចពន្យល់ពីមូលហេតុ។
- តើអ្នកគួរអនុវត្តការស្រាវជ្រាវដើម្បីស្វែងរកកត្តាដែលនាំអោយមានការបោះបង់ការសិក្សាដោយរបៀបណា?

# ករណីសិក្សា ៣.៣

## *អាទិភាពរបស់សហគមន៍នៅតាមខេត្ត*

សហគមន៍មួយក្នុងខេត្តគចូលរួមក្នុងការព្រាងអាទិភាពរបស់ខ្លួនសម្រាប់ផែនការអភិវឌ្ឍន៍ឃុំប្រចាំឆ្នាំ។សហគមន៍នោះមានចម្ងាយ១៥គីឡូម៉ែត្រពីផ្លូវខេត្ត ទីផ្សារ និងមណ្ឌលសុខភាព។ សហគមន៍នោះមានប្រជាជន ២៥០ គ្រួសារ ដែលភាគច្រើនធ្វើកសិកម្ម (ធ្វើស្រែ និងដាំបន្លែមួយចំនួន)។ បុរស និងស្ត្រីវ័យក្មេងជាច្រើនបានចាកចេញពីភូមិ ហើយក្នុងករណីខ្លះបានទុកកូនឱ្យយាយតាជាអ្នកថែទាំ។ គ្រួសារក្រីក្របំផុត (ID Poor) មានប្រមាណ ១៤% នៃចំនួនប្រជាជនសរុបក្នុងសហគមន៍។ ការពិភាក្សាបឋមបានគូសបញ្ជាក់ពីអាទិភាពជាច្រើន ដូចជា អាងសម្រាប់ស្តុកទឹកនៅរដូវប្រាំង បណ្តាញធារាសាស្ត្រថ្មីសម្រាប់កសិករធ្វើស្រែប្រាំង ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធអនាម័យសម្រាប់សាលារៀន និងគ្រួសារក្រីក្របំផុតដែលគ្មានលទ្ធភាពសង់ដោយខ្លួនឯងបាន ការជួសជុលផ្លូវ ការថែទាំកុមារនៅថ្នាក់មុនមត្តេយ្យ និងរចនាសម្ព័ន្ធអាហារដ្ឋានក្នុងសាលារៀនសម្រាប់ការផ្តល់អាហារនៅសាលារៀន ដោយមានការរួមចំណែកពីអ្នកផលិតអាហារក្នុងមូលដ្ឋាន។ សហគមន៍នេះមានមតិបែកខ្ញែកគ្នា ព្រោះក្រុមខ្លះទាមទារឱ្យមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ បណ្តាញធារា សាស្ត្រ) ចំណែកក្រុមផ្សេងទៀតទាមទារអន្តរាគមន៍សង្គមកាន់តែច្រើន ដូចជា អនាម័យ សាលាមត្តេយ្យ និងការផ្តល់អាហារនៅសាលារៀន។

ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងដើម្បីស្វែងយល់ពីអាទិភាពរបស់ប្រជាជន និងរួមចំណែកដល់ការរៀបចំផែនការដែលផ្តោត លើសមភាពយេនឌ័រ និងសង្គមបរិយាបន្ន។

- តើក្រុមណាខ្លះក្នុងសហគមន៍ដែលគួរតែជាចំណុចផ្តោតនៃការស្រាវជ្រាវដើម្បីជានាបរិយាបន្ន?
- តើវិធីសាស្ត្រណាជាជម្រើសល្អបំផុតសម្រាប់ការប្រមូលព័ត៌មានពីក្រុមទាំងនេះ?

**មានវីដេអូមួយចំនួនស្តីពីការស្រាវជ្រាវជាមួយក្រុមដែលបាត់បង់ឱកាស វិធីសាស្ត្របែបចូលរួម និងការព្រួយបារម្ភពីក្រមសីលធម៌ ដែលអាចបំផុសការពិភាក្សាបន្ថែម ៖**

- សមត្ថភាពផ្នែកវប្បធម៌ និងការដាក់ខ្លួនក្នុងវប្បធម៌ (ជាភាសាអង់គ្លេស)៖ ផ្តល់ការឆ្លុះបញ្ចាំងពីទំនាក់ទំនងអំណាច ការយល់ដឹងរបស់អ្នកស្រាវជ្រាវ និងក្រុមដែលបាត់បង់ឱកាស
- ការជំរុញការចូលរួមរបស់ក្រុមដែលបាត់បង់ឱកាស (ជាភាសាអង់គ្លេស) ៖ គំនូរជីវចលស្តីពីរបៀបជំរុញក្រុម ឬបុគ្គលដែលបាត់បង់ឱកាសក្នុងសហគមន៍ ឱ្យចូលរួមក្នុងការស្រាវជ្រាវ
- វិធីសាស្ត្រជំរុញឱ្យសហគមន៍ចូលរួមក្នុងការគ្រប់គ្រងទន្លេនៅខេត្តស្ទឹងត្រែង (ជាភាសាខ្មែរ) ៖ វីដេអូឯកសារស្តីពីការស្រាវជ្រាវបែបចូលរួម ដែលបានធ្វើឡើងជាមួយសហគមន៍នេសាទស្តីពីបរិស្ថាន
- ក្រមសីលធម៌ក្នុងការស្រាវជ្រាវ (ជាភាសាអង់គ្លេស) ៖ សេចក្តីផ្តើមខ្លីស្តីពីក្រមសីលធម៌ក្នុងការស្រាវជ្រាវ។



# ៤ សមភាពយេនឌ័រ និង សង្គមបរិយាបន្នក្នុងការស្រាវជ្រាវ

យុទ្ធសាស្ត្រស្រាវជ្រាវសមភាពយេនឌ័រ និងសង្គមបរិយាបន្ន បញ្ជាក់ថាមានការពិចារណាពីសមភាព យេនឌ័រ និងសង្គមបរិយាបន្ន ក្នុងពេលរៀបចំ គ្រោង និងធ្វើការស្រាវជ្រាវ។ ផ្នែករងខាងក្រោមផ្តល់ព័ត៌មាន ពាក់ព័ន្ធនឹងការបញ្ជ្រាបសមភាពយេនឌ័រ និងសង្គមបរិយាបន្នក្នុងជំហានផ្សេងៗទាំងនេះ។ ដោយមិនគ្របដណ្តប់លើផ្នែកទាំងអស់នៃការអនុវត្តការស្រាវជ្រាវ ផ្នែករងទាំងនេះនឹងផ្តល់គន្លឹះអនុវត្តន៍មួយចំនួនដើម្បីជាត្រីវិស័យក្នុង ការរៀបចំ និងធ្វើការស្រាវជ្រាវដែលផ្តោតការយកចិត្តទុកដាក់លើសមភាពយេនឌ័រ និង សង្គមបរិយាបន្ន។




## ៤.១. ក្របខណ្ឌទ្រឹស្តី និងការពិនិត្យឡើងវិញលើឯកសារពាក់ព័ន្ធ

ក្រោយពេលកំណត់ច្បាស់ពីគោលដៅទូទៅនៃការស្រាវជ្រាវ ក្របខណ្ឌទស្សនាទានសម្រាប់ការរៀបចំ សំណួរស្រាវជ្រាវ និងការរៀបចំការសិក្សាត្រូវបានបង្កើតឡើងចេញពីការស្រាវជ្រាវឯកសារពាក់ព័ន្ធ។ ចំណុចនេះ អាចឱ្យអ្នកដឹងនូវអ្វីដែលត្រូវបានរកឃើញ វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់សម្រាប់ការវិភាគបញ្ហា ការជជែកដេញដោលលើបញ្ហានេះ ចំណុចខ្វះខាត និងផ្នែកនានានៃការស្រាវជ្រាវដែលមិនសូវមានការស្វែងយល់និងពាក្យបច្ចេកទេសដែលគេប្រើ។

បច្ចុប្បន្ន យេនឌ័រត្រូវបានទទួលស្គាល់ជាសមាសភាគដ៏សំខាន់មួយនៃការវិភាគសង្គម ហើយការសិក្សាយេនឌ័រគ្របដណ្តប់លើវិស័យ និងវិជ្ជាជីវៈទាំងអស់។ដូច្នេះមានឯកសារពាក់ព័ន្ធយ៉ាងច្រើនដែលស្រាវជ្រាវពីទិដ្ឋភាពយេនឌ័រក្នុងវិស័យផ្សេងៗ ដូចជាកសិកម្ម ( សូមមើល FAO & World Bank, 2008; Razavi, 2009; Quisumbing, Agnes R. et al., 2014 ) ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងនេសាទ (សូមមើល Agarwal, 2010; Colfer & Minarchek, 2012; CIFT, 2012) និងគោលនយោបាយសាធារណៈ ម៉ាក្រូសេដ្ឋកិច្ច និងការងារ (Jain & Elson, 2011;Lansky, Ghosh, Meda, & Rani, 2017 )។ល។ ការស្រាវជ្រាវក៏មានភាពរីកចម្រើនក្នុងវិស័យនានា ដូចជាយេនឌ័រ និងជាតិពន្ធុ វណ្ណៈ និងឋានៈ ពិការភាព អត្តសញ្ញាណភេទ និងប្រភេទផ្សេងទៀតក្នុងសង្គមផងដែរ។ ការសិក្សាជាច្រើនក្នុងចំណោមនេះផ្តោតលើវិស័យ តំបន់ភូមិសាស្ត្រ ឬបរិបទសង្គមជាក់លាក់។

ប្រសិនបើជាតិពន្ធុបង្កើតបានជាសមាសភាគដ៏សំខាន់មួយក្នុងការស្រាវជ្រាវនេះ ប្រការសំខាន់ត្រូវប្រមូលព័ត៌មានដើម្បីស្វែងយល់ពីរបេចិញ្ចឹមជីវិត ការរៀបចំសង្គម វប្បធម៌ និងជំនឿ និងតួនាទីយេនឌ័រក្នុងក្រុមជាតិពន្ធុដែលប្រឈមនឹងហានិភ័យ។ ឧ. ក្នុងករណីក្រុមជនជាតិដើមភាគតិចនៅកម្ពុជា ការស្រាវជ្រាវមិនអាចផាត់ចេញវិស័យកសិកម្ម និងរបៀបចាត់ចែងធនធានធម្មជាតិ ច្បាប់ទំនៀមទំលាប់ ការរៀបចំសង្គម និងជំនឿវប្បធម៌របស់ពួកគេ និងតួនាទីយេនឌ័រក្នុងសង្គមរបស់ពួកគេបានឡើយ (សូមមើល Park & Maffii, 2017)។ ចំណេះដឹងនេះជួយលុបបំបាត់ការវិនិច្ឆ័យជាមុន និងផ្ទត់គំនិតដែលកើតចេញពីការមិនយល់ដឹង។

# ៤.២. ធនធាន

វិធីសាស្ត្រសមស្របសម្រាប់ការស្រាវជ្រាវសមភាពយេនឌ័រ និងសង្គមបរិយាបន្ន ត្រូវបានពិភាក្សាក្នុង វគ្គមុន។ គួរបញ្ជាក់ផងដែរថា វិធីសាស្ត្របែបគុណភាពផ្តល់ឱកាសកាន់តែច្រើនដល់ការស្រាវជ្រាវពីការរើសអើងយេនឌ័រ និងការផាត់ចេញពីសង្គមដោយផ្អែកលើទស្សនៈវិស័យរបស់បុគ្គល និង/ឬសហគមន៍។ ទោះជាយ៉ាងណា អ្នកស្រាវជ្រាវគួរពិចារណាពីធនធានដែលមាន ដូចជា ជំនាញ ពេលវេលា និងថវិកា។

ក្របខណ្ឌពេលវេលា និងមូលនិធិតិចតួច មិនអាចឱ្យអ្នកស្រាវជ្រាវប្រឡូកក្នុងការងារចុះប្រមូលទិន្នន័យ យ៉ាងច្រើន និងវិធីសាស្ត្របែបចូលរួមដែលទាមទារការចូលរួមរបស់សហគមន៍ និងអន្តរកម្មចម្រុះបានឡើយ។ កត្តាដ៏សំខាន់មួយទៀតគឺជំនាញ។ យ៉ាងហោចណាស់ ក្រុមស្រាវជ្រាវសមភាពយេនឌ័រ និងបរិយាប័ន្នសង្គម គួរមានសមាសភាគអ្នកជំនាញយេនឌ័រម្នាក់ ព្រោះថា ការវិភាគយេនឌ័រត្រូវធ្វើឡើងជាចាំបាច់។ មានលក្ខខណ្ឌតម្រូវផ្នែក ទ្រឹស្តីដែលត្រូវដោះស្រាយ និងប្រែក្លាយទៅជាឧបករណ៍វិធីសាស្ត្រ និងការអនុវត្ត។ ក្រៅពីយេនឌ័រ បទពិសោធន៍ក្នុងការអនុវត្តការស្រាវជ្រាវដោយប្រើវិធីសាស្ត្រជាក់លាក់ ដូចជា វិធីសាស្ត្របែបគុណភាព និងវិធីសាស្ត្របែបចូលរួម ក៏ជាបុរេលក្ខខណ្ឌមួយផងដែរ។ ប្រសិនបើការស្រាវជ្រាវសមភាពយេនឌ័រ និងបរិយាប័ន្នសង្គម ផ្តោតលើវិស័យជាក់លាក់ (ការផាត់ចេញដោយសារពិការភាព ជាតិពន្ធុ។ល។) ចាំបាច់ត្រូវមានជំនាញក្នុងការអនុវត្តការស្រាវជ្រាវផ្នែកសង្គមទាំងនេះផងដែរ។

# ៤.៣. ទិន្នន័យបន្ទាប់បន្សំដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ និងសង្គមបរិយាបន្ន

**ទិន្នន័យបន្ទាប់បន្សំ គួរពិចារណាពីប្រភេទដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ និងសង្គមបរិយាបន្ន។ ដូច្នេះ ចាំបាច់ត្រូវប្រមូលទិន្នន័យដូចខាងក្រោម៖**

## ទិន្នន័យបែងចែកតាមភេទនៅ មានកម្រិត

ទិន្នន័យបែងចែកតាមភេទនៅកម្រិតមូលដ្ឋាន ដែលពាក់ព័ន្ធនឹងប្រជាជន សន្ទស្សន៍ភាពក្រីក្រ (ID Poor) សមាសភាគគ្រួសារ អាយុ ជាតិពន្ធុ របរចិញ្ចឹមជីវិត លទ្ធភាពទទួលបានធនធាន (សិទ្ធិកាន់កាប់ដីធ្លី) លទ្ធភាពជ្រៀតចូលទីផ្សារ ការធ្វើចំណាកស្រុក ការអប់រំ និងអក្ខរភាព សុខភាព (ប្រេវ៉ាឡង់មេរោគអេដស៍ របេង ពិការភាព។ល។) អាហារូបត្ថម្ភ ការធ្វើដំណើរ ចល័តភាព ទំនាក់ទំនង សុខភាពបន្តពូជ (លទ្ធភាពទទួលបានសេវាពន្យារកំណើត ការពិនិត្យផ្ទៃពោះមុនពេលសម្រាល មរណមាតា។ល។) ប្រេវ៉ាឡង់នៃអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្អែកលើយេនឌ័រ។

ជាញឹកញាប់ គ្មានប្រភពទិន្នន័យដែលចងក្រងឯកសារស្តីពីក្រុមដែលបាត់បង់ឱកាសផ្សេងទៀត ដូចជាក្រុម LGTBI អ្នកប្រកបរបរផ្លូវភេទ កម្មករក្រៅប្រព័ន្ធ ដូចជា អ្នកសុំទាន អ្នករើសអេតចាយ អ្នកជំពាក់បំណុល អ្នកប្រើប្រាស់គ្រឿងញៀន ឬក្រុមផ្សេងទៀតដែលប្រឈមនឹងការបាត់បង់ឱកាស និងការមាក់ងាយក្នុងសង្គម យ៉ាងខ្លាំងឡើយ។

## ការខ្វះចន្លោះទិន្នន័យបែងចែកតាមភេទនៅថ្នាក់ជាតិ

ទិន្នន័យបែងចែកតាមភេទនៅថ្នាក់ជាតិ ច្រើនតែគ្មាន ហើយនេះជាបញ្ហា។ ក្នុងករណីខ្លះ គេអាចរកបានទិន្នន័យ នៅកម្រិតទាប។ ការិយាល័យជាច្រើនក្នុងរដ្ឋបាលសាធារណៈធ្វើកិច្ចការជាច្រើនលើការប្រមូលទិន្នន័យដែលជា ញឹកញាប់មិនសូវមានមធ្យោបាយ និងលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យា (ស្ថិតិសរសេរដោយដៃ ឬកត់ត្រាលើ ក្រដាស ឬក្តារខៀន។ល។)

## ក្របខណ្ឌច្បាប់អំពីសមភាព

ក្របខណ្ឌច្បាប់ មានសារៈសំខាន់ក្នុងការធ្វើក្របខណ្ឌទៅលើលើការរើសអើងយេនឌ័រ និងការផាត់ចេញពីសង្គមក្នុងបរិបទច្បាប់ទូលំទូលាយ តាមរយៈការស្រាវជ្រាវពីសិទ្ធិគ្រប់ជ្រុងជ្រោយផ្អែកតាមរដ្ឋធម្មនុញ្ញ ច្បាប់ជាតិ និងការផ្តល់សច្ចាប័នដល់លិខិតុបករណ៍អន្តរជាតិ (អនុសញ្ញា CEDAW អនុសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងការរើសអើងពូជសាសន៍ សិទ្ធិជនជាតិដើមភាគតិច សិទ្ធិការងារ។ល។)។

## គោលនយោបាយជាតិអំពីបរិយាបន្ន

គោលនយោបាយជាតិតាមវិស័យ ត្រូវបានតាក់តែងឡើងដើម្បីដោះស្រាយបញ្ហាសង្គមជាក់លាក់ (គោលនយោបាយ ឬយុទ្ធសាស្ត្រយេនឌ័រ គោលនយោបាយជាតិដែលផ្តោតលើភាពក្រីក្រ សន្តិសុខ សង្គម ប្រជាជនវ័យចំណាស់ ឬយុវជន ជនមានពិការភាព អ្នកផ្ទុកមេរោគអេដស៍ ក្រុមជនជាតិ ដើមភាគតិច។ល។)

## ទិន្នន័យស្តីពីនិន្នាការសង្គម និងសេដ្ឋកិច្ច

ទិន្នន័យដែលមានស្តីពីនិន្នាការ និងការផ្លាស់ប្តូរ ៖ ឧ. ចំណាកស្រុក ឬចំណូលស្រុក ការប្រែប្រួលលទ្ធភាពទទួលបានដីធ្លី និងធនធានធម្មជាតិ សកម្មភាព និងប្រភពរបរចិញ្ចឹមជីវិតថ្មីៗ។ល។

## ៤.៤. ការកំណត់ជាមុននូវអត្តសញ្ញាណ របស់ក្រុមដែលបាត់បង់ឱកាស

ដូចការលើកឡើងខាងលើ មិនមែនក្រុមដែលបាត់បង់ឱកាសទាំងអស់សុទ្ធតែត្រូវបានកំណត់អត្តសញ្ញាណទុកជាមុនឡើយ ព្រោះក្រុម ឬបុគ្គលទាំងឡាយមិនមែនលេចឡើងតែក្នុងដំណើរការស្រាវជ្រាវនោះទេ។ ទោះជាយ៉ាងណា ទិន្នន័យបន្ទាប់បន្សំដើរតួនាទីជាត្រីវិស័យ និងអាចផ្តល់ទស្សនៈវិស័យទូទៅមួយ (ភាគរយនៃអត្ត-សញ្ញាណកម្មគ្រួសារក្រីក្រ ជនចំណាកស្រុក ស្ត្រីមេគ្រួសារ ក្រុមជាតិពន្ធុ អ្នកគ្មានដីធ្លី។ល។)។

- **គេអាចប្រមូលព័ត៌មានស្តីពីក្រុមដែលបាត់បង់ឱកាសពីអ្នកផ្តល់ព័ត៌មាននៅមូលដ្ឋាន** ដូចជា អាជ្ញាធរសហគមន៍ ប្រធានក្រុម អ្នកពាក់ព័ន្ធអង្គការសង្គមស៊ីវិល។ល។ ប៉ុន្តែជាញឹកញាប់ អ្នកផ្តល់ព័ត៌មានមិនមានភាពអព្យាក្រឹត្យឡើយ។ អាជ្ញាធរមូលដ្ឋាន អ្នកពាក់ព័ន្ធ ឬអង្គការសង្គមស៊ីវិលអាចប្រើការវិនិច្ឆ័យខ្ពស់ពេកទៅលើក្រុមមួយចំនួន ឬប្រើការវិនិច្ឆ័យទាបពេកទៅលើក្រុមផ្សេងទៀត។ គេអាចលុបបំបាត់ភាពលម្អៀងដែលពាក់ព័ន្ធនឹងអ្នកផ្តល់ព័ត៌មានតាម រយៈការផ្អែកលើព័ត៌មានពីប្រភពចម្រុះ ជាពិសេសប្រសិនបើព័ត៌មានពីប្រភពទាំងនោះតំណាងឱ្យផលប្រយោជន៍ ផ្សេងគ្នា (អង្គការរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិលដែលផ្តោតលើជនជាតិដើមភាគតិច និងអង្គការសង្គមស៊ីវិលដែលមិនផ្តោតលើជនជាតិដើមភាគតិច ឬក្រុមនានា ជនអន្តោរប្រវេសន៍ និងក្រុមក្នុងមូលដ្ឋាន។ល។)។

- **ជាទូទៅ ព័ត៌មានជាក់លាក់ស្តីពីវិសមភាពយេនឌ័រ ការរើសអើង ឬអំពើហិង្សាផ្អែកលើយេនឌ័រ** ត្រូវបានផ្តល់ដោយអង្គការដែលធ្វើការក្នុងវិស័យនេះ ឬអាជ្ញាធរដែលមានអាណត្តិយេនឌ័រជាក់លាក់ ដូចជា នាយកដ្ឋានរបស់ក្រសួងកិច្ចការនារី និងគណៈកម្មាធិការឃុំទទួលបន្ទុកកិច្ចការនារី និងកុមារ។ល។)។

- **ក្រុម ឬបុគ្គលមួយចំនួនអាចត្រូវបានកំណត់អត្តសញ្ញាណតែក្នុងពេលចុះប្រមូលទិន្នន័យតែប៉ុណ្ណោះ** តាមរយៈការសង្កេតផ្ទាល់ ឬដោយមានជំនួយពីអ្នកផ្តល់ព័ត៌មាន។ ការសង្កេតផ្ទាល់នៅកម្រិតសហគមន៍គឺជាវិធីសាស្ត្រប្រកបដោយអត្ថន័យ ព្រោះវាជួយឱ្យយើងយល់ពីការផាត់ចេញដោយសារកត្តាភូមិសាស្ត្រ (ចម្ងាយពីផ្លូវ សេវា។ល។) ទទួលបានការយល់ដឹងដំបូងអំពីភាពខុសគ្នាផ្នែកសង្គមសេដ្ឋកិច្ច (លំនៅដ្ឋាន ចំនួនសត្វពាហនៈ លទ្ធភាពទទួលបាន ទឹក អគ្គិសនី និងបង្គន់ ចម្ងាយពីសេវា។ល។) និងភាពខុសគ្នារវាងក្រុមផ្សេងៗ (ជនចំណាកស្រុក ជនជាតិភាគតិច។ល។)។

# ៤.៥. ការគ្រោងដំណើរការប្រមូលទិន្នន័យ

វិធីសាស្ត្រស្រាវជ្រាវបែបគុណភាពប្រើប្រាស់វិធីសាស្ត្រចម្រុះក្នុងការប្រមូលព័ត៌មាន។ ការស្រាវជ្រាវ សមភាពយេនឌ័រ និងសង្គមបរិយាបន្នដែលផ្តោតលើការស្វែងយល់ពីមូលហេតុ ឧបសគ្គ បទដ្ឋាន និងកត្តាផ្សេងទៀតដែលរួមចំណែកបង្កជាវិសមភាពយេនឌ័រ និងការផាត់ចេញពីសង្គម នឹងផ្អែកលើបទសម្ភាសន៍ស៊ីជម្រៅ ឬបទសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ កិច្ចពិភាក្សាក្រុមគោលដៅ (FGDs) សកម្មភាពដែលចូលរួមដោយសហគមន៍ ការប្រមូលរឿងរ៉ាវ ករណីសិក្សា។ល។ សកម្មភាពទាំងអស់នេះគួរផ្តោតលើយេនឌ័រដើម្បីឱ្យស្ត្រី និងបុរសមានសុវត្ថិភាពក្នុងការចូលរួម ដោយរាប់ទាំងសកម្មភាពដែលពាក់ព័ន្ធនឹងក្រុមដែលបាត់បង់ឱកាស។ **ដូច្នេះ ចាំបាច់ត្រូវប្រមូលព័ត៌មានដាច់ដោយឡែកតាមក្រុមស្ត្រី និងក្រុមបុរសក្នុងដំណើរការស្រាវជ្រាវ។ ខាងក្រោមនេះគឺជាជំហានសំខាន់ៗសម្រាប់គម្រោងការប្រមូលទិន្នន័យ ៖**

- **ព្រាងបញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មាន/អ្នកពាក់ព័ន្ធសំខាន់ៗ ដែលត្រូវបានជ្រើសរើសសម្រាប់ការសម្ភាសន៍បុគ្គល**
- **ព្រាងបញ្ជីឈ្មោះក្រុមស្ត្រី និងបុរសដែលត្រូវដាក់បញ្ចូលក្នុងកិច្ចពិភាក្សាក្រុមគោលដៅ** និងលក្ខណៈវិនិច្ឆ័យជាក់លាក់ដែលត្រូវដាក់បញ្ចូល ដូចជា ស្ត្រីមេគ្រួសារ ក្រុមអាយុផ្សេងៗ ក្រុមជាតិពន្ធុផ្សេងៗ កម្រិតនៃភាពក្រីក្រ។ល។
- **ផែនការសម្រាប់ការសម្ភាសន៍បុគ្គលដែលបាត់បង់ឱកាស** ដែលមិនអាចចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅ (អ្នកផ្ទុកមេរោគអេដស៍ អ្នកមានពិការភាព ក្រុម LGBTI ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី។ល។)
- **ផែនការសម្រាប់សកម្មភាពសហគមន៍** (ការប៉ាន់ប្រមាណតំបន់ជនបទបែបចូលរួម (PRA) ការគូសផែនទី បទបង្ហាញលទ្ធផល និងកិច្ចប្រជុំផ្តល់សុពលភាពជាមួយក្រុមស្ត្រី និងបុរស)។

***គួរកត់សម្គាល់ថា ការសម្ភាសន៍គ្រួសារដែលមិនញែកស្ត្រី និងបុរស មនុស្សចាស់ និងយុវជន មិនអាចច្បាមយកបញ្ហាសមភាពយេនឌ័រ ឬទម្រង់ផ្សេងទៀតនៃការផាត់ចេញបានឡើយ។***

# ៤.៦. ការរៀបចំឧបករណ៍ស្រាវជ្រាវ

ការស្រាវជ្រាវពីសមភាពយេនឌ័រ និងបរិយាបន្នសង្គម ផ្អែកលើការវិភាគយេនឌ័រ និងក្របខណ្ឌនៃការវិភាគ។ វិធីសាស្ត្រនៃការវិភាគយេនឌ័រពិនិត្យមើល ៖

- **តួនាទីយេនឌ័រ និងការបែងចែកការងារ ៖** នរណាត្រូវធ្វើកិច្ចការអ្វីក្នុងផ្នែកដែលមានផលិតភាព (ការងារ មុខរបរ សកម្មភាពដែលមានផលិតភាព) ឬក្នុងផ្នែកបន្តពូជ (ការងារថែទាំ កិច្ចការផ្ទះ ការចម្អិន។ល។)
- **លទ្ធភាពទទួលបាន ការគ្រប់គ្រង និងការកាន់កាប់ធនធាន៖** នរណាត្រូវធ្វើកិច្ចការអ្វី អាចជាធនធានរូបី ដូចជា ដីធ្លី ឧបករណ៍ ជាតុចូល មូលធន ។ល។ ឬពេលវេលា ការអប់រំ ការបង្កើតបណ្តាញ និងការប្រឡូកក្នុងសកម្មភាពសង្គម។
- **អំណាចធ្វើសេចក្តីសម្រេចចិត្ត ៖** នរណាសម្រេចចិត្ត និងសម្រេចចិត្តពីអ្វី អាចក្នុងគ្រួសារ ឬនៅកម្រិតសហគមន៍ ឬកម្រិតផ្សេងទៀត។
- **បទដ្ឋាន គុណតម្លៃ និងជំនឿដែលជះឥទ្ធិពលលើទិដ្ឋភាពទាំងនេះ និងការប្រែប្រួលតាមពេលវេលា។**

*ក្នុងសមភាពយេនឌ័រ និងសង្គមបរិយាបន្ន ផ្នែកទាំងនេះមិនត្រឹមតែត្រូវបានវិភាគក្នុងចំណោមស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានវិភាគក្នុងចំណោមក្រុមរងផ្សេងៗដែលពាក់ព័ន្ធក្នុង a( ឧ. ជនក្រីក្របំផុត ជនជាតិភាគតិច មនុស្សចាស់ យុវជន អ្នកមានពិការភាព។ល។)។*

# បញ្ជីត្រួតពិនិត្យការវិភាគយេនឌ័រ

ខាងក្រោមនេះជាឧទាហរណ៍ទូទៅមួយនៃបញ្ជីត្រួតពិនិត្យការវិភាគយេនឌ័រ ដែលអាចកែសម្រួលទៅតាមបរិបទ និងក្រុមផ្សេងៗបាន។

## ការបែងចែកការងារ

### ការងារចិញ្ចឹមជីវិត

- [x] តើសកម្មភាពចិញ្ចឹមជីវិតសំខាន់ៗមានអ្វីខ្លះ?
- [ ] តើបុរស និងស្ត្រីសុទ្ធតែសកម្មក្នុងវិស័យនេះ ឬទេ?
- [ ] តើស្ត្រី និងបុរសធ្វើកិច្ចការអ្វីខ្លះ?
- [ ] តើមានភារៈកិច្ចដែលត្រូវបានចែករំលែករវាងបុរស និងស្ត្រី ឬសម្រាប់តែក្រុមមួយ ដែរឬទេ?
- [ ] ផ្អែកតាមវប្បធម៌តើបុរស ឬស្ត្រីដែលមិនត្រូវបានអនុញ្ញាតអោយចូលរួមធ្វើ កិច្ចការណាមួយ? តើហេតុអ្វី? (បទដ្ឋាន។ល។)
- [ ] តើតួនាទីទាំងនេះអាចបត់បែនបានដែរឬទេបើសិនមានករណីជួបការលំបាក ឬគ្រោះអាសន្ននានា?
- [ ] តើស្ត្រី ឬបុរសត្រួតត្រាគ្នាដែរឬទេ ប្រសិនបើមុខរបរចិញ្ចិមជីវិតផ្តល់ប្រាក់ចំណេញកាន់តែច្រើន?
- [ ] តើមានការប្រែប្រួលលើការបែងចែកការងារតាមយេនឌ័រ ឬទេ? ហេតុអ្វី?
- [ ] តើស្ត្រី និងបុរសមានជំនាញ ឯកទេស និងចំណេះដឹងសំខាន់ៗអ្វីខ្លះ?

### ការងារផ្ទះ

- [ ] តើនរណាធ្វើកិច្ចការផ្ទះ (មើលថែសមាជិកគ្រួសារ មើលកូន មើលថែសាច់ញាតិ/អ្នករស់នៅក្នុងបន្ទុក រកអាហារ ដើរផ្សារ រៀបចំអាហារ និងចម្អិន រកអុស/ធ្យូង/ថាមពល និងទឹក អប់រំ ថែទាំសុខភាព បោកគក់ និងសម្អាត ជួសជុលថែទាំផ្ទះ។ល។)?
- [ ] តើតួនាទីទាំងនេះមានភាពបត់បែនក្នុងករណីជួបការលំបាក ដែរឬទេ?
- [ ] តើសកម្មភាពទាំងនេះចំណាយពេលយូរប៉ុណ្ណា?
- [ ] តើមានការប្រែប្រួលលើសកម្មភាពទាំងនេះដែរឬទេ ដែលធ្វើឱ្យពួកគេកាន់តែងាយស្រួល ឬកាន់តែលំបាក?

### ការងារសហគមន៍

- [ ] តើស្ត្រី និងបុរសធ្វើការងារសម្រាប់សហគមន៍មូលដ្ឋាន (ការថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ដូចជា បរិក្ខារផ្គត់ផ្គង់ទឹក កន្លែងប្រជុំ និងទីគោរពបូជា) ដែរឬទេ?
- [ ] តើការងារទាំងនេះចំណាយពេលយូរប៉ុណ្ណា? បញ្ចប់នៅពេលណា?
- [ ] តើតួនាទីទាំងនេះមានភាពបត់បែនទេ?
- [ ] តើមានការប្រែប្រួលលើសកម្មភាពទាំងនេះ ឬទេ?

## លទ្ធភាពទទួលបាន ការគ្រប់គ្រង និងការកាន់កាប់ធនធាន

- ☐ តើស្ត្រី និងបុរសកាន់កាប់ ឬមានលទ្ធភាពទទួលបាន និងគ្រប់គ្រងដីធ្លី មូលធន បរិក្ខារ ឥណទាន ការអប់រំ ទីផ្សារ ពេលវេលា បណ្តាញ ទំនាក់ទំនងក្នុងកម្រិតណា? ហេតុអ្វី?
- ☐ តើមានឧបសគ្គ និងផលវិបាកអ្វីខ្លះបណ្តាលមកពីកង្វះការគ្រប់គ្រង ឬលទ្ធភាពទទួលបានធនធានដែលមានផលិតភាព?
- ☐ តើបុរស និងស្ត្រី ខុសគ្នាដូចម្តេចនៅពេលប្រឈមនឹងឧបសគ្គ? តើភាពខុសគ្នាទាំងនេះប៉ះពាល់ដូចម្តេចដល់ការងារ ផលិតភាព និងលទ្ធភាពទទួលបានអត្ថប្រយោជន៍របស់ពួកគេ?
- ☐ តើស្ត្រី និងបុរសមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានប្រាក់ចំណូល អត្ថប្រយោជន៍ គ្រឿងលើកទឹកចិត្ត ប្រាក់ឈ្នួល ឬទេ? ប្រសិនបើមិនមាន ហេតុអ្វី?
- ☐ តើស្ត្រី និងបុរសមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការថែទាំសុខភាព ទឹក និងអនាម័យ ការបណ្តុះបណ្តាល និងការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំមនុស្សពេញវ័យ ឬទេ? ប្រសិនបើមិនមាន ហេតុអ្វី?
- ☐ តើស្ត្រី និងបុរសទទួលបានឋានៈ និងការគោរពពីសកម្មភាពរបស់ខ្លួន ឬទេ? ហេតុអ្វី?
- ☐ តើបទដ្ឋានវប្បធម៌អ្វីខ្លះដែលរារាំងលទ្ធភាពទទួលបាន ការគ្រប់គ្រង និងការកាន់កាប់ធនធាន (ពិចារណាផ្អែកតាមបរិបទវប្បធម៌ដែលធ្វើអោយមានការផាត់ចេញ ពីសកម្មភាពចិញ្ចឹមជីវិត ការចូលរួមក្នុងការងារផ្ទះ កង្វះពេលវេលា កង្វះចល័តភាព ការផាត់ចេញពីសកម្មភាពសាធារណៈ បទប្បញ្ញត្តិច្បាប់។ល។)?
- ☐ តើមានការប្រែប្រួលលើលទ្ធភាពរបស់ស្ត្រី និងបុរសក្នុងការទទួលបាន កាន់កាប់ និងគ្រប់គ្រងធនធាន ឬទេ? ហេតុអ្វី?

## អំណាចធ្វើសេចក្តីសម្រេចចិត្ត

- ☐ តើស្ត្រី និងបុរសធ្វើសេចក្តីសម្រេចចិត្តក្នុងគ្រួសារដោយរបៀបណា?
- ☐ តើដំណើរការធ្វើសេចក្តីសម្រេចចិត្តក្នុងគ្រួសាររួមចំណែកដល់វិសមភាពយេនឌ័រ ឬទេ?ដោយរបៀបណា?
- ☐ តើមានការប្រែប្រួលលើអំណាចធ្វើសេចក្តីសម្រេចចិត្តក្នុងគ្រួសារ ឬទេ? ហេតុអ្វី?
- ☐ តើមានប្រភេទអង្គការសមូហភាពអ្វីខ្លះ (អង្គការសង្គមវប្បធម៌បែបប្រពៃណី ក្រុមអ្នកផលិត ដូចជាសហករណ៍ ក្រុមសន្សំ និងក្រុមឥណទាន អង្គការតាមសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលសហជីព។ល។) ក្នុងវិស័យដែលប្រឈមនឹងហានិភ័យ?
- ☐ តើអង្គការសហគមន៍ទាំងនេះមានសាវតាសមាជិកភាពដូចម្តេច? តើស្ត្រី និងបុរស ឬក្រុមផ្សេងទៀតមានលទ្ធភាពស្មើភាពក្នុងការចូលជាសមាជិក ឬទេ? ប្រសិនបើទេ ហេតុអ្វី?
- ☐ តើស្ត្រី និងបុរសមានតំណាងស្មើភាព (ចំនួន) ក្នុងអង្គការទាំងនេះ ឬទេ? ប្រសិនបើទេ ហេតុអ្វី?
- ☐ តើក្រុមផ្សេងទៀតមានតំណាងស្មើភាព (ចំនួន) ក្នុងអង្គការទាំងនេះ ឬទេ? ប្រសិនបើទេ ហេតុអ្វី?

- ☐ តើមានឧបសគ្គអ្វីខ្លះដែលរារាំងស្ត្រី បុរស និងក្រុមផ្សេងទៀតមិនឱ្យចូលរួមក្នុងសកម្មភាពអង្គការសហគមន៍ កិច្ចប្រជុំ? ហេតុអ្វី?
- ☐ តើស្ត្រី បុរស និងក្រុមផ្សេងទៀតទទួលបានព័ត៌មានស្មើគ្នាពីសកម្មភាពសហគមន៍ ឬទេ? ប្រសិនបើទេ ហេតុអ្វី?
- ☐ តើស្ត្រី បុរស និងក្រុមផ្សេងទៀត មានលទ្ធភាពស្មើភាពក្នុងការទទួលបានតួនាទីគ្រប់គ្រងក្នុងអង្គការទាំងនេះ ឬទេ? ប្រសិនបើទេ ហេតុអ្វី?
- ☐ តើស្ត្រី បុរស និងក្រុមផ្សេងទៀតមានភាពសកម្មដូចគ្នាក្នុងការកំណត់របៀបវារៈ ការដាក់សំណើ ការជ្រើសរើសអាទិភាព ការរៀបចំសកម្មភាព ការសម្រេចចិត្តពីការប្រើប្រាស់មូលនិធិ ឬការវិនិយោគ ឬទេ?
- ☐ តើមានអង្គការស្ត្រីក្នុងសហគមន៍ ឬទេ? អង្គការអ្វីខ្លះ?
- ☐ តើមានអង្គការដែលប្រមូលផ្តុំក្រុមជាក់លាក់ (មនុស្សចាស់ ជនពិការ ជនជាតិភាគតិច។ល។) ឬទេ?
- ☐ តើមានអ្នកដឹកនាំជាស្ត្រីក្នុងសហគមន៍ ឬទេ? ជាសមាជិកក្រុមនៃប្រធានក្រុមផ្សេងទៀត?
- ☐ តើមានការប្រែប្រួលលើការចូលរួមរបស់ស្ត្រី បុរស និងក្រុមផ្សេងទៀតក្នុងរចនាសម្ព័ន្ធសម្ហូហភាព ឬទេ? តើការប្រែប្រួលទាំងនេះបង្កផលវិបាកអ្វីខ្លះ?

## អនុសាសន៍

- ☐ តើគេអាចបង្កើតការផ្លាស់ប្តូរជាវិជ្ជមានដោយរបៀបណា?
- ☐ តើគេត្រូវការអ្វីខ្លះដើម្បីកែលម្អស្ថានភាពរបស់ស្ត្រី បុរស?
- ☐ តើស្ត្រី និង/ឬបុរសបានចាត់វិធានការដើម្បីកែប្រែស្ថានភាពនេះ ឬទេ? ដោយរបៀបណា?
- ☐ តើត្រូវធ្វើអ្វីផ្សេងទៀត?
- ☐ តើគួរផ្តល់ការគាំទ្រពីខាងក្រៅអ្វីខ្លះ?

# ៤.៧. ដំណើរការប្រមូលទិន្នន័យ

គេមិនងាយនឹងប្រមូលបានចម្លើយសម្រាប់សំណួរទាំងអស់នេះក្នុងកិច្ចពិភាក្សាក្រុមគោលដៅ ឬការសម្ភាសឡើយ។ អ្នកស្រាវជ្រាវគួរប្រើប្រាស់បញ្ជីត្រួតពិនិត្យនេះប្រកបដោយយុទ្ធសាស្ត្រ មិនមែនចេះតែប្រើឱ្យតែបានៗនោះទេ។ ចំណុចសំខាន់គឺមិនមែនបំពេញបញ្ជីនេះទេ ប៉ុន្តែត្រូវកំណត់រកបញ្ហាសំខាន់ៗ។

បញ្ជីត្រួតពិនិត្យការវិភាគយេនឌ័រ គួរត្រូវបានដាក់បញ្ចូលគ្នាដោយចាប់ផ្តើមពីវិស័យជាក់លាក់ដែលជាចំណុចផ្តោតនៃការស្រាវជ្រាវ។ អ្នកស្រាវជ្រាវគួរមានជំនាញលើវិស័យនោះ ដើម្បីព្រាងសំណួរដែលពាក់ព័ន្ធ និងត្រូវបានកែសម្រួល។

*ឧ. ការស្រាវជ្រាវពីកសិកម្មនឹងពិចារណាពីកិច្ចការកសិកម្មទាំងអស់ក្នុងការបែងចែកការងារ និងទ្រព្យសម្បត្តិជាក់លាក់ដើម្បីវាយតម្លៃលទ្ធភាពទទួលបានធនធាន។ ការស្រាវជ្រាវពីលទ្ធភាពទទួលបានសេវាសុខភាពនឹងផ្តោតបន្ថែមទៀតលើការធ្វើសេចក្តីសម្រេចចិត្ត និងចល័តភាព។ល។*

ការសួរថា ***"ហេតុអ្វី?"*** នឹងជួយដល់ការស្វែងយល់ពីបទដ្ឋានដែលជះឥទ្ធិពលលើការបែងចែកការងារ លទ្ធភាពទទួលបានធនធាន អំណាចធ្វើសេចក្តីសម្រេចចិត្ត និងការចូលរួម។

# ការចរចាពេលវេលា និងទីតាំងសមស្របសម្រាប់ការពិភាក្សា និងការសម្ភាសន៍ជាកិច្ចការចាំបាច់ក្នុងការស្រាវជ្រាវសមភាពយេនឌ័រ និងសង្គមបរិយាបន្នៈ

## ការគាំទ្រការចូលរួម

ពិចារណាពីកង្វះពេលទំនេររបស់ស្ត្រី និងឧបសគ្គផ្សេងទៀត (ការចម្អិន មើលកូន។ល។)។ ពេលខ្លះ ប្រហែលជាត្រូវរៀបចំការថែទាំកុមារក្នុងពេលប្រជុំជាមួយស្ត្រីដើម្បីអាចឱ្យស្ត្រីចូលរួមបាន

## ការប្រើប្រាស់ដោយបរិយាបន្ន

ពិចារណាពីតម្រូវការរបស់មនុស្សចាស់ និងអ្នកដែលជួបបញ្ហាក្នុងការបំលាស់ទី

## ការផ្តល់អំណាចដល់ការចូលរួម

ធានាថា ស្ត្រី និងក្រុមរងយល់ថាពួកគេត្រូវបានលើកទឹកចិត្តអោយនិយាយ (ពិចារណាពីការរក្សាការសម្ងាត់ សម្ពាធពីអ្នកមានអំណាច ឬស្វាមីជាពិសេសក្នុងពេលជ្រើសរើសទីតាំង)

## ចូលរួមដោយក្រុមចម្រុះ

រៀបចំជាក្រុមដោយឡែកៗ ដូចជា ជនក្រីក្របំផុត មនុស្សចាស់ យុវជន អ្នកគ្មានដីធ្លី ជាតិពន្ធុផ្សេងៗ។ល។

## ការអនុវត្តរក្សាការសម្ងាត់របស់អ្នកចូលរួម

សម្រាប់ជនមានពិការភាព អ្នកផ្ទុកមេរោគអេដស៍ និងជនរងគ្រោះដោយសារអំពើហិង្សា សូមធ្វើសម្ភាសន៍បុគ្គល និងធានាការការពារ និងការរក្សាការសម្ងាត់ (វិធីសាស្ត្រធ្វើសំណាកដែលមានឈ្មោះថាSnowball ៖ ដំបូង សួរអ្នកផ្តល់បទសម្ភាសន៍ថាតើពួកគេស្គាល់អ្នកផ្សេងទៀតដែលប្រឈមនឹងបញ្ហាស្រដៀងគ្នាដែលនឹងយល់ព្រមឱ្យសម្ភាស និងបន្តតាមរបៀបនេះ ឬទេ)

## ការប៉ះប៉ូវប្រកបដោយសីលធម៌

ពិចារណាពីការប៉ះប៉ូវនៅពេលធ្វើការជាមួយក្រុម ឬជនក្រីក្របំផុត ឬក្រុម/ជនដែលបាត់បង់ឱកាស។ ការប៉ះប៉ូវអាចឱ្យអ្នកដែលពឹងផ្អែកលើប្រាក់ចំណូលប្រចាំថ្ងៃ ចូលរួមក្នុងសកម្មភាពស្រាវជ្រាវបាន (ឧ. ពលករ អ្នកសុំទាន។ល។) ឬពិចារណាពីការប៉ះប៉ូវជាសម្ភារៈ (អាហារ បាយថ្ងៃត្រង់ សម្ភារៈមានប្រយោជន៍ផ្សេងទៀត)។

# ៤.៨. ដំណើរការសម្ភាស និងពិភាក្សា

ការធ្វើបទសម្ភាសន៍ និងកិច្ចពិភាក្សាក្រុមគោលដៅ គឺជាសិល្បៈ និងទាមទារនូវជំនាញ និងភាពប៉ិនប្រសប់។ ទាំងការសម្ភាសន៍ និងកិច្ចពិភាក្សាក្រុមគោលដៅ សុទ្ធតែត្រូវគ្រោងឡើងតាមរយៈការប្រមូលព័ត៌មានសាវតា ការសម្រេចពីរបៀបចាប់ផ្ដើម ការជ្រើសរើសសំណួរដែលជំរុញការចូលរួមច្រើនបំផុត និងការបង្កើតកម្រងសំណួរ។ ការសម្ភាសដោយសួរសំណួរទម្រង់បើក និងការសម្ភាសពាក់កណ្ដាលរចនាសម្ព័ន្ធ និងកិច្ចពិភាក្សាក្រុម មិនគួរធ្វើឡើងដោយគ្រាន់តែអនុវត្តតាមកម្រងសំណួរនោះទេព្រោះវាជាការរំលឹកជាជាងការណែនាំជាជំហានៗ។ក្នុងការស្រាវជ្រាវបែបគុណភាពការសម្ភាស និងកិច្ចពិភាក្សាមានទម្រង់ជាកិច្ចសន្ទនា ជាជាងវគ្គសំណួរ/ចម្លើយ។

**ខាងក្រោមនេះជាគន្លឹះ និងការលើកឡើងមួយចំនួនដែលគួរចងចាំ ៖**

| | |
|---|---|
| **ការយល់ព្រមដោយសេរីជាមុន** | ទំនាក់ទំនងដំបូង និងការណែនាំខ្លួនពិតជាសំខាន់ណាស់ និងអាចជះឥទ្ធិពលលើដំណើរការទាំងមូល។ សូមប្រើប្រាស់ភាសាសាមញ្ញ និងច្បាស់ៗ មិនមែនពាក្យច្ចេកទេស ឬពាក្យសាំញ៉ាំឡើយ។ ប្រសិនបើគ្មានការចរចាជាមុនទេនោះ សូមខិតខំទទួលបានការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ និងផ្ដល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការពន្យល់សំនួរ និងយោបល់ត្រឡប់។ |
| **ការផ្ដល់ការទុកចិត្តជាអាទិភាព** | រៀបចំសំណួរទម្រង់បើកមួយចំនួន ដូចជា "តើការប្រមូលផលយ៉ាងម៉េចហើយ ?" "តើសុខភាពល្អជាទេ ?" សំណួរទាំងនេះមិនត្រឹមតែអាចជួយ ដំណើរការចាប់ផ្ដើមមានភាពរលូន ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យអ្នកចូលរួមយល់ថា អ្នកស្រាវជ្រាវរង់ចាំស្ដាប់ពួកគេទៀតផង មិនមែនត្រឹមតែច្បាមយកព័ត៌មានមួយចំនួនពីពួកគេឡើយ។ |
| **ការស្ដាប់ដោយភាពបត់បែន** | ទទួលយកការឆ្លើយរបស់អ្នកចូលរួមដែលឆ្លើយមិនចំនឹងសំណួរ ដែលកំណត់ទុកជាមុន។ គោលបំណងគឺមិនមែនដើម្បីបំពេញកម្រងសំណួររបស់អ្នកទេប៉ុន្តែគឺដើម្បីទទួលបានយោបល់ត្រឡប់ និងយល់ពីបញ្ហារបស់ពួកគេ! ការប្រញាប់សួរបញ្ចប់សំណួរ នឹងធ្វើឱ្យបាត់បង់ការចូលរួម និងអន្តរកម្ម។ |
| **ការសម្របសម្រួលអន្តរកម្មជាក្រុម** | ការសង្កេតមើលបម្រែបម្រួល ក្រុមគឺជាផ្នែកមួយនៃការប្រមូលទិន្នន័យ។ ការមិនចុះសម្រុងអាចលេចឡើងក្នុងក្រុម និង ទាមទារអោយមានជំនាញសម្របសម្រួលដ៏ប៉ិនប្រសប់ដើម្បីស្វែងរកបញ្ហា។ ពេលខ្លះ គួរធ្វើ សម្ភាសន៍បុគ្គលដើម្បីទទួលបានការយល់ដឹងកាន់តែច្រើន។ |
| **ការប្រើឧទាហរណ៍បំផុសគំនិត** | ប្រើឧទាហរណ៍ និងការប្រៀបធៀបដើម្បីបំផុសការពិភាក្សា ("ក្នុងភូមិ គ្រួសារ ក្រុម.....ដែលនៅជុំវិញមានគេប្រាប់ថា..." ) |

| | |
|---|---|
| **ការស្វែងយល់ទស្សនៈផ្សេងៗ** | សំណួរស្តីពី "តើមានការប្រែប្រួលអ្វីខ្លះ.... ?" អាចឱ្យអ្នកចូលរួមបង្ហាញទស្សនៈរបស់ខ្លួន ហើយវាក៏មានប្រយោជន៍នៅពេលចាប់ផ្តើម។ |
| **ការស្វែងយល់បញ្ហាប្រឈម** | សួរថាតើជីវិតរស់នៅមានភាពងាយស្រួល ឬលំបាកជាងមុន ( ការងារច្រើនពេក មិនសូវមានធនធាន មិនសូវមានលទ្ធភាពទទួលបាន ឧបសគ្គច្រើនជាងមុន ) និងមូលហេតុ។ |
| **ផ្តល់គំនិតដែលចង់ដឹងមូលហេតុ** | ប្រកាន់ផ្នត់គំនិតចង់ដឹងមូលហេតុ មិនមែនមកផ្ទៀងផ្ទាត់។ សូមចាំថា ពួកគេជាអ្នកជំនាញដែលដឹងច្បាស់ពីស្ថានភាពផ្ទាល់ខ្លួន។ សូមដាក់ខ្លួន និងបើកចិត្តទទួលយកការរៀនសូត្រពីអ្នកចូលរួម។ |
| **ការស្តាប់ដោយការគោរព** | ពិចារណាថា ជាញឹកញាប់ ស្ត្រី និងក្រុមដែលបាត់បង់ឱកាសអាចមានភាពលម្អៀង និងបុរេនិច្ឆ័យក្នុងផ្នត់គំនិតរបស់ខ្លួន មិនមានទំនុកចិត្ត និងមិនឱ្យតម្លៃអ្វីដែលពួកគេធ្វើ និងអ្វីដែលពួកគេដឹង។ |
| **ការផ្តល់អំណាចដល់ការចូលរួម** | លើកទឹកចិត្តអ្នកចូលរួម និងឱ្យតម្លៃជំនាញ ចំណេះដឹង និងការសង្កេតរបស់ពួកគេ ។ |
| **ការគោរពលើការបញ្ចេញអារម្មណ៍** | បង្ហាញសមានចិត្ត! អ្នកចូលរួមប្រហែលជាធ្លាប់ឆ្លងកាត់បទពិសោធន៍អវិជ្ជមាន និងឈឺចាប់ដែល ពួកគេពិបាករំលឹកឡើង និងពន្យល់។ |
| **ការទទួលស្គាល់ភាពក្លាហាន** | ផ្តល់ការសាទរទៅលើសមិទ្ធផលដែលគេសម្រេចបាន និងភាពធន់របស់ពួកគេ៖ "អ្នកក្លាហានណាស់ដែលអាចជម្នះបញ្ហានេះបាន...។ តើអ្នកអាចបន្តដំណើរជីវិតនៅចំពោះមុខបញ្ហានោះដោយរបៀបណា ?" |
| **ប្រមូលផ្តុំទស្សនៈផ្សេងៗ** | ប្រមូលអនុសាសន៍ និងទស្សនៈស្តីពីការផ្លាស់ប្តូរជាវិជ្ជមាន។ |
| **ការបញ្ចប់ដោយភាពវិជ្ជមាន** | កុំបញ្ចប់កិច្ចពិភាក្សាដោយបន្សល់នូវបញ្ហាដែលធ្វើឱ្យមានអារម្មណ៍ក្រៀមក្រំ និងបង្កជាវិបត្តិ។ រៀបចំសំណួរងាយៗ និងស្រាលៗមួយចំនួនសម្រាប់ពេលបញ្ចប់ និងកុំទុកឱ្យក្រុម ឬបុគ្គលណាម្នាក់មានអារម្មណ៍ក្រៀមក្រំ ឬបាក់ទឹកចិត្ត។ |
| **ការគោរពពេលវេលា** | កុំឃាត់ឱ្យអ្នកចូលរួមបន្តមានវត្តមានក្នុងកិច្ចប្រជុំលើសពីពេលវេលាដែលបានចរចាគ្នា។ ប្រសិនបើអ្នកស្រាវជ្រាវយល់ថា លទ្ធផលមិនគ្រប់គ្រាន់ សូមចរចាពីជំនួប ឬការសម្ភាសន៍បុគ្គលមួយផ្សេងទៀត។ |

# ៤.៩. អំពីការបកប្រែ

ប្រសិនបើអ្នកធ្វើការជាមួយក្រុមជនជាតិដើមភាគតិច អ្នកត្រូវធ្វើបទសម្ភាសន៍ និងកិច្ចពិភាក្សាជាភាសារបស់ពួកគេ!

- ភាសាជនជាតិដើមភាគតិចគ្មានក្បួនខ្នាតទេប៉ុន្តែពួកគេចេះភាសានោះច្បាស់ និងជាញឹកញាប់ អាចនិយាយភាសាជនជាតិដើមភាគតិចលើសពី ១។

    ***កុំវិនិច្ឆ័យអត្តភាពរបស់ពួកគេ!***

- កុំទុកចិត្តអ្វីដែលអ្នកផ្តល់ព័ត៌មានបាននិយាយ ទៅលើភាពស្ទាត់ជំនាញផ្នែកភាសាផ្លូវការរបស់ជនជាតិដើមភាគតិច។

    ***ជាញឹកញាប់ ស្ត្រី ឬមនុស្សចាស់មិនចេះនិយាយស្ទាត់ទេ។***

- ជ្រើសរើសអ្នកបកប្រែលើសពីម្នាក់ និងសាកល្បងពួកគេ។ កុំស្ទាក់ស្ទើរក្នុងការផ្លាស់ប្តូរអ្នកបកប្រែប្រសិនបើចាំបាច់។

    ***ជាញឹកញាប់ លទ្ធផលរបស់អ្នកផ្អែកលើគុណភាពនៃការបកប្រែ។***

- ពន្យល់ឱ្យបានច្បាស់ដល់អ្នកបកប្រែពីគោលបំណងនៃការស្រាវជ្រាវ និងភាពចាំបាច់ក្នុងការយល់ដឹងស៊ីជម្រៅពី

    ***អ្វីដែលមនុស្សនិយាយដោយមិនបង្អាក់ពួកគេ ឬសង្ខេបសំដីរបស់ពួកគេ។***

- ពិនិត្យរកភាពលម្អៀងរបស់អ្នកបកប្រែ (អ្នកបកប្រែដែលមានការយល់ដឹងអាចមានបុរេនិច្ឆ័យលើបែបផែនជីវិតប្រពៃណី។

    ***អ្នកបកប្រែភេទប្រុសអាចមិនយល់ច្បាស់ ឬមិនឱ្យតម្លៃទស្សនៈ និងចំណេះដឹងរបស់ស្ត្រី។ល។)។***

# ៤.១០. អំពីការថតសំឡេងបទសម្ភាសន៍ និងកិច្ចពិភាក្សាក្រុមគោលដៅ

ការថតសំឡេងផ្តល់គុណសម្បត្តិ និងគុណវិបត្តិមួយចំនួន ៖

## គុណសម្បត្តិ

- អនុញ្ញាតឱ្យមានការថតសំឡេងនូវរាល់ពាក្យពេចន៍ដែលគេនិយាយ
- ប្រតិចារិកដែលបានកត់ត្រាទុកអាចបង្កើនស្តង់ដារគុណភាព

## គុណវិបត្តិ

- ត្រូវចរចាជាមួយអ្នកចូលរួម និងប្រហែលជាធ្វើឱ្យអ្នកចូលរួមមានអារម្មណ៍មិនកក់ក្តៅ
- ការធ្វើប្រតិចារិកខ្សែអាត់សំឡេង (transcribe)ត្រូវចំណាយពេលយូរ
- អ្នកស្រាវជ្រាវអាចនឹងទុកចិត្តម៉ាស៊ីនថតសំឡេងខ្លាំងពេក។នេះជាហានិភ័យ ព្រោះនៅតាមមូលដ្ឋានអាចមានកត្តាជាច្រើនដំណើរការមិនរលូន។ ១. ក្រុមប្រហែលជាមិនថតសំឡេងបានត្រឹមត្រូវ។ ក្នុងកិច្ចពិភាក្សា ក្រុមអាចនឹងភ្លេចពិនិត្យថាតើម៉ាស៊ីនថតសំឡេងដំណើរការឬទេ។ ក្នុងករណីជាច្រើន សំឡេងរំខានជុំវិញកន្លែងប្រជុំ (កុមារលេងឆ្កែព្រុស សំឡេងមាន់ គ្រឿងម៉ាស៊ីន ដូចជា ម៉ាស៊ីនកិនស្រូវ ម៉ាស៊ីនបូមទឹក។ល។) រំខានដល់ការថតសំឡេង ម៉ាស៊ីនថតសំឡេងឆាប់អស់ថ្ម។ល។

***ការថតសំឡេងបំពេញបន្ថែម ប៉ុន្តែមិនជំនួសឱ្យការកត់ត្រាទេ។ ជានិច្ចជាកាល យកល្អគួរកត់ត្រាដើម្បីបញ្ចៀសហានិភ័យដែលខ្សែអាត់សំឡេងដែលមិនសូវច្បាស់។***

# ៤.១១. ចំនួនប៉ុន្មាន ?

ក្នុងការស្រាវជ្រាវបែបបរិមាណ ទំហំសំណាកត្រូវបានកំណត់ទុកជាមុន។ ក្នុងការស្រាវជ្រាវបែបគុណភាព ចំនួននៃកិច្ចពិភាក្សាក្រុមគោលដៅ ឬបទសម្ភាសន៍អាស្រ័យលើការរៀបចំ ប៉ុន្តែអាចមានភាពបត់បែន។ បញ្ហា អាចលេចឡើង ដែលគួរតែទទួលបានការស្រាវជ្រាវបន្ថែម ឬក៏បទសម្ភាសន៍មួយអាចបង្កើតជាសេណារីយ៉ូថ្មីមួយដែល ត្រូវការព័ត៌មានបន្ថែម។

លក្ខណៈវិនិច្ឆ័យគោលសម្រាប់ការប្រមូលទិន្នន័យក្នុងការវិភាគបែបគុណភាព គឺ Saturation។ នៅតែមានការជេញដោលលើទស្សនាទាននៃ Saturation ( Saunders et al., 2018 ) ប៉ុន្តែជារួម ៖

> *នៅពេលទិន្នន័យថ្មីៗលែងផ្តល់ចំណេះដឹងថ្មី គេនឹងសម្រេចបាន saturation ផ្នែកទ្រឹស្តី*
>
> ( Flick et al., 2004, pp. 182-3 )

ចំណុចនេះមានន័យថា នៅចំណុចណាមួយព័ត៌មានដែលប្រមូលបានមានភាពស្រដៀងគ្នា និងច្រំដែល និងលែងមានប្រធានបទ ឬបញ្ហាថ្មីលេចចេញពីកិច្ចពិភាក្សាក្រុមគោលដៅ ឬបទសម្ភាសន៍។

# ៤.១២. ការផ្ទៀងផ្ទាត់លទ្ធផល?

ក្នុងបទសម្ភាសន៍បុគ្គល ឬកិច្ចពិភាក្សា និងសកម្មភាពសមូហភាព ចាំបាច់ត្រូវផ្តល់ការផ្ទៀងផ្ទាត់ លើអ្វីដែលអ្នកស្រាវជ្រាវបានយល់ និងកត់សម្គាល់។ គេអាចសម្រេចចំណុចនេះបានបន្ទាប់ពីសួរសំណួរនីមួយៗ ឬតាមរយៈការសង្ខេបលទ្ធផលនៅពេលបញ្ចប់បទសម្ភាសន៍ ឬកិច្ចពិភាក្សា និងការសួរអ្នកចូលរួមថាតើអ្វីដែលបានកត់ត្រា ត្រឹមត្រូវ ឬទេ។ ដំណើរការនៃការផ្ទៀងផ្ទាត់ អាចផ្តល់ខ្លឹមសារលម្អិតបន្ថែមលើចំណុចដែលខ្វះខាត ដែលអាចឱ្យអ្នកចូលរួមធ្វើការកែតម្រូវ និងបញ្ជាក់បញ្ហា និងបន្ថែមគុណភាពដល់ព័ត៌មានដែលប្រមូលបាន។

***នៅពេលធ្វើការស្រាវជ្រាវជាមួយសហគមន៍ គួររៀបចំកិច្ចប្រជុំដែលក្រុមផ្សេងៗនឹងបង្ហាញពីលទ្ធផលរកឃើញរបស់ពួកគេ។ វាជាដំណើរការដ៏សំខាន់ដែលអាចបង្កើតការយល់ដឹង និងការផ្លាស់ប្តូរ។ ជាញឹកញាប់ នេះជាឱកាសដំបូងសម្រាប់ឱ្យក្រុមដែលបាត់បង់ឱកាស ស្ត្រី ក្រុមក្រីក្រ ជនជាតិដើមភាគតិច។ល។ បង្ហាញខ្លួននិងចែករំលែកកង្វល់របស់ខ្លួន ហើយវាតំណាងឱ្យកត្តាផ្លាស់ប្តូរដ៏សំខាន់មួយសម្រាប់ពួកគេ និងក្រុមគោលដៅ។***

គួរចរចាសកម្មភាពជាមុនជាមួយក្រុមនីមួយៗ។ អ្នកស្រាវជ្រាវគួរពន្យល់ពីដំណើរការនេះ និងទទួលបានការយល់ព្រមពីអ្នកចូលរួម។ យកល្អ គួរផ្តល់ការគាំទ្រដល់តំណាងក្រុមដែលបានជ្រើសរើសដើម្បីបង្ហាញពីលទ្ធផលស្តីពីរបៀបរៀបចំសុន្ទរកថារបស់ពួកគេ (មិនមែនលទ្ធផលស្តីពីខ្លឹមសារទេ!)។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលគឺ អ្នកដែលបានមិនកត់ត្រា អាចចាំដោយងាយនូវសំណួរ និងចម្លើយទាំងអស់ក្នុងកិច្ចពិភាក្សា។

# ៤.១៣. ឯកសារសម្រាប់ការពិភាក្សា និងលំហាត់ជាក្រុម

វគ្គទី ៤ ផ្តោតលើវិធីសាស្ត្រសមភាពយេនឌ័រ និងសង្គមបរិយាបន្នសម្រាប់ការរៀបចំគម្រោង វិធីសាស្ត្រ ដំណើរការប្រមូលទិន្នន័យ។ល។ លំហាត់គ្រប់ជ្រុងជ្រោយមួយត្រូវបានបង្កើតឡើងដើម្បីអនុវត្តផ្នែកផ្សេងៗដែលបានពិភាក្សា។ លំហាត់នេះមានសេណារីយ៉ូមួយ និងករណីសិក្សាពាក់ព័ន្ធ ២ បូករួមនឹងសំណួរជាច្រើនដែលត្រូវឆ្លើយ។

## សេណារីយ៉ូសម្រាប់លំហាត់ករណីសិក្សាស្តីពីសមភាពយេនឌ័រ និងសង្គមបរិយាបន្ន

វិបត្តិកូវីដ ១៩ ទូទាំងពិភពលោកកំពុងបង្កផលប៉ះពាល់យ៉ាងខ្លាំងលើប្រជាជន និងសហគមន៍នៅកម្ពុជា ៖

- មានការថយចុះការងារក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធក្នុងវិស័យឧស្សាហកម្ម និងសេវា ដូចជា វិស័យវាយនភណ្ឌ ទេសចរណ៍ និងបដិសណ្ឋាកិច្ច សំណង់ ឬពាណិជ្ជកម្មខ្នាតតូច ហើយបញ្ហានេះអាចធ្វើឱ្យកម្មករដែលបាត់បង់ការងារគ្មានឱកាសការងារច្បាស់លាស់។
- សហគ្រាសខ្នាតតូច និងមធ្យម នឹងមានទំហំអាជីវកម្មថយចុះ ដែលនឹងប៉ះពាល់ដល់ជីវិតរស់នៅ និងសន្តិសុខស្បៀងរបស់ក្រុមសង្គមផ្សេងៗ ជាពិសេសក្រុមដែលងាយរងគ្រោះបំផុត។
- វិបត្តិកូវីដ ១៩ ដែលបង្កផលប៉ះពាល់លើប្រទេសជិតខាង កំពុងធ្វើឱ្យជនចំណាកស្រុករាប់ពាន់នាក់គ្មានការងារ និងមិនអាចផ្ញើប្រាក់ទៅគ្រួសារបាន។ ប្រាក់បញ្ញើនោះជាធនធានដ៏សំខាន់សម្រាប់ឧបត្ថម្ភដល់គ្រួសារនៅជនបទ។

វិបត្តិនេះនឹងប៉ះពាល់ដល់ប្រជាជនកម្ពុជាទាំងអស់ ប៉ុន្តែស្ត្រីនឹងរងផលប៉ះពាល់ខ្លាំងជាងគេ។ ស្ត្រីជាអ្នកកាន់កាប់សហគ្រាសពាណិជ្ជកម្មខ្នាតតូចក្រៅប្រព័ន្ធភាគច្រើន និងមានសមាសភាគយ៉ាងច្រើនលើសលប់ក្នុងវិស័យការងារដែលផ្តល់ប្រាក់ឈ្នួល ទាប ក្រៅប្រព័ន្ធ និងមិនសូវជាប់លាប់។ នៅទីជនបទស្ត្រីដែលជាមេគ្រួសារ (២០%-២៤% នៃគ្រួសារសរុប) និងស្ត្រីគ្មានដីធ្លី មនុស្សចាស់ដែលជាអ្នកមើលថែកូនៗរបស់ពលករចំណាកស្រុក និងស្ត្រីជំពាក់បំណុលក៏ងាយរងគ្រោះខ្លាំងណាស់ដែរ។ ក្នុងពេលមានវិបត្តិ ស្ត្រី និងក្មេងស្រីជាអ្នកទទួលបន្ទុកលើការដោះស្រាយអសន្តិសុខស្បៀង។ បន្ទុកការងាររបស់ពួកគាត់កើនឡើង ឬបង្ខំឱ្យពួកគាត់ប្រឡូកក្នុងសកម្មភាពមិនជាប់លាប់ដែលធ្វើឱ្យបាត់បង់ឱកាសអប់រំ និងការងារល្អប្រសើរ។ តាមពិត បុរសក៏រងផលប៉ះពាល់ដោយសារវិបត្តិនេះ ដូចក្រុមដែលបាត់បង់ឱកាសជាច្រើននៅទីក្រុង និងទីជនបទដែរ (សហគមន៍ ជនជាតិដើមភាគតិច ក្រុមជនជាតិភាគតិច ស្ត្រី និងបុរសដែលប្រឡូកក្នុងការងារមិនជាប់លាប់ ប្រជាជនវ័យចំណាស់ ជនមានពិការភាព ឬអ្នកមានជំងឺរ៉ាំរ៉ៃ។ល។)។ វិបត្តិអាចបង្កជាឱកាសសម្រាប់ការប្រមើលមើលគំរូអភិវឌ្ឍន៍ថ្មីដែលកាន់តែមាន និរន្តរភាព បង្កើនសមធម៌លើការបែងចែកធនធាន បង្កើនសមភាពយេនឌ័រ និង សង្គមបរិយាប័ន្ន។ ទីភ្នាក់ងារអភិវឌ្ឍន៍ ជាច្រើនកំពុងធ្វើការជាមួយរដ្ឋាភិបាលកម្ពុជាដើម្បីកំណត់រកវិធានការ និងការគាំទ្រចាំបាច់ដើម្បីដោះស្រាយវិបត្តិនេះ។

ក្រោមគោលដៅនេះ ពួកគេកំពុងគ្រោងរៀបចំកម្រងការស្រាវជ្រាវដើម្បីកំណត់រកតម្រូវការរបស់ក្រុមដែលងាយរងគ្រោះបំផុត ដោយអនុវត្តក្របខណ្ឌសមភាពយេនឌ័រ និងសង្គមបរិយាបន្ន សំដៅធានានូវសមភាព និងបរិយាបន្ន និងមិនទុកនរណាម្នាក់ ចោល។

## ករណីសិក្សា ៤.១

*ការគាំទ្រដល់លទ្ធភាពចូលរៀនបឋមសិក្សា និងអត្រាគង់វង្សនៅទីជនបទ*

ករណីសិក្សានេះនឹងផ្តោតលើឃុំមួយដែលស្ថិតក្នុងតំបន់ផលិតកម្មស្រូវ។ សមាសភាគសង្គមរបស់សហគមន៍នេះឆ្លុះបញ្ចាំងពីមធ្យមភាគថ្នាក់ជាតិ ដូចជា ប្រាក់ចំណូល ធនធាន និងភាពក្រីក្រ។ ទោះជាយ៉ាងណា វិបត្តិកូវីដ ១៩ បានធ្វើឱ្យគ្រួសារជាច្រើនមានជីវភាពដុនដាបរួមទាំងយុវជនដែលបាត់បង់ការងារនៅទីក្រុង ការថយចុះចំនួនប្រាក់បញ្ញើពីពលករចំណាកស្រុក និងការថយចុះប្រាក់ចំណូលកសិកម្ម។ អាជ្ញាធរបានធ្វើការសិក្សាមួយដើម្បីវាយតម្លៃថាតើវិបត្តិនេះបង្កផលប៉ះពាល់លើការបោះបង់ការ សិក្សារបស់សិស្សនៅកម្រិតបឋមសិក្សាដោយរបៀបណា។ វិធីសាស្ត្រសមភាពយេនឌ័រ និងសង្គមបរិយាបន្ននៃការសិក្សានេះ គួរជានាការបញ្ជ្រាបសមភាពយេនឌ័រ និង សង្គមបរិយាបន្នក្នុងការវាយតម្លៃដើម្បីស្វែងយល់ពីកត្តាដែលអាចបង្កផលប៉ះពាល់ ខ្លាំងលើស្ត្រី និងក្រុមដែលបាត់បង់ឱកាស និងកូនៗរបស់ពួកគាត់ ជាកត្តាដែលជះផលមិនល្អលើលទ្ធភាពទទួលបានសេវាអប់រំ។

## ករណីសិក្សា ៤.២

*ការបង្កើនលទ្ធភាពទទួលបានសេវាមូលដ្ឋានសម្រាប់ជនក្រីក្រក្នុងទីក្រុង*

ការសិក្សានេះនឹងផ្តោតលើតំបន់ជាយក្រុងនៅក្រុងភ្នំពេញ ដែលសំបូរដោយកម្មករក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ អ្នកលក់ដូរតិចតួច អ្នករត់ឡានឈ្នួល និងគ្រួសារមានប្រាក់ចំណូលទាបផ្សេងទៀតដែលកំពុងប្រឈមនឹងហានិភ័យក្នុងអំឡុងវិបត្តិកូវីដ ១៩។ តំបន់ទាំងនេះប្រឈមនឹងកង្វះសេវាមូលដ្ឋាន ( ទឹក អនាម័យ ផ្លូវចេញចូល និងការប្រមូលសំរាម ) ដែលបង្កើនចំណាយលើការរស់នៅ។ ការសិក្សានេះមានគោលបំណងកំណត់រកតម្រូវការ និងអាទិភាពរបស់ក្រុមដែលកំពុងរស់នៅក្នុងតំបន់ទាំងនេះ ក្នុងគោលបំណងព្រាងផែនការមួយសម្រាប់ការផ្តល់សេវាមូលដ្ឋាន ដូចជា ទឹកពិសា បង្គន់អគ្គិសនី ការប្រមូលសំរាម និងបង្កើនជីវភាពរស់នៅរបស់ពួកគេ។ វិធីសាស្ត្រសមភាពយេនឌ័រ និងសង្គមបរិយាបន្ន គួរជានាការបញ្ជ្រាបសមភាពយេនឌ័រ និងសង្គមបរិយាបន្នក្នុងការវាយតម្លៃដើម្បីស្វែងយល់ពីកត្តាដែលអាចបង្កផលប៉ះពាល់ខ្លាំងលើស្ត្រី និងក្រុមដែលបាត់បង់ឱកាស ជាកត្តាដែលជះផលមិនល្អលើលទ្ធភាពស្មើភាពក្នុងការទទួលបានសេវា និងការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

## សំណួរ

- តើត្រូវមានទិន្នន័យបន្ទាប់បន្សំអ្វីខ្លះដើម្បីគ្រោងផែនការសម្រាប់ការស្រាវជ្រាវ និងគួរពិគ្រោះជាមួយអ្នកផ្ដល់ព័ត៌មានអ្នកពាក់ព័ន្ធណាខ្លះ?
- តើគួរផ្ដោតសំខាន់លើក្រុមឬគ្រួសារក្នុងសហគមន៍ណាខ្លះ? ព្រាងបញ្ជីឈ្មោះបណ្ដោះអាសន្នរបស់ក្រុម ឬគ្រួសារដែលត្រូវការការយកចិត្តទុកដាក់ រួចពន្យល់ពីមូលហេតុ?
- តើគួរប្រមូលព័ត៌មានដោយរបៀបណាពីក្រុម ឬគ្រួសារទាំងនេះ? ព្រាងវិធីសាស្ត្របណ្ដោះអាសន្នសម្រាប់ការប្រមូលទិន្នន័យ។
- តើត្រូវប្រមូលព័ត៌មានសំខាន់ៗអ្វីខ្លះពីក្រុម និងគ្រួសារទាំងនេះ? ព្រាងកម្រងសំណួរបណ្ដោះអាសន្នសម្រាប់កិច្ចពិភាក្សាក្រុមគោលដៅ ការសម្ភាសបុគ្គល ឬមធ្យោបាយផ្សេងទៀតសម្រាប់ការប្រមូលទិន្នន័យ។

## ការណែនាំ

- ជ្រើសរើសករណីសិក្សា
- អាចកែប្រែសេណារីយ៉ូករណីសិក្សាទៅតាមបទពិសោធន៍ ឬជំនាញរបស់អ្នក ដោយមិនផ្លាស់ប្ដូរទស្សនៈវិស័យស្ដីពីសមភាពយេនឌ័រ និងសង្គមបរិយាបន្ន។ ប្រសិនបើមានការផ្លាស់ប្ដូរ សូមផ្ដល់សំអាងហេតុ និងពន្យល់ពីការផ្លាស់ប្ដូរទាំងនោះ។
- សង្ខេបលទ្ធផលក្នុងស្លាយ (មិនលើស ៤ ស្លាយ)
- អាចបន្ថែមទិន្នន័យ ព័ត៌មាន មតិ ឬអនុសាសន៍តាមចិត្តចង់។

មានវីដេអូសំខាន់ៗជាច្រើនតាមប្រព័ន្ធអ៊ីនធឺណិតដែលអាចផ្ដល់ចំណេះដឹង និងជំនាញពាក់ព័ន្ធនឹងវិធីសាស្ត្រស្រាវជ្រាវបែបគុណភាព ៖

- មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវបែបគុណភាព (ភាសាអង់គ្លេស) ម៉ូឌុលទាំង ៦ ដំបូងគេ (រកបានតាមប្រព័ន្ធអ៊ីនធឺណិត) ដែលបង្ហាញដោយបណ្ឌិត Leslie Curry, Yale University

វីដេអូ ២ ខាងក្រោមបង្ហាញពីបច្ចេកទេសសម្ភាសន៍ និងផ្ដល់ការណែនាំជាក់ស្ដែងស្ដីពីរបៀបបញ្ចៀសកំហុសឆ្គងក្នុងពេលធ្វើបទសម្ភាសន៍ ៖

- បទសម្ភាសន៍ដែលមានកំហុសឆ្គង (ភាសាអង់គ្លេស)
- បទសម្ភាសន៍ដដែល ដែលគ្មានកំហុសឆ្គង (ភាសាអង់គ្លេស)



# ៥ | ការវិភាគលទ្ធផល និង ការរាយការណ៍

## ៥.១. ការកត់ត្រា

ល្អបំផុត ក្រុមស្រាវជ្រាវបែបគុណភាពគួរមានអ្នកស្រាវជ្រាវម្នាក់ដែលសួរសំណួរ។ អាចមានពីរនាក់សម្រាប់ក្រុមធំ ឬសហគមន៍ និងអ្នកកត់ត្រាម្នាក់។ អ្នកកត់ត្រាទទួលខុសត្រូវលើការកត់ត្រាសកម្មភាព សំណួរដែលបានសួរ និងចម្លើយរបស់អ្នកចូលរួម មតិយោបល់ និងការប្រាស្រ័យទាក់ទង។ ការកត់ត្រាល្អ និងគ្រប់ជ្រុងជ្រោយ ជាគន្លឹះនៃការងារចុះប្រមូលទិន្នន័យដ៏ជោគជ័យ។ ការកត់ត្រាអាចធ្វើឱ្យហត់នឿយ។ ដូច្នេះ សូមគ្រោងរៀបចំអ្នកកត់ត្រាលើសពីម្នាក់ដើម្បីចែករំលែកកិច្ចការនេះ។

គួរមានបណ្ដុំកំណត់ត្រាដាច់ដោយឡែកមួយសម្រាប់កិច្ចប្រជុំកិច្ចពិភាក្សា ឬបទសម្ភាសន៍នីមួយៗ។ នៅពេលចុះប្រមូលទិន្នន័យ កំណត់ត្រា និងការភ័ន្តច្រឡំជាច្រើននឹងកើតឡើង! ចូរដាក់កូដកំណត់ត្រាដោយប្រើព័ត៌មាន ដូចជា ឈ្មោះអ្នកកត់ត្រា ពេលវេលាកាលបរិច្ឆេទ និងទីតាំងនៃកិច្ចប្រជុំ/កិច្ចពិភាក្សា គោលបំណង ចំនួនអ្នកចូលរួម ភេទ អាយុរបស់ពួកគេ។ល។



ក្រោយកិច្ចប្រជុំ ឬបទសម្ភាសន៍នីមួយៗ អ្នកស្រាវជ្រាវគួរពិនិត្យឡើងវិញលើកំណត់ត្រាទាំងនោះដើម្បី បន្ថែមខ្លឹមសារលម្អិតលើអ្វីដែលបានកត់ត្រារួច ក្នុងគោលបំណងកែតម្រូវបញ្ហា និងពិនិត្យមើលថាតើត្រូវមានការបញ្ជាក់បន្ថែម ឬទេ។

ក្រុមគួរពន្យល់សង្ខេប និងពិនិត្យឡើងវិញលើកំណត់ត្រានៅពេលបញ្ចប់សកម្មភាពតាមថ្ងៃនីមួយៗ ដើម្បីអាចឱ្យពួកគេប្រៀបធៀបលទ្ធផល រិះរកសំណួរថ្មីៗដែលគួរសួរ និងចែករំលែកទស្សនៈ និងគំនិត។ ប្រសិនបើធ្វើកិច្ចការនេះជារៀងរាល់ថ្ងៃការធ្វើប្រតិចារិតកំណត់ត្រានៅពេលបញ្ចប់ការងារចុះប្រមូលទិន្នន័យនឹងកាន់តែងាយស្រួល។ ក្នុងពេលអនុវត្តការស្រាវជ្រាវ គេនឹងមានកំណត់ត្រាកាន់តែច្រើន ហើយប្រើគ្មានការពន្យល់សង្ខេបឱ្យបានជាប់លាប់ គេនឹងបាត់ខ្លឹមសារលម្អិត និងបញ្ហាជាច្រើន។

## ៥.២. ការវិភាគព័ត៌មាន

ការវិភាគការស្រាវជ្រាវបែបគុណភាព ជាកិច្ចការស្មុគស្មាញ និងគ្មានមធ្យោបាយស្តង់ដារដែលត្រូវតែអនុវត្តតាមនោះឡើយ។ ចំណុចនេះបណ្តាលមកពីវិធីសាស្ត្របែបគុណភាពមាន ច្រើន។ ទោះបីជាយើងមិនអាចពិភាក្សាបានស៊ីជម្រៅពីវិធីសាស្ត្របែបគុណភាពនៅក្នុងវគ្គ បណ្តុះបណ្តាលខ្លីស្តីពីសមភាពយេនឌ័រ និងសង្គមបរិយាបន្ន នេះក្តី ប៉ុន្តែមានឯកសារពាក់ព័ន្ធយ៉ាងច្រើនហើយប្រភពដែលបានដកស្រង់មួយចំនួនផ្តល់ខ្លឹមសារសង្ខេបល្អៗ (Flick et al., 2004; Denzin & Lincoln, 2008; Denzin & Lincoln, 2017)។

# ជំហានក្នុងការវិភាគប្រធានបទ សម្រាប់ការស្រាវជ្រាវបែបគុណភាព

ជំហានខាងក្រោមជាការចង្អុលបង្ហាញ និងមានគោលបំណងផ្តល់ជាតុចូលជាក់ស្តែងមួយចំនួនស្តីពីរបៀបអនុវត្តដំណាក់កាលដ៏ស្មុគស្មាញបំផុតមួយនៃដំណាក់កាលស្មុគស្មាញជាច្រើនក្នុងការស្រាវជ្រាវបែបគុណភាព។

## ប្រតិចារិកកំណត់ត្រា

1

ការធ្វើប្រតិចារិកកំណត់ត្រាជាជំហានដំបូងនៃការវិភាគ។ បន្ទាប់មក សមាជិកក្រុមគួរអានកំណត់-ត្រាទាំងនោះជាច្រើនដង។ ចាំបាច់ត្រូវអានកំណត់ត្រាឱ្យបានច្រើនដងក្នុងការស្រាវជ្រាវបែបគុណភាព។

## កំណត់ប្រធានបទគោល

2

សមាជិកក្រុមម្នាក់ៗគួរចាប់ផ្តើមកំណត់រក និងគូសបញ្ជាក់ពីបញ្ហាដែលពាក់ព័ន្ធ ដូចជា ទស្សនាទាន បញ្ហា ឱណាមិកដែលនឹងបង្កើតបានជាប្រធានបទសំខាន់ៗ។ ប្រធានបទមួយអាចមានវ៉ារ្យង់ ឬប្រធានបទរងផ្សេងៗ។
ឧ. មនុស្សអាចកំណត់រកបញ្ហាស្រដៀងគ្នា ប៉ុន្តែមានប្រតិកម្មខុសគ្នា។ បញ្ហាដូចគ្នាអាចមានផលប៉ះពាល់ខុសពីគ្នា។

## ពិនិត្យប្រធានបទគោល

3

សមាជិកក្រុមគួរសហការគ្នាពិនិត្យឡើងវិញលើប្រធានបទ និងប្រធានបទរងដែលបានកំណត់រួច ដោយពិនិត្យមើលភាពស៊ីសង្វាក់គ្នា តម្រែតម្រង់ឱ្យស៊ីគ្នា និងឯកភាពលើប្រធានបទគោល និងប្រធានបទរង។

## ដាក់កូដប្រធានបទគោល

4

នៅចំណុចនោះ គេអាចដាក់កូដប្រធានបទគោល និងប្រធានបទរងបាន។ កូដជាពាក្យ ឬប្រយោគខ្លី មួយដែលសង្ខេបពីទស្សនាទានមួយ។

## ផ្ទៀងផ្ទាត់កូដ

5

គួរពិនិត្យឡើងវិញលើកំណត់ត្រាម្តងហើយម្តងទៀត ដើម្បីផ្តល់ផ្ទៀងផ្ទាត់កូដ។ ជាញឹកញាប់ កូដខ្លះត្រូវដាក់ជារួម កូដខ្លះត្រូវដាក់ដោយឡែក ឬក៏ត្រូវកំណត់ ថ្មីៗល។

បន្ទាប់ពីដំណើរការនេះ គេអាចព្រាងលំដាប់លំដោយកូដដ៏សមស្របមួយ ដែលជាមូលដ្ឋានគ្រឹះនៃការវិភាគ លទ្ធផល។ វាជាដំណើរការមួយដែលស្រដៀងនឹងការព្រាងមាតិកា ដែលមានជំពូក ជំពូករង។ល។

- ចូររំពឹងថានឹងមានការផ្លាស់ប្តូរលំដាប់លំដោយដែលត្រូវបានគិតពីដំបូងក្នុងអំឡុងពេលវិភាគ។ ជាញឹកញាប់ គេលំបាកដាក់កូដទាំងអស់តាមលំដាប់ណាស់ ព្រោះអាចមានករណីលើកលែង បញ្ហាពិសេសៗដែលលេចឡើងតែក្នុងការសម្ភាសន៍មួយចំនួន ឬបញ្ហាចម្រូងចម្រាស។ល។
- សង្ខេបគំនិតនិងពិភាក្សាជាមួយក្រុមរហូតដល់ក្រុមអាចព្រាងតារាងមួយ ឬផែនទីមួយដែលរួម អាចដាក់កូដចូលទាំងអស់។

ក្នុងពេលវិភាគ សូមជ្រើសរើស ៖

- សម្រង់សំដីរបស់បុគ្គលដែលអាចយកមកពន្យល់ពីកូដ។ សម្រង់សំដីជាចំណុចស្នូលនៃការពិពណ៌នា។
- រឿងរ៉ាវដែលប្រមូលបានពីការសម្ភាសន៍បុគ្គល ដែលអាចត្រូវបានជ្រើសរើសសម្រាប់ករណីសិក្សាដាក់លាក់។

***ទិន្នន័យបែបគុណភាពគួរត្រូវបានវិភាគរកអត្ថន័យរបស់វា។ កុំព្យាយាមគណនាភាគរយ ឬហ្វ្រេកង់ឱ្យសោះ។ លទ្ធផលនៃការវិភាគគឺរបាយការណ៍ពិពណ៌នា មិនមែនតារាងហ្វ្រេកង់នោះទេ។***

# ៥.៣. អំពី SOFTWARE សម្រាប់ការវិភាគទិន្នន័យបែបគុណភាព

បច្ចុប្បន្ន មាន Software ផ្សេងៗជាច្រើនដែលផ្តល់ការវិភាគទិន្នន័យបែបគុណភាព។ ជម្រើសក្នុងការប្រើប្រាស់ឧបករណ៍ទាំងនេះគឺទៅតាមបុគ្គល។ គ្មានភស្តុតាងបញ្ជាក់ថា Software អាចធ្វើឱ្យការវិភាគកាន់តែល្អ ឬមិនល្អឡើយ។ ខាងក្រោមនេះជាគុណសម្បត្តិ និងគុណវិបត្តិនៃ Software ទាំងនោះ (Winsome & Johnson, 2000) ៖

| | |
|---|---|
| **គុណសម្បត្តិ** | កាត់បន្ថយកិច្ចការធ្វើដោយដៃ សន្សំសំចៃពេល ជាពិសេសនៅពេលមានបណ្តុំទិន្នន័យច្រើន បង្កើនសុពលភាពទិន្នន័យ |
| **ការព្រួយបារម្ភ** | ចំណាយពេលលើការរៀនប្រើកញ្ចប់Software ដំណើរការដែលទាមទារការសម្របខ្លួន ហានិភ័យនៃការបាត់បង់ភាពស៊ីជម្រៅ និងអត្ថន័យ ហានិភ័យដែលបង្កអោយ អ្នកស្រាវជ្រាវមិនអាចយកចិត្តទុកដាក់លើការងារវិភាគ។ |

***ជារួម កញ្ចប់ Software កុំព្យូទ័រអាចធ្វើឱ្យកិច្ចការរបស់អ្នកស្រាវជ្រាវមានភាពសាមញ្ញ ប៉ុន្តែមិនមានន័យថា ភាពសាមញ្ញនោះបន្ថែមភាពស៊ីជម្រៅ និងអត្ថន័យដល់ការស្រាវជ្រាវបែបគុណភាពឡើយ។***

# ៥.៤. ការសរសេររបាយការណ៍

ការស្រាវជ្រាវបែបគុណភាពជាវិធីសាស្ត្រស្មុគស្មាញ និងគួរចងចាំចំណុចនេះនៅពេលបង្កើតសំណួរ និងវិសាលភាពនៃការស្រាវជ្រាវ។ បើការស្រាវជ្រាវមានវិសាលភាពកាន់តែធំ នឹងមានកិច្ចការកាន់តែច្រើនក្នុងការវិភាគលទ្ធផល និងសរសេររបាយការណ៍!

*សូមគិតល្អៗ និងកុំបង្កើតវិសាលភាពធំពេក!*

**គ្រោងពេលវេលាគ្រប់គ្រាន់សម្រាប់ការសរសេររបាយការណ៍សូម្បីតែអ្នកនិពន្ធដ៏មានបទពិសោធន៍ ក៏ត្រូវការពេល ច្រើនដើម្បីធ្វើរបាយការណ៍បែបគុណភាពដែរ។**

## *តើអ្នកចង់ផ្តើមសរសេរដោយរបៀបណា?*

ដើម្បីបង្កើតសំណួរស្រាវជ្រាវ និងជ្រើសរើសវិធីសាស្ត្រមួយ អ្នកស្រាវជ្រាវបានវិភាគជាស្រេចនូវឯកសារដែលពាក់ព័ន្ធនឹងប្រធានបទនៃការស្រាវជ្រាវ និងគួរព្រាងផ្នែកនេះ (នៃរបាយការណ៍) ឱ្យរួចរាល់។ ទោះជាយ៉ាងណាលទ្ធផលអាចបង្ហាញថាត្រូវវិភាគ និងបន្ថែមប្រភពផ្សេងទៀតក្នុងការវិភាគដំបូងលើឯកសារពាក់ព័ន្ធ។

## *ចាប់ផ្តើមសរសេរពីវិធីសាស្ត្រ*

ការសរសេរលម្អិតពីអ្វីដែលបានធ្វើ ជួយឱ្យក្រុមចងចាំដំណើរការ ផ្តោតអារម្មណ៍លើការស្រាវជ្រាវ និងរៀបចំខ្លឹមសារ។ នេះក៏ជាផ្នែកដ៏ងាយស្រួលមួយក្នុងរបាយការណ៍ផងដែរ (រួមទាំងការពិពណ៌នាបន្ថែមដែលជួយបណ្តុះបណ្តាលជំនាញសរសេរដល់អ្នកស្រាវជ្រាវ)។

បន្ទាប់មកសរសេរលទ្ធផលរកឃើញ ៖ ក្រៅពីលំដាប់លំដោយកូដ ផ្នែកសំខាន់ៗនៃការស្រាវជ្រាវសមភាពយេនឌ័រ និងសង្គមបរិយាបន្ន អាចជួយរៀបចំលទ្ធផលរកឃើញដូចខាងក្រោម ៖

- តួនាទី ការងារ ការបែងចែកការងារ និងផលវិបាករបស់វា៖ កូដសំខាន់ៗ និងកូដរង
- លទ្ធភាពទទួលបានធនធាន និងផលវិបាករបស់វា៖ កូដសំខាន់ៗ និងកូដរង
- ការធ្វើសេចក្តីសម្រេចចិត្ត ការចូលរួម និងទីភ្នាក់ងារ និងផលវិបាករបស់វា៖ កូដសំខាន់ៗ និងកូដរង
- តើបទដ្ឋានជះឥទ្ធិពលដូចម្តេចលើផ្នែកទាំងនេះ?<br>តើបានកំណត់រកការប្រែប្រួល ឬនិន្នាការអ្វីខ្លះ?<br>តើវាបង្កផលប៉ះពាល់អ្វីខ្លះ?៖ កូដសំខាន់ៗ និងកូដរង?
- ក្តីរំពឹងទុក និងអនុសាសន៍ ៖ កូដសំខាន់ៗ និងកូដរង។

ព្រាងការពិពណ៌នាពីលទ្ធផលរកឃើញបឋម រួចពិនិត្យឡើងវិញលើភាពស៊ីសង្វាក់គ្នា និងលុបចោលភាព ច្រំដែល ឬភាពលើសតម្រូវការ។ សូមមានភាពជាក់ស្តែង និងត្រៀមខ្លួនកាត់ចោលផ្នែកនានា។ ជាញឹកញាប់ ពង្រាងដំបូងហាក់មានទំហំកាន់តែធំ ប៉ុន្តែប្រវែងវែងមិនផ្តល់ភាពច្បាស់លាស់ទេ។

គួរបង្ហាញលទ្ធផលតាមបែបធម្មតា និងគ្មានការវិនិច្ឆ័យ។ គេអាចបង្ហាញទស្សនៈរបស់អ្នកស្រាវជ្រាវក្នុង ជំពូកស្ដីពីការពិភាក្សា និងសេចក្ដីសន្និដ្ឋាន។ នេះជាផ្នែកដែលអាចដាក់បញ្ចូលការបកស្រាយ។ នេះជាការស្រាវជ្រាវរបស់អ្នក ហើយអ្នកមានសិទ្ធិផ្ដល់ការយល់ឃើញ។

ការពិភាក្សា និងសេចក្ដីសន្និដ្ឋាន មិនគួរបង្ហាញពីលទ្ធផលថ្មីទេ ប៉ុន្តែគួរពិភាក្សា និងបកស្រាយអ្វីដែលបានរាយការណ៍ក្នុងលទ្ធផលរកឃើញ។ ប្រៀបធៀបលទ្ធផលជាមួយនឹងលទ្ធផលរកឃើញក្នុងការស្រាវជ្រាវផ្សេងទៀត គូសបញ្ជាក់ពីភាពដូចគ្នា និងពន្យល់ពីភាពខុសគ្នា។ ទទួលស្គាល់ថា លទ្ធភាពនៅមានកម្រិត និងលើកឡើងពីផ្នែកដែលត្រូវស្រាវជ្រាវបន្ថែមទៀត។

## ៥.៥. អនុសាសន៍

អនុសាសន៍សម្រាប់ការស្រាវជ្រាវសមភាពយេនឌ័រ និងសង្គមបរិយាបន្ន គួរផ្ដោតលើរបៀបបង្កើន/សម្រេចបានសមភាពយេនឌ័រ និងសង្គមបរិយាប័ន្ន និងការជម្នះឧបសគ្គ និងលុបបំបាត់គម្លាត។

ផ្ដល់អនុសាសន៍ និងផ្ដោតជាក់លាក់លើ ៖

| អ្នកពាក់ព័ន្ធ | ក្របខណ្ឌពេលវេលា | ការអនុវត្ត |
|---|---|---|
| តើនរណាគួរអ្វី? | តើត្រូវធ្វើអ្វីខ្លះក្នុងរយៈពេលខ្លី មធ្យម ឬវែង? | មិនត្រឹមតែជាអ្វីដែលត្រូវធ្វើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរបៀបធ្វើ ធនធាន ការគាំទ្រ ការចូលរួមផងដែរ។ល។ |

# ៥.៦. ឯកសារយោង

ដកស្រង់យ៉ាងផ្ចិតផ្ចង់នូវការសិក្សា ការពិនិត្យឡើងវិញ ការស្រាវជ្រាវ ឬស្ថិតិទាំងអស់ដែលរួមចំណែកដល់ការស្រាវជ្រាវ។ ដកស្រង់ប្រយោគ ឬអត្ថបទទាំងស្រុងប្រសិនបើវាបន្ថែមភាពច្បាស់លាស់។

*ត្រូវមានសុក្រឹតភាពក្នុងការដកស្រង់ឯកសារយោង។*

បច្ចុប្បន្ន មាន software ដែលជួយដាក់បញ្ចូលសម្រង់សំដីក្នុងអត្ថបទ និងរៀបចំបញ្ជីឯកសារយោង (ឧ. Mendeley)។

# ៥.៧. ការអានពិនិត្យផ្ទៀងផ្ទាត់

ការអានពិនិត្យផ្ទៀងផ្ទាត់របាយការណ៍ចុងក្រោយ ជួយពង្រឹងរបាយការណ៍ និងសម្រួលការព្រួយបារម្ភលើជំនាញសរសេរ។ សូម្បីតែអ្នកនិពន្ធជាជនជាតិដើមអង់គ្លេសក៏ឱ្យគេអានពិនិត្យផ្ទៀងផ្ទាត់អត្ថបទរបស់ខ្លួនដែរ។ បន្ថែមធនធានសម្រាប់ការអានពិនិត្យផ្ទៀងផ្ទាត់ក្នុងថវិកាសម្រាប់ការស្រាវជ្រាវរបស់អ្នក។

*យកអត្ថបទទៅឱ្យគេអានពិនិត្យផ្ទៀងផ្ទាត់ជាមុន ប្រសិនបើអ្នកគ្រោងនឹងដាក់របាយការណ៍នោះទៅអ្នកពិនិត្យគុណភាព (peer reviewers)។ ពុំនោះទេ ពួកគេនឹងគ្រាន់តែផ្តោតលើការកែតម្រូវសំណេររបស់អ្នកប៉ុណ្ណោះ។*

# ៥.៨. ការជួយពិនិត្យ

ទោះបីជាអ្នកមិនដាក់ឯកសាររបស់អ្នកជាផ្លូវការសម្រាប់ការចុះផ្សាយក្នុងទិន្នានុប្បវត្តិក្តី ក៏អ្នកគួរយកការសិក្សារបស់អ្នកទៅឱ្យសហការី ឬអ្នកជំនាញអានដែរ។ ទោះជាយ៉ាងណា អ្នកជួយពិនិត្យគួរមានសមត្ថភាពផ្នែកស្រាវជ្រាវ។ មតិយោបល់ និងធាតុចូលពីអ្នកជំនាញដែលគ្មានជំនាញជាក់លាក់ អាចធ្វើឱ្យរញ៉េរញ៉ៃ ឬគ្មានប្រយោជន៍ទៅវិញ។

> អ្នកជួយពិនិត្យដែលល្អ មានចរិតសុភាពរាបសារ ចេះជួយគ្នា និងផ្តល់យោបល់ដែលជួយពង្រឹងរបាយការណ៍របស់អ្នក។ពួកគេបញ្ចៀសការទិតៀនតែផ្តល់ការស្ថាបនា និងការគាំទ្រ។ ចូរទទួលយកមតិយោបល់ និងសំណូមពររបស់ពួកគេ ទោះបីជាវាធ្វើឱ្យការងារកាន់តែច្រើនក៏ដោយ។

# ៥.៩. សេចក្តីថ្លែងអំណរគុណ និងការផ្តល់កិត្តិយស

កុំភ្លេចថ្លែងអំណរគុណមនុស្សទាំងអស់ដែលបានរួមចំណែកដល់ការស្រាវជ្រាវ រួមទាំងអ្នកចូលរួមក្នុងការស្រាវជ្រាវ។ អរគុណអ្នកជួយពិនិត្យ និងអ្នកអានពិនិត្យផ្ទៀងផ្ទាត់ និងអ្នកដែលបានរួមចំណែកដល់ការស្រាវជ្រាវ។ ផ្តល់ការទទួលស្គាល់ដល់រូបភាពទាំងអស់ដែលលេចឡើងក្នុងរបាយការណ៍។

# ៥.១០. ឯកសារសម្រាប់ការពិភាក្សា និងលំហាត់ជាក្រុម

វគ្គទី ៥ ផ្តោតលើការវិភាគទិន្នន័យ។ ខាងក្រោមនេះជាលំហាត់មួយស្តីពីការដាក់កូដទិន្នន័យដែលត្រូវបានបង្ហាញក្នុងវគ្គបណ្តុះបណ្តាលនេះ ៖

## ករណីសិក្សា ៥.១

*Analyzing Gender Relations in Garment Factories*

- ការស្រាវជ្រាវពីទំនាក់ទំនងយេនឌ័រក្នុងរោងចក្រកាត់ដេរ
- កិច្ចពិភាក្សាក្រុមគោលដៅជាមួយកម្មកររោងចក្រកាត់ដេរនៅក្រុងភ្នំពេញ ខណ្ឌដង្កោរ
- អ្នកចូលរួម ៖ ស្ត្រី ៦ នាក់ (ប្រធានសហជីព ២ នាក់) និងបុរស ១។ កម្មករទាំងអស់ ជាងដេរ ជាងកាត់
- ទីតាំង ៖ បរិវេណបន្ទប់ជួលរបស់កម្មករ
- រយៈពេល ៖ +/- ១ ម៉ោង ពេលល្ងាច
- អ្នកកត់ត្រា ៖ xxxxxx

ទំនាក់ទំនងរវាងស្ត្រី និងបុរសក្នុងរោងចក្រកាត់ដេរ





*ក ៖ (**ស្ត្រី**) ខ្ញុំជាប្រធានសហជីព ហើយបុរសដែលជាប្រធានសហជីពផ្សេងទៀត ចំអកឱ្យខ្ញុំ។ ពួកគេនិយាយថា ស្ត្រីខ្លាចច្រើន។ បុរសម្នាក់ក្នុងចំណោមនោះនិយាយថា គាត់ជាប្រធានសហជីព។ ដូច្នេះ គាត់មិនចាំបាច់ធ្វើការដូចកម្មករធម្មតាទេ ចំណែកខ្ញុំដែលជាប្រធានសហជីព នៅតែធ្វើការដូចកម្មករធម្មតា ព្រោះខ្ញុំយល់ថា ខ្ញុំគួរព្យាយាមអស់ពីលទ្ធភាពដើម្បីផលិតផលិតផលឱ្យបានច្រើន និងមានគុណភាពដូចកម្មករធម្មតាដែរ។ វាមិនមានន័យថា ខ្ញុំខ្លាចថៅកែទេ។ ខ្ញុំធ្វើអ្វីដែលខ្ញុំអាច ធ្វើបាន។ ក្នុងនាមជាសមាជិកនៃក្រុមសហជីព អ្នកតែងតែប្រឈមនឹងការបៀតបៀន ជាពិសេសការបៀតបៀនពីសន្តិសុខ យាមរោងចក្រ។*



*ខ ៖ (**ស្ត្រី**) ខ្ញុំក៏ជាសមាជិកនៃក្រុមសហជីពដែរ។ ថ្ងៃនេះ អ្នកត្រួតពិនិត្យម្នាក់បានគ្រវែងក្រណាត់ចោលលើឥដ្ឋ និងប្រាប់កម្មការនីម្នាក់រើសដាក់លើតុវិញ។ គាត់ចង់ឱ្យកម្មករធ្វើការអោយលឿន។ គាត់ជាមនុស្សអាក្រក់ និងធ្វើឱ្យកម្មករជាច្រើនមិនសប្បាយចិត្ត។ ថ្ងៃនេះ ខ្ញុំបានពិភាក្សាជាមួយរដ្ឋបាលរោងចក្រ ព្រោះខ្ញុំចង់បញ្ឈប់ទង្វើរបស់គាត់។ ពីមុនមកយើង ធ្លាប់ ទទួលជោគជ័យក្នុងករណីផ្សេងទៀតដែលពាក់ព័ន្ធនឹងអ្នកគ្រប់គ្រងអាក្រក់អញ្ចឹង ដើម្បីអោយពួកគេបញ្ឈប់ទង្វើបែបនឹង ឬឱ្យពួកគាត់សូមទោសកម្មករ។ សូម្បីតែក្រុមហ៊ុនក៏មិនចង់បានថៅកែទាំងនេះដែរ ព្រោះពួកគេបង្កបញ្ហាជាច្រើន។ យើងមានសហជីពផ្សេងទៀតនៅក្នុងរោងចក្រនេះ ប៉ុន្តែពួកគេចូលដៃចូលជើងជាមួយនិយោជក។ ដូច្នេះ សហជីពទាំងនោះមានពេលទំនេរច្រើន អាចទៅណាក៏បាន។ ប៉ុន្តែខ្ញុំវិញគឺខុសពីគេ។ ខ្ញុំត្រូវយកចិត្តទុកដាក់លើបញ្ហាទាំងនេះគ្រប់ពេល ប៉ុន្តែប្រាក់បៀវត្សរ៍របស់ខ្ញុំគឺទាបជាងគេក្នុងរោងចក្រនេះ! ប្រធានសហជីពទាំងនេះគឺជាបុរស និងមានចរិតដូចក្មេងទំនើង។ ពួកគេចំអក និងគំរាមកំហែងខ្ញុំ ប៉ុន្តែខ្ញុំមិនខ្វល់ មិនខ្លាចពួកគាត់ទេ!*



*គ ៖ (**ស្ត្រីមានផ្ទៃពោះ**) ខ្ញុំជាកម្មករក្នុងក្រុមកាត់ក្រណាត់ ហើយនៅពេលកម្មករភេទប្រុសម្នាក់ដឹកក្រណាត់មកដល់ គាត់តែងតែជ្រើសរើសផ្ទាំងក្រណាត់ណាដែលធំ និងធ្ងន់ជាងគេឱ្យខ្ញុំកាត់។ ហើយប្រសិនបើខ្ញុំរអ៊ូពីការមានផ្ទៃពោះ គាត់និយាយថា "ប្រសិនបើធ្វើមិនកើតទេ ឈប់ធ្វើការទៅផ្ទះទៅ!" គាត់ជាប្តីរបស់ប្រធានក្រុម។ ប្រុសៗក្នុងរោងចក្រនេះមានពេលទំនេរច្រើន។ ជាធម្មតាប្រុសៗជាជាងជួសជុលម៉ាស៊ីនដេរ ហើយពួកគេមិនសូវមានការងារធ្វើច្រើនទេ ព្រោះម៉ាស៊ីនដេរមិនខូចរាល់ថ្ងៃឡើយ។ នៅពេលទំនេរ ពួកគេដើរហើរដោយសេរីក្នុងរោងចក្រ ជជែកគ្នា និងញ៉ែស្រី។ នៅពេលខ្ញុំដើរទៅបង្គន់ គ្រប់គ្នា រួមទាំងប្រធានក្រុមមើលមុខខ្ញុំដោយក្រសែភ្នែកយ៉ាងចម្លែក។ ប្រធានក្រុមមិនចង់បានស្ត្រីមានផ្ទៃពោះទេ។ ការពរពោះលំបាកណាស់។ ស្ត្រីមានផ្ទៃពោះមានអារម្មណ៍មិនស្រួលខ្លួន ចម្លែកក្នុងចិត្ត និងអស់កម្លាំង និងលំបាកក្នុងខ្លួនណាស់។ យើងឆាប់ល្អិតល្ហៃក្អួត និងត្រូវបត់ជើងតូចញឹកញាប់។ ប្រធានក្រុមដែលជាស្ត្រីដែរនោះ ចំអកដាក់ស្ត្រីមានផ្ទៃពោះថា "អ្នកដែលធ្វើការមិនកើត ទៅនៅផ្ទះទៅ មិនចាំបាច់មកធ្វើការទេ"។ ពួកគេនិយាយថា ស្ត្រីមានផ្ទៃពោះធ្វើការស្លឹក យឺតយ៉ាវ ឈឺច្រើន និងសុំច្បាប់ឈប់ច្រើន។*



*យ ៖ (**ស្ត្រី**) ក្នុងរោងចក្រខ្ញុំ បុរសមានតិចជាង ១០% នៃចំនួនកម្មករសរុប ហើយពួកគេជាជាងជួសជុលម៉ាស៊ីន ប៉ុន្តែពេលខ្លះ ពួកគេគ្រាន់តែអង្គុយលេង មិនធ្វើអ្វីពេញមួយថ្ងៃ។ ប្រសិនបើបញ្ចប់កិច្ចការរួច កម្មការនីនឹងត្រូវបានគេបញ្ជូនទៅជួយផ្នែកមួយផ្សេងទៀត។ យើងមិនដែលមានពេលទំនេរទេ។ ប្រសិនបើយើងបញ្ចប់ការងារដេរប៉ាក់ គេស្នើឱ្យយើងជួយបត់សំលៀកបំពាក់ជាមួយក្រុមផ្សេងទៀត។ ប៉ុន្តែប្រុសៗអាចអង្គុយលេង និងរង់ចាំដល់ម៉ាស៊ីនមានបញ្ហា។ ប្រុសៗទទួលបានប្រាក់ឈ្នួលថេរ និងជាងពួកយើង។ ប្រសិនបើយើងពិភាក្សាពីសមភាពប្រាក់ឈ្នួល ពួកគេនិយាយថា យើងមិនអាចប្រៀបធៀបប្រាក់ខែរបស់ប្រុស និងស្រីបានទេ ព្រោះយើងធ្វើការក្នុងផ្នែកខុសគ្នា។ មាន បុរសផ្សេងទៀតដែលត្រូវបានជ្រើសរើសបណ្តោះអាសន្នឱ្យទទួលខុសត្រូវលើការលើកដាក់ទូកុងតឺន័រ ឬកិច្ចការស្រដៀងគ្នាសម្រាប់រយៈពេលតែ ១ ឬ ២ សប្តាហ៍ប៉ុណ្ណោះ។ រោងចក្រមិនងាយជ្រើសរើសបុរសឱ្យធ្វើការទេ។ ប្រធានគ្រប់គ្រងរោងចក្រខ្លាចកម្មករភេទប្រុស ព្រោះប្រុសៗរអ៊ូរទាំច្រើន។ ទោះបីជាស្ត្រីគ្មានជំនាញ ប៉ុន្តែរោងចក្រជ្រើសរើស និងបណ្តុះបណ្តាលពួកគេ ហើយប្រសិនបើស្ត្រីមិនសូវមានជំនាញដេរប៉ាក់ រោងចក្រនឹងបញ្ជូនយើងទៅផ្នែកមួយផ្សេងទៀត។ ប៉ុន្តែប្រសិនបើប្រុសៗគ្មានជំនាញ ឬសញ្ញាបត្រ រោងចក្រនឹងមិនរើសពួកគេឱ្យចូលធ្វើការទេ។*



*ង ៖(**ស្ត្រី**) មានករណីនៃការបៀតបៀនផ្លូវភេទ។ ជាពិសេសប្រសិនបើកម្មការនីស្លៀកសំលៀកបំពាក់សិចស៊ី។ យើងមានបញ្ហានៃការបៀតបៀនផ្លូវភេទក្នុងរោងចក្រនេះ។ កម្មករភេទប្រុស អ្នកបច្ចេកទេស និងសន្តិសុខ បៀតបៀន និងព្យាយាមប៉ះពាល់កម្មការនីទាំងនោះ ឬនិយាយពាក្យមិនល្អ ឬនិយាយកំប្លែង។ រោងចក្រកំណត់ថា អ្នកដែលស្លៀកសំលៀកបំពាក់ សិចស៊ីត្រូវឈរមុខកម្មករផ្សេងទៀតឱ្យគេមើល។ គួរឱ្យអាម៉ាស់ណាស់ ប៉ុន្តែបន្ទាប់មក យើងបាននិយាយជាមួយសហជីពពីបញ្ហានោះ ហើយរោងចក្របានលុបគោលការណ៍នោះចោល។*



*ច ៖ (**បុរស**) ខ្ញុំត្រូវបានបណ្តេញចេញពីរោងចក្រចាស់ ព្រោះខ្ញុំជួយកម្មការនីដែលសែងកាតុងធ្ងន់ៗនៅពេលដែលប្រញាប់ ខ្លាំង។ និយាយតាមត្រង់ក្នុងរោងចក្រនេះ គេមិនខ្វល់ថាស្រី ឬប្រុសទេ ហើយគេតឿនឱ្យកម្មការនីលីសែង សូម្បីតែរបស់ធ្ងន់ ខ្លាំង។ យើងមានប្រធានសហជីពជាស្ត្រី ហើយសមាជិកសហជីពផ្សេងទៀត (បុរស) ចំអកឱ្យ គាត់។ ពួកគេនិយាយថាគាត់មិនរឹងមាំ។ អ្នកខ្លះរករឿងរំខានគាត់ដោយនិយាយថា "មនុស្សស្រី សក់វែង គំនិតខ្លី និងនោមមិនផុតកែងជើង"។ សូមទោសដែលខ្ញុំនិយាយដូច្នេះ ប៉ុន្តែខ្ញុំទុកចិត្តគាត់។ គាត់ក្លាហាន គាត់ការពារពួកយើង។ ក្នុងរោងចក្រថ្មីនេះ ខ្ញុំធ្វើការងារថែមម៉ោងជាង ៦ ខែមកហើយ រួមទាំងថ្ងៃអាទិត្យ។ ខ្ញុំមានអារម្មណ៍អស់កម្លាំង និងមិនស្រួលខ្លួន។ គាត់បានអង្គុយជាមួយខ្ញុំ និងកម្មករផ្សេងទៀតនៅពេលសម្រាកញ៉ាំបាយថ្ងៃត្រង់ និងបាននិយាយជាមួយផ្នែករដ្ឋបាលពីបញ្ហានេះ។ គាត់ហ៊ាននិយាយ។*



## ការណែនាំ

- ព្យាយាមកំណត់រកប្រធានបទ និងប្រធានបទរងឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន
- ដាក់កូដប្រធានបទ និងប្រធានបទរង
- គូសបញ្ជាក់ពីបញ្ហា ឬទស្សនទានដែលត្រូវការការបកស្រាយបន្ថែម
- គូសបញ្ជាក់ពីបញ្ហាអន្តរវិស័យ
- ផ្តោតលើកូដ និងការវិភាគ សូមព្យាយាមរិះរកសំណួរសម្រាប់កិច្ចពិភាក្សាក្រុមគោលដៅ ឬបទសម្ភាសន៍បន្ថែម។

មានធនធានអនឡាញជាច្រើនស្តីពីការវិភាគទិន្នន័យបែបគុណភាព។ ខាងក្រោមនេះជាតំណភ្ជាប់កម្រងមេរៀនយ៉ាងលម្អិតស្តីពីការវិភាគទិន្នន័យក្នុងការស្រាវជ្រាវបែបគុណភាព ដែលផ្តល់ដោយសាស្ត្រាចារ្យ Graham R. Gibbs ៖

ការធ្វើប្រតិចារិកសម្រាប់ការស្រាវជ្រាវបែបគុណភាព (ភាសាអង់គ្លេស)

ការដាក់កូដកំណត់ត្រា (ភាសាអង់គ្លេស)

ការដាក់កូដកំណត់ត្រា (២) (ភាសាអង់គ្លេស)

# ឯកសារយោង

*Agarwal, B.* (2010). **Gender and Green Governance - The Political Economy of Women's Presence Within and Beyond Community Forestry.** *Oxford University Press.*

*AIPP, & Bourdier, F.* (2015). **Indigenous Peoples in ASEAN: Cambodia, Asian Indigenous Peoples Pact, Chiang Mai.**

*Andaya, B. W.* (2006). **The flaming womb. Repositioning women in early modern Southeast Asia.** *Honolulu: Hawaii University Press.*

*Andersen, H.* (2019). **Multidimensional Poverty Analysis Cambodia.** Phnom Penh.

*Bergold, J., & Thomas, S.* (2012). *Participatory Research Methods: A Methodological Approach in Motion*. **Forum: Qualitative Social Research, 13**(1). https://doi.org/http://dx.doi.org/10.17169/fqs-13.1.1801.

*CIFT.* (2012). **Gender in Fisheries**. *Cochin, Indian Council of Agricultural Research.*

*CIPA-CIYA-AIPP.* (2019). **Situation of Indigenous Peoples in Cambodia.** *Phnom Penh.*

*Colfer, C.J.P., Sijapati Basnett, B., & Ihalainen, M.* (2018). **Making sense of intersectionality: A manual for lovers of people and forests. Center for International Forestry Research (CIFOR).** https://doi.org/10.17528/cifor/006793

*Colfer, Carol J. Pierce, & Daro Minarchek, R.* (2012). **Women, men and forest research, CIFOR.**

*Creswell, J.* (2014). **Research Design: Quantitative, Qualitative and Mixed Methods Approaches, 4th edition.** *Sage Publications.*

*DAC. (2017).* **Promoting Social Inclusion in Cambodia - Disability.** *Phnom Penh.*

*Denzin, N., & Lincoln, Y.* (2008). **Strategies of Qualitative Inquiry.** *Sage Publications.*

*Denzin, N., & Lincoln, Y.* (2017). **The SAGE Handbook of Qualitative Research Fifth Edition**. *Sage Publications.*

*FAO, & World Bank.* (2008). **Gender in Agriculture Sourcebook. Gender in Agriculture Sourcebook.** https://doi.org/10.1596/978-0-8213-7587-7

*Flick, U., von Kardorff, E., & Steinke, I.* (2004). **A Companion to Qualitative Research.** London: *SAGE Publications.*

*International Dev. Partners Group.* (2017). **A Common Framework for Gender Equality & Social Inclusion.** *Oxford University Press.* https://doi.org/10.1093/0198250126.003.0002

*IWGIA.* (2020). **THE INDIGENOUS WORLD 2020.** *Copenhagen: The International Work Group for Indigenous Affairs (IWGIA).*

*Jackson, L. M.* (2011). **The psychology of prejudice: From attitudes to social action. The psychology of prejudice: From attitudes to social action.** *American Psychological Association.* https://doi.org/10.1037/12317-000

*Jacobsen, T.* (2008). **Lost Goddesses: The Denial of Female Power in Cambodian History.** *(NIAS Press, Ed.). Copenhagen.*

*Jain, D., & Elson, D.* (2011). **Harvesting Feminist Knowledge for Public Policy.** *New Delhi: Sage Publications.*

*Kabeer, N.* (2005). **Social exclusion : concepts , findings and implications for the MDGs.** *Institute of Development Studies, (September), 1–33.*

*Lansky, M., Ghosh, J., Meda, D., & Rani, U.* (2017). **Women, Gender and Work Volume 2 Social Choices and Inequalities** *(Vol. 2). Geneva: ILO.*

*Ministry of Women's Affairs Cambodia.* (2014a). **Cambodia Gender Assessment- Rights: Vulnerable Groups of Women and Girls.** *Phnom Penh.*

*Ministry of Women's Affairs Cambodia.* (2014b). **Neary Rattanak IV- Cambodia Gender Strategi Plan 2014-2018.** *Phnom Penh.*

Moree, D. *(2018).* ***Qualitative Approaches to Studying*** **Marginalized Communities.** *Oxford Research Encyclopedia of Education, (May), 1–23.* https://doi.org/10.1093/acrefore/9780190264093.013.246

*NIS.* (2014). **Cambodia, Demographic and Health Survey 2014.** *Phnom Penh.*

*OECD Development Centre.* (2017). **Youth Well-being Policy Review of Cambodia.** *Paris.*

*OHCHR.* (2014). **Gender Stereotypes, Women's Rights and Gender Section, OHCHR Research and Right to Development Division.**

*Park, C. M. Y., & Maffii, M.* (2017). **'We are not afraid to die': gender dynamics of agrarian change in Ratanakiri province, Cambodia.** *Journal of Peasant Studies, 6150(December), 1–20.* https://doi.org/10.1080/03066150.2017.1384725

*Quisumbing, Agnes R.; Meinzen-Dick, R. S., & Raney, Terri L.; Croppenstedt, André; Behrman, J. A. .* (2014). **Gender in Agriculture.** *(A. R. Quisumbing, R. Meinzen-Dick, T. L. Raney, A. Croppenstedt, J. A. Behrman, & A. Peterman, Eds.). Dordrecht: Springer Netherlands.* https://doi.org/10.1007/978-94-017-8616-4

*Razavi, S.* (2009). **Engendering the political economy of agrarian change.** *Journal of Peasant Studies, 36(1), 197–226.* https://doi.org/10.1080/03066150902820412

*Royal Government of Cambodia.* (2017). **National Aging Policy 2017-2030.** *Phnom Penh.*

*Saunders, B., Sim, J., Kingstone, T., Baker, S., Waterfield, J., Bartlam, B., … Jinks, C.* (2018). **Saturation in**

**qualitative research: exploring its conceptualization and operationalization.** *Quality and Quantity, 52(4), 1893–1907.* https://doi.org/10.1007/s11135-017-0574-8

*Schubotz, D.* (2020). **Participatory Research: Why and How to Involve People in Research.** *London: SAGE Publications Inc.*

*Scott, J. C.* (2009). **The art of not being governed: An anarchist history of upland Southeast Asia. The Art of Not Being Governed: An Anarchist History of Upland Southeast Asia.** *New Haven: Yale University Press.* https://doi.org/10.1080/10848770.2013.791444

*Smeru Research Institute.* (2018). **Gender and Social Inclusion (GESI) Contextual Analysis.** *Jakarta.*

*UNDP.* (2015a). **Humanity Divided: Confronting Inequality in Developing Countries. A Report of United Nation Development Program.** *New York.* https://doi.org/10.1016/S0963-8687(02)00022-7

**UNDP.** (2015b). **What does it mean to leave no one behind ? A framework for implementation.** *New York.*

*UNDP.* (2016). **Leaving no One Behind: The Imperative of Inclusive Development.** *UNDP Department of Economic and Social Affairs DESA.*

*UNESCO.* (2016). **World Social Science Report 2013.** *OECD.* https://doi.org/10.1787/9789264203419-en

*Winsome, J., & Johnson, P.* (2000). **The Pros and Cons of Data Analysis Software for Qualitative Research.** *Journal of Nursing Scholarship, 32(4), 393–397.* https://doi.org/10.1111/j.1547-5069.2000.00393.x

កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា (២០១៩-២០២៣) គឺជាកម្មវិធីមួយមានរយៈពេលបួនឆ្នាំ ដែលផ្តួចផ្តើមឡើងដោយអង្គការមូលនិធិអាស៊ី ក្នុងគោលបំណងរួមចំណែកពង្រឹង សមត្ថភាពស្ថាប័នស្រាវជ្រាវ ដើម្បីលើកកម្ពស់ការស្រាវជ្រាវ ប្រកបដោយគុណភាព ដែលអាចប្រើប្រាស់ជាទិន្នន័យ គាំទ្រដល់ការវិភាគ និងការពិភាក្សាអំពីគោលនយោបាយសាធារណៈនៅកម្ពុជា ក្រោមការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្រ្តាលី។

## អង្គការមូលនិធិអាស៊ី


ផ្ទះលេខ៥៩ ផ្លូវ២៤២ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ponlokchomnes@asiafoundation.org
(+៨៥៥) ០២៣ ២១០ ៤៣១




Australian Aid

ពន្លក ចំណេះ

The Asia Foundation